

# រ៉េដបូក និងកម្ពុជា៖ ការផ្សារភ្ជាប់ទស្សនៈ និងការចូលរួមរបស់សហគមន៍

*របាយការណ៍សិក្ខាសាលាអប់រំផ្សព្វផ្សាយតាមបណ្តាខេត្តដើម្បីលើកកំពស់ការ ចូលរួមរបស់អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើម*



**ចងក្រងនិងកែសម្រួល :**

សៀវភៅនេះកែសម្រួលដោយ លោកសំអឿន សុធីរ៉ូ និងលោកស្រី ជេន ថេល័រ របស់ក្រុមហ៊ុន អេសខនសាល់ថេនស៊ី ( S-Consultancy )

រចនាដោយ ក្រុមហ៊ុន អេសខនសាល់ថេនស៊ី ( S-Consultancy )
- គម្របរូបថត : WWF, NTFP-EP
- រូបថតខាងក្នុង : NTFP-EP, CDA, AFD, NTFP, WCS

**ឯកសារច្បាប់ចំលងនៃរបាយការណ៍នេះគឺអាចរកបាននៅ :**

**NTFP-EP**
អាស័យដ្ឋាន៖ ផ្ទះលេខ ១០Eo ផ្លូវ៤២០ សង្កាត់បឹងត្របែកខ័ណ្ឌចំការមន ក្រុងភ្នំពេញកម្ពុជា។
ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៧២៧ ៤០៧
អ៊ីម៉ែល : ntfp_epc@online.com.kh

**NGO Forum on Cambodia**
អាស័យដ្ឋាន៖ ផ្ទះលេខ ៩-១១ ផ្លូវ៤៧៦ សង្កាត់ទួលទំពូង ភ្នំពេញកម្ពុជា។
ទូរស័ព្ទលេខ៖ (+៨៥៥) ២៣ ៩៩៤ ០៦៣
អ៊ីម៉ែល : ngoforum@ngoforum.org.kh

**CDA**
អាស័យដ្ឋាន៖ ភូមិដូនកែន ស្រុកសំរោង ក្រុងសំរោង ខេត្តឧត្តមានជ័យ កម្ពុជា។
ទូរស័ព្ទលេខ៖ (+៨៥៥) ១៧ ២២៣ ០៥០
អ៊ីម៉ែល : cambodiacda@gmail.com.kh

រក្សាសិទ្ធិ@2013

# វេដបូក និងកម្ពុជា៖ ការផ្សារភ្ជាប់ទស្សនៈ និងការចូលរួមរបស់សហគមន៍

*របាយការណ៍សិក្ខាសាលាអប់រំផ្សព្វផ្សាយតាមបណ្ដាខេត្តដើម្បីលើកកំពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើម*

២០១៣

# មាតិកា


បញ្ជីរពាក្យបំព្រួញ ៦
សេចក្តីថ្លែងអំណរគុណ ៨
សេចក្តីផ្តើម ១០

របាយការណ៍៖
ខេត្តឧត្តរមានជ័យ ១៣
ខេត្តកំពង់ធំ ៣៣
ខេត្តព្រះវិហារ ៤៧
ខេត្តមណ្ឌលគិរី ៥៧
ខេត្តរតនៈគិរី ៦៥
ខេត្តស្ទឹងត្រែង ៧៥
ខេត្តពោធិ៍សាត់ ៨៥
ខេត្តកំពង់ស្ពឺ ៩៧

បញ្ជីរឧបសម្ព័ន្ធ
បញ្ជីឈ្មោះអ្នកចូលរួម ១០៦
កម្មវិធីសិក្ខាសាលា ១២១
បទបង្ហាញ ១២៥
គំនូសព្រៀងស្តីពីការគ្រប់គ្រងព្រៃឈើ ១៥២

# បញ្ជីពាក្យបំព្រួញ

| | |
|---|---|
| AEC | Action for Environment and Communities |
| AFD | Action for Development |
| AIPP | Asia Indigenous People Pact |
| AK | Anakut Kumar |
| BFDK | Buddhism for Development Kampong Thom |
| CANDO | Cambodia NTFP Development Organization |
| CBOs | Community Based Organization |
| CDA | Children's Development Association |
| CEPA | Culture and Environment Preservation Association |
| CF | Community Forestry |
| CFI | Community Forestry International |
| CFMC | Community Forestry Management Committee |
| CIYA | Cambodia Indigenous Youth Association |
| CLEC | Community Legal Education Center |
| CPA | Community Protected Area |
| CPN | Community Peacebuildiing Network |
| CSO | Civil Society Organization |
| DoE | Department of Environment |
| DoH | Department of Health |
| DPA | Development Partners in Action |
| EHE | Environment and Health Education |
| EIA | Environmental Impact Assessment |
| ELC | Economic Land Concession |
| EPDO | Environment Protection for Development Organization |
| EU | European Union |
| EWMI | East-West Management Institute |
| FA | Forestry Administration |
| FAC | Forestry Administration Cantonment |
| FAO | Food and Agriculture Organization of the United Nations |
| FCPF | Forest Carbon Partnership Facility |
| FiA | Fisheries Administration |
| IADC | Indigenous Agriculture Development Cambodia |
| ICSO | Indigenous Community Support Organization |
| IDEA | Independent Democracy of Informal Economy Association |
| IPs | Indigenous Peoples |
| IRAM | Indigenous Rights Active Members |

| | |
|---|---|
| KCB | Krom Chnom Bramang |
| KIPD | Khmer Institute for Peace and Development |
| KLA | Khmer Lue Association |
| LWD | Life with Dignity |
| MAFF | Ministry of Agriculture, Forestry and Fisheries |
| MoE | Ministry of Environment |
| MVI | My Village |
| NAPA | National Adaptation Programme of Action |
| NCDD | National Committee for Sub-national Democratic Development |
| NGO | Non-Governmental Organization |
| NGOF | NGO Forum on Cambodia |
| NTFPs | Non-Timber Forest Products |
| NTFP-EP | Non-Timber Forest Products Exchange Programme |
| OPKC | Organisation to Promote Kuy Culture |
| PK | Ponleur Kumar |
| PRA | Participatory Rural Assessment |
| PVT | PrumVihear Thor |
| RECOFTC | Regional Community Forestry Training Center for Asia and the Pacific (Center for People and Forests) |
| REDD | Reducing Emissions from Deforestation and Forest Degradation |
| RGC | Royal Government of Cambodia |
| R-PIN | Readiness Plan Idea Note |
| SCW | Save Cambodia's Wildlife |
| SDC | Swiss Agency for Development and Cooperation |
| SLC | Social Land Concession |
| 3SPN | 3S Rivers Protection Network |
| UNDP | United Nations Development Programme |
| UNFCCC | United Nations Framework Convention on Climate Change |
| UN-REDD | United Nations Collaborative Programme on Reducing Emissions from Deforestation and Forest Degradation in Developing countries |
| WCS | Wildlife Conservation Society |

# សេចក្តីថ្លែងអំណរគុណ

ការសំរបសំរួលសិក្ខាសាលា និងរៀបរៀងចងក្រងរបាយការណ៍ដែលមាននៅក្នុងសៀវភៅនេះ គឺអាចប្រព្រឹត្តិទៅបានដោយមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធ និងអង្គការនានា ដែលបានដើរតួនាទីជាផ្នែកមួយក្នុងការបង្កើតនូវអ្វីដែលយើង សង្ឃឹមថានឹងក្លាយទៅជាមគ្គុទេសក៍ដ៏មានសារៈសំខាន់ សំរាប់ការអនុវត្តន៍គំរោងរ៉េដបូកនៅកម្ពុជា។ មិនតែប៉ុណ្ណោះគឺដើម្បីចូលរួមចំណែកលើកកំពស់ការយល់ដឹងទៅដល់សហគមន៍ព្រៃឈើទាំងឡាយស្តីពីសារៈសំខាន់និងតំលៃនៃព្រៃឈើព្រមទាំងកត្តានានាដែលអាចធានាចេរភាពបាន។យើងខ្ញុំសង្ឃឹមថា ការព្រួយបារម្ភ និងអនុសាសន៍នានារបស់ប្រជាជនដែលមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជា មួយនិង ព្រៃឈើក្នុងប្រទេសកម្ពុជា នឹងត្រូវបានគេលើកយកមកពិចារណាក្នុងការរៀបចំ គោលនយោបាយ និងផែនការនានាដែលផ្តោតទៅលើការទទួលស្គាល់សិទ្ធ ហើយដែលទន្ទឹមនិងគ្នានោះក៏អាចលើកកំពស់ សុវត្ថិភាព និងជីវភាពរបស់ពួកគេ។

ជាពិសេស សូមថ្លែងអំណរគុណចំពោះ ៖

**អ្នកផ្តល់មូលនិធិ៖**

យើងខ្ញុំសូមថ្លែងអំណរគុណសំរាប់ការគាំទ្រផ្នែកហិរញ្ញវត្ថុពីសំណាក់ភ្នាក់ងារមួយចំនួនដូចជា៖ Global Green Grants; Action Aid; World Bank/Forest Carbon Partnership Facility; Swiss Agency for Development and Cooperation; and East-West Management Institute តាមរយៈអង្គការមួយចំនួនដូចជា : CDA, NTFP-EP, AIPP

**អ្នកសំរបសំរួលសិក្ខាសាលា**

- កញ្ញា ហ្វេមី ពីនតូ (NTFP-EP)
- លោក ឆឹង ស៊ីរីយ៉ា (NTFP-EP)
- លោក ណក់ វ៉ែន (NTFP-EP)
- លោក ជី បូរ៉េត (CDA)
- លោក ស្មៀន បូរីវត្ន (CDA)
- លោក សេង សុខខេង (CPN)
- លោក ហួន គឹមហុង (EWMI)
- លោក ហ៊ាន ប៊ុនហៀង (AIPP)
- កញ្ញា តេង រិទ្ធិនី (NGOF)

- លោក អាង ជាតិលោម (PKH)
- លោក ភាព សុជា (CIYA)
- លោកស្រី ហ៊ី សុម៉ាលី (CLEC)
- លោក វ៉ន ពៅ (IDEA)
- លោក ជុំ ឈាន (NTFP)

អ្នករៀបចំនៅតាមបណ្តាខេត្ត និងភ្ញៀវកិត្តិយស

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នករៀបចំកម្មវិធីនៅតាមបណ្តាខេត្តនានាមានដូចជា៖ BFDK, EHE, PKH, KIPD, WVS, RECOFTC, CIYA, CLEC, MVI, NTFP, និងភ្ញៀវកិត្តិយសទាំងឡាយដែលបានផ្តល់នូវការគាំទ្រ ដោយមានវត្តមាននៅក្នុងសិក្ខាសាលា ព្រមទាំងផ្តល់នូវវិចារណកថាស្វាគមន៍ទៅដល់អ្នកចូលរួម។ យើងខ្ញុំក៏សូមសំដែងនូវការដឹងគុណជូនចំពោះតំណាងរាជរដ្ឋាភិបាល និងមន្ត្រីជាន់ខ្ពស់នៅក្នុងខេត្តនីមួយៗ ដែលបានចំណាយពេលវេលាដ៏មានតំលៃបង្ហាញពីការគាំទ្រទៅដល់គំនិតផ្តួចផ្តើមនេះ។

**អ្នករៀបរៀងឯកសារ**

- លោក ឆឹង ស៊ីរីយ៉ា (NTFP-EP)
- លោក ណក់ វ៉េន (NTFP-EP)
- លោក ស្មៀន បូរីវឌ្ឍ (CDA)
- លោក សេង សុខហេង (CPN)
- លោក លី ខុម (BFDK)

**អ្នកចូលរួម**

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួម ជាពិសេសបងប្អូនជនជាតិដើមភាគតិត និងសហគមន៍មូលដ្ឋានដែលភាគច្រើនជានារី ដែលបានចូលរួមចែករំលែកទស្សនៈ ការព្រួយបារម្ភ និងអនុសាសន៍នានា។ ការប្តេជ្ញាចិត្តរបស់ពួកគេគឺមានតំលៃមិនអាចកាត់ថ្លៃបានក្នុងការធានាថាសិក្ខាសាលាទាំងអស់នេះនឹងផ្តល់នូវឥទ្ធិពលជាវិជ្ជមានដ៏យូរអង្វែង ព្រមទាំងអាចជំរុញអោយពួកគេបង្កើតនូវសកម្មភាពគោលដែលអាចផ្តល់នូវគុណប្រយោជន៍ទៅមុខទៀតបាន នៅក្នុងការអនុវត្តន៍កម្មវិធីរ៉េដបូកនៅប្រទេសកម្ពុជា។

# សេចក្ដីផ្ដើម

ការធ្វើអោយប្រសើរឡើងនៃហិរញ្ញប្បទានវិស័យព្រៃឈើ និង ការការបន្ថយផលប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុគឺជាយុទ្ធសាស្ត្រដ៏សកម្មមួយ របស់រាជរដ្ឋាភិបាលកម្ពុជាឆ្ពោះទៅរកការសំរេចបាន នូវគោលដៅអភិវឌ្ឍន៍ជាតិ។ នៅដើមឆ្នាំ២០០៨ រាជរដ្ឋាភិបាលកម្ពុជាបានដាក់បញ្ចូលនូវផែនការទស្សនៈទាន ស្ដីពីត្រៀមខ្លួនជាស្រេចរបស់ខ្លួន ឆ្ពោះទៅកម្មវិធីភាពជាដៃគូរកាបូនព្រៃឈើ (FCPF) របស់ធនាគាពិភពលោក ហើយផែនការនេះត្រូវបានទទួលយកនៅដើមឆ្នាំ ២០០៩។ ក្នុងខែតុលា ឆ្នាំ២០០៩ ប្រទេសកម្ពុជាត្រូវបានអញ្ជើញឲ្យចូលរួមក្នុងតួនាទីជាអ្នកអង្កេតស្ថានភាព របស់ក្រុមប្រឹក្សាភិបាលគោលនយោបាយកម្មវិធីយូអ៊ិនរ៉េដ។

តាមរយៈការបើកផ្លូវរបស់កម្ពុជាចូលក្នុងយូអិនរ៉េដ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ( យូអិនឌីភី )កម្ពុជា និង អង្គការស្បៀងនិងកសិកម្មពិភពលោកនៅកម្ពុជា បានប្ដេជ្ញាគាំទ្ររាជរដ្ឋាភិបាកកម្ពុជា លើដំណើរការរៀបចំផែនការសកម្មភាពរ៉េដបូក រហូតបានឈានទៅដល់ការបង្កើតនូវផែនទីបង្ហាញផ្លូវរ៉េដបូក (សំណើផែនការសកម្មភាពកម្ពុជាលើគម្រោងរ៉េដបូក)។

## ការចូលរួមរបស់អង្គការសង្គមស៊ីវិល និង សហគមន៍មូលដ្ឋាន

តាមរយៈការអនុម័តយល់ព្រមពីយូអិនរ៉េដ និង FCPF លើសំណើរៀបចំសកម្មភាព របស់រាជរដ្ឋាភិបាលកម្ពុជានៅដើមឆ្នាំ២០១១, ក្រុមអង្គការសង្គមស៊ីវិលបានទាមទារ ឲ្យមានការអប់រំផ្សព្វផ្សាយ និងជំរុញការចូលរួមរបស់បណ្ដាញសមាជិកសហគមន៍ទាំងឡាយ។ សិក្ខាសាលានេះក៏បានស្វែងយល់ផងដែរថា ការចែករំលែកព័ត៌មាន និងកិច្ចពិភាក្សា ពិគ្រោះយោបល់ទៅដល់សហគមន៍គឺមានសារៈសំខាន់ណាស់ ជាពិសេសក្នុងការចូលរួមលើកកំពស់រេដបូក និងការគាំទ្រទៅលើយុទ្ធសាស្ត្រគ្រប់គ្រង និងកាត់បន្ថយ ការប្រែប្រួលអាកាសធាតុ ដែលកត្តាទាំងនេះគឺមានទំនាក់ទំនងទៅនិងការការពារព្រៃឈើ។

## កម្មវិធីសិក្ខាសាលាទូទាំងប្រទេស

បន្ទាប់ពីរៀបចំសិក្ខាសាលានៅខេត្តឧត្តរមានជ័យកាលពីខែតុលា ឆ្នាំ២០១១ រួចមក ក៏មានសិក្ខាសាលាអប់រំផ្សព្វផ្សាយស្ដីពីសិទ្ធិសហគមន៍ គំនិតផ្ដួចផ្ដើមស្ដីពីព្រៃឈើ ធនធានធម្មជាតិ និងរ៉េដបូក។ សិក្ខាសាលានេះបានផ្ដោការយកចិត្តទុកដាក់ ទៅលើដំណើរការ គំរោងការបូនព្រៃឈើដំបូង ដោយផ្អែកទីលើការយល់ឃើញរបស់សហគមន៍មូលដ្ឋាន។ មួយវិញទៀតសិក្ខាសាលានេះក៏បាន ព្យាយាមស្វែងយល់ ពីគំរិតយល់ដឹងរបស់សហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិចអំពីបញ្ហាព្រៃឈើការប្រែប្រួលអាកាសធាតុនិងកម្មវិធីរ៉េដបូកនៅក្នុងតំបន់របស់ពួកគេ និងនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ព្រមទាំងការចូលរួមសកម្មភាព និងទស្សនៈវិស័យសំរាប់អនាគតរបស់ពួកគេផងដែរ។

សិក្ខាសាលាបឋមនេះត្រូវបានអនុវត្តតាមគំនិតផ្ដួចផ្ដើមស្រដៀងគ្នានេះ ចាប់ពីខែកុម្ភះ ទៅដល់ខែសីហា ឆ្នាំ២០១២ នៅទូទាំងប្រទេស ហើយក្នុងគោលបំណងលើក កំពស់ការយល់ដឹងរបស់សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិចអំពីគោលការណ៍និងហេតុផលនៅពីក្រោយរ៉េដបូកព្រមទាំងដំណើរការរៀបចំផែនទីបង្ហាញផ្លូវរ៉េដបូក និងការអនុវត្តផ្សេងៗ។

## គោលបំណង

- ដើម្បីធ្វើការអប់រំផ្សព្វផ្សាយ និង ផ្តល់នូវការកសាងសមត្ថភាពស្តីពីទស្សនៈទានរេ៉ដបូក
- ដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍លើការងារអនុវត្តគម្រោងរេ៉ដបូករួមមាន៖ ការពិភាក្សាលើបញ្ហាប្រឈម ឱកាស ដំណើរការ និង បទពិសោធន៍នាពេលបច្ចុប្បន្នជំវិញការគ្រប់គ្រងព្រៃឈើក្នុងប្រទេសកម្ពុជា។
- ដើម្បីប្រមូលអនុសាសន៍ និងសំណូមពរផ្ញើរជូនរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រុមការងាររេ៉ដបូកថ្នាក់ជាតិស្តីពីការអនុវត្តផែនទីបង្ហាញផ្លូវរេ៉ដបូក និង កម្មវិធីរេ៉ដបូកថ្នាក់ជាតិ។

ប្រធានបទលំអិតរបស់សិក្ខាសាលាគឺមានលក្ខណៈប្លែកៗគ្នាខ្លះ ដោយផ្អែកទៅលើស្ថានភាព ក្នុងខេត្តនីមួយៗ ហើយ និងត្រូវបានបញ្ជាក់នៅក្នុងរបាយការណ៍នេះ។

## វិធីសាស្រ្តនៅវគ្គសិក្ខាសាលា

អ្នកសម្របសម្រួលនៅក្នុងវគ្គសិក្ខាសាលាបានប្រើប្រាស់នូវវិធីសាស្រ្តផ្សេងៗ និង ការពិភាក្សាបន្ថែម នៅកំឡុងពេលសិក្ខាសាលារួមមាន៖ ភាពយន្តឯកសារ ផ្ទាំងរូបភាព បទបង្ហាញរួមជាមួយប្រធានបទសំខាន់ៗ។ សិក្ខាសាលា ក៏បានរៀបចំឲ្យមានផងដែរ នូវការពិភាក្សាក្រុមតូចៗ ក្នុងការឆ្លុះបញ្ចាំង និង ពិពណ៌នាអំពីទិដ្ឋភាពដែលគាត់បានជួប ប្រទះនៅសហគមន៍របស់គាត់ និងអាចសួរនូវសំនួរផ្សេងៗ។ ចំនុចគន្លឹះក្នុងកិច្ចពិភាក្សារួមមាន៖

1. ផែនទីបង្ហាញផ្លូវរេ៉ដរបស់កម្ពុជានឹងបង្កើតអោយមានយុទ្ធសាស្រ្តរេ៉ដបូកថ្នាក់ជាតិ តើអ្នកមានបំណងចូលរួមក្នុងការរៀបចំនេះទេ? តើព័ត៌មានអ្វីខ្លះដែលអ្នកត្រូវការ ដើម្បីចូលរួមតាមដានក្នុងដំណើរការនេះអោយកាន់តែមានប្រសិទ្ធិភាព? តើអ្នកត្រូវការការកសាងសមត្ថភាពបែបណាដែរ?
2. ផែនទីបង្ហាញផ្លូវរេ៉ដបូករបស់កម្ពុជានឹងបង្កើតក្រុមប្រឹក្សាផ្តល់យល់ និងក្រុមបច្ចេកទេសរបស់រេ៉ដបូក ។ តើអ្នកធ្វើយ៉ាងណាដើម្បីជ្រើសរើសតំណាង អោយចូលរួមសកម្មភាពនេះ?
3. តើអនុសាសន៍គន្លឹះអ្វីខ្លះដែលអ្នកអាចផ្តល់អោយ ដើម្បីធ្វើអោយប្រាកដថាការចូលរួមរបស់ស្ថាប័នថ្នាក់មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច ទៅក្នុងការអនុវត្តផែនទីបង្ហាញផ្លូវរេ៉ដបូករបស់កម្ពុជា?

## ការគាំទ្រផ្នែកថវិកា និងបច្ចេសទេស

សិក្ខាសាលាទាំងនេះអាចប្រព្រឹត្តិទៅបានដោយមានការគាំទ្រផ្នែកថវិកាពីធនាគាពិភពលោក ទីភ្នាក់ងារប្រទេសស្វីស សំរាប់ការអភិវឌ្ឍន៍ អង្គការកត្តិសញ្ញាជនជាតិដើមភាគតិចអាស៊ី និង អង្គការ EWMI។ សិក្ខាសាលាទាំងអស់នេះ គឺបានទទួលការគាំទ្រ និងសំរបសំរួលដោយ សមាគមន៍អភិវឌ្ឍន៍កុមារ បណ្តាញកសាងសន្តិភាពសហគមន៍ និង អង្គការ NTFP-EP, NGO Forum, និង អង្គការកត្តសញ្ញាជនជាតិដើមភាគតិចអាស៊ី (AIPP)។

សៀវភៅនេះគឺជាការចងក្រងនូវរបាយការណ៍ដែលទទួលបានមកពីសិក្ខាសាលាទាំងប្រាំបី ហើយដែលរួមបញ្ចូលនូវទស្សនៈ ការព្រួយបារម្ភ យោបល់ និងសំណើរសុំពីអង្គការសង្គមស៊ីវិល តំណាងសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលបានចូលរួម ហើយមតិយោបល់ទាំងនេះត្រូវបានចងក្រងជាអនុសាសន៍សំរាប់សកម្មភាពផ្លូវការផ្សេងៗ។

# ខ្ញុំមានជ័យ



# ឧត្តរមានជ័យ

សិក្ខាសាលាលើកទីមួយនេះគឺត្រូវបានរៀបចំឡើងនៅក្នុងខេត្តឧត្តមានជ័យ ចាប់ពីថ្ងៃទី ១១ដល់ទី១៣ ខែតុលា ឆ្នាំ២០១២ នៅផ្ទះតាម៉ុក ក្នុងស្រុកអន្លង់។ សិក្ខាកាមដែលបានចូលរួមមានចំនួន៧៣នាក់ ដែលជាតំណាង មកពី៖

- ឃុំ និងសហគមន៍ក្នុងខេត្តមណ្ឌលគិរី រតនៈគិរី ព្រះវិហារ កំពង់ធំ និងឧត្តមានជ័យ
- CDA, NTFP-EP, the NGO Forum, ពន្លកខ្មែរ, និង CIYA
- បណ្តាញសហគមន៍ព្រៃឈើ

គោលបំណងនៃសិក្ខាសាលារយៈពេលបីថ្ងៃនេះគឺដើម្បី៖

១/ ផ្តល់បច្ចុប្បន្នភាពចំពោះអ្នកដែលបានចូលរួមទៅលើដំណើការ និងបញ្ហាជុំវិញគំនិតផ្តួចផ្តើមស្តីពីរ៉េដ ជាពិសេស ផែនការទាំងឡាយដែលពាក់ព័ន្ធ ទៅនិងដីធ្លី ព្រៃឈើ និងធនធានធម្មជាតិ។ ការផ្តោតការយកចិត្តទុកដាក់ជាពិសេសនេះគឺទៅលើ តំបន់សហគមន៍ព្រៃឈើចំនួន១៣ នៅក្នុងខេត្តឧត្តមានជ័យ
២/ ផ្តល់នូវឱកាសសំរាប់ការកសាងបណ្តាញសំរាប់ចែករំលែកបទពិសោធន៍ ក្នុងចំណោមសហគមន៍ផ្សេងៗ ដែលពាក់ព័ន្ធទៅនិងសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធនធានធម្មជាតិ និងគំរោងរ៉េដ រឺគំរោងក្នុងវិស័យព្រៃឈើនានា

## កិច្ចពិភាក្សា និង លទ្ធផលសិក្ខាសាលា

ថ្ងៃទី១៖ ១៥ មិនា ឆ្នាំ២០១២

លោកជី បូរ៉េដនាយកប្រតិបត្តិអង្គការ CDA បានប្រកាសបើកកម្មវិធីដោយបានថ្លែងអំណរគុណអ្នកគាំទ្រនិងអ្នករៀបចំទាំងឡាយដោយបាន ដាក់ចេញនូវគោលបំណងរបស់សិក្ខាសាលានេះ។ បន្ទាប់មកលោក ស្មៀន បុរីរ័ត្ន (CDA) បានធ្វើការសង្ខេបនូវលទ្ធផលនៃអង្គសិក្ខាសាលា ដែលបានប្រារព្វឡើងកាលពីឆ្នាំ២០១១ ជូនដល់សិក្ខាកាមទាំងអស់។
ការសង្ខេបនេះផ្តោតទៅលើការគ្រប់គ្រងធនធានធម្មជាតិ នៅក្នុងខេត្តឧត្តមានជ័យដោយបង្ហាញនូវអ្នកដែលបង្ករអោយមានការកាប់រានព្រៃឈើផងដែរ មានជាអាទិ ការរុករករ៉ែ និងការធ្វើសម្បទានដីសេដ្ឋកិច្ច ការកាប់ឈើដោយខុសច្បាប់និងការតាំងទីលំនៅរបស់កងកំលាំងប្រដាប់អាវុធនិងអ្នកភូមិ។ព័ត៌មានទាំងនេះគឺជាគ្រឹះសំរាប់ការប្រព្រឹត្តិទៅ របស់សិក្ខាសាលា។

## កំណត់ និងចាត់អទិភាពនៃការប្រឈម

សិក្ខាកាមត្រូវបានបែកចែកជាប្រាំបីក្រុម ដើម្បីពិភាក្សាបញ្ហាទាក់ទងនិងការគ្រប់គ្រងធនធាន ធម្មជាតិនៅក្នុងខេត្តចំនួនប្រាំ។ បន្ទាប់មកក្រុមទាំងនោះក៏ត្រូវបានកំណត់អោយស្វែងរក ចំនុចប្រឈមជារួម៖

1. ការកាប់ឈើ និងប្រម៉ាញ់ខុសច្បាប់
2. កង្វះខាតថវិការដើម្បីគាំទ្រការការពារព្រៃឈើ និងធនធានធម្មជាតិ និងកង្វះខាតសមត្ថភាពរបស់សហគមន៍
3. បំរែបំរួលអាកាសធាតុហួសហេតុពេក
4. ការធ្វើសម្បទានដីសេដ្ឋកិច្ច និងរុករករ៉ែ
5. កង្វះខាតក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ និងព្រៃឈើ

## ទំនាក់ទំនងរវាងបុព្វហេតុ និងបញ្ហា

ក្រុមនីមួយៗបានពិភាក្សាទៅលើរឹសគល់នៃបញ្ហា និងឥទ្ធិពលរបស់វា ដោយមានការយកចិត្តទុកដាក់ខ្ពស់ទៅលើទំនាក់ទំនងរវាងបញ្ហា និងការការពារព្រៃឈើ និងធនធានធម្មជាតិ។

១. ក្រុមពិភាក្សាខេត្តព្រះវិហារ

- សមាជិកសហគមន៍មិនមានការងារធ្វើ
- បញ្ហាទឹកជំនន់ និងភាពរាំងស្ងួត
- ដំណាំកសិកម្មកើតជំងឺ និងសត្វល្អិត
- សាមគ្គីភាពក្នុងសហគមន៍ជាមួយតំបន់ជាមួយគ្នាពុំ ល្អ ឬមានតិចតួចក្នុងឃុំក្រីក្រ
- មានក្រុមហ៊ុនមួយចុះមកវាយតម្លៃអំពីលទ្ធភាពដាំដំណាំកៅស៊ូ
- ការបរបាញ់ និងកាប់ព្រៃខុសច្បាប់ ប្រព្រឹត្តដោយពួទាហាន និងនគរបាល
- ការដណ្តើមដី និងព្រៃឈើ
- នេសាទខុសច្បាប់ ដោយប្រសម្ភារគ្រោះថ្នាក់
- ដីសម្បទានសេដ្ឋកិច្ចមានផលប៉ះពាល់ដល់ដី និង ព្រៃសហគមន៍
-ប្រជាជនក្នុងសហគមន៍បរបាញ់ដោយប្រើសម្ភារៈខុសច្បាប់

២.ក្រុមពិភាក្សាខេត្តកំពង់ធំ (CPA ឆោមធ្លក ក្នុងភូមិឆោមធ្លក ឃុំឆាមធ្លក ស្រុកសណ្តាន់ ខេត្តកំពង់ធំ និង CPA ត្រពាំងអំពិល ក្នុងភូមិស្នួច ស្រុកប្រាសាទបាល្ល័ង ខេត្តកំពង់ធំ)

- ការកាប់ឈើខុសច្បាប់ ដោយមនុស្សពីខាងក្រៅមន្ត្រីរដ្ឋាភិបាល មានអំណាច
-ក្រុមហ៊ុនកាន់តែច្រើនកំពុងធ្វើដីសំអាតព្រៃ សម្រាប់ដាំកៅស៊ូ នៅតំបន់នេះ
- តំបន់ការពាររបស់សហគមន៍គឺតូចពេកពិបាកទទួលយក មិនសមស្រប បើប្រៀបធៀបនឹងដីក្រុមហ៊ុនវិញគឺធំណាស់
- សហគមន៍ភាគច្រើនមានចំណេះដឹងតិចតួចអំពីការចូលរួមការពារព្រៃឈើ និងធនធានធម្មជាតិ
- មិនទាន់បានទទួលការអនុញ្ញាតពីក្រសួងឲ្យមានផែនការគ្រប់គ្រង សម្រាប់CPA នៅតំបន់នោះ។

៣. ក្រុមពិភាក្សាខេត្តមណ្ឌលគីរី (ភូមិស្រែអំពិល ឃុំស្រែខ្ទម ស្រុកសីម៉ា ខេត្តមណ្ឌលគីរី)

ស្ថានភាពបច្ចុប្បន្នរបស់ឃុំ

- ព្រៃឈើកំពុងទទួលរងការបាត់បង់ ដោយសារអំពីកាប់ឈើខុសច្បាប់ច្រើនពេក
- ដីកាន់តែច្រើនថែមទៀតត្រូវបង្វិលទៅឲ្យដីសម្បទានសេដ្ឋកិច្ច
- ធនធានធម្មជាតិ ៖ ក្រុមហ៊ុនកាន់តែច្រើនទៀតកំពុងចូលមកក្នុងតំបន់នេះ

៤.ក្រុមពិភាក្សាខេត្តរតនៈគីរី (ភូមិសាទុក ស្រុកអូរជុំ ភូមិកាចុនក្រោម ស្រុកវើនសៃ ភូមិកូឡាត ឃុំភ្នំកុក ស្រុកវើនសៃ)

-ក្រុមហ៊ុនឈូសឆាយដីសហគមន៍ នៅភូមិកាចុន ដើម្បីបណ្តុះកូនកៅស៊ូ
-ដីសម្បទានសេដ្ឋកិច្ចនៅតំបន់ភ្នំកុក ស្រុកវើនសៃ ខេត្តរតនៈគីរី
-សហគមន៍ចូលទន្ទ្រានយកដីព្រៃ និងដីក្នុងតំបន់ការពារ
-ការកាប់ឈើខុសច្បាប់ ក្នុងតំបន់ការពារ
-នៅតំបន់ដីសហគមន៍ មានសិប្បកម្មកែច្នៃគ្រឿងសង្ហារឹមយ៉ាងច្រើន
- សមាជិកសហគមន៍ព្រៃឈើមិនគោរពលក្ខខណ្ឌការងាររបស់សហគមន៍ព្រៃឈើ

៥.ក្រុមពិភាក្សាស្រុកអន្លង់វែង និងត្រពាំងប្រាសាទ

- ការកាប់ឈើខុសច្បាប់ធ្ងន់ធ្ងរ ដោយក្រុមមនុស្សមានអំណាច និងទាហានមានអំណាច
- ការទន្ទ្រានដី និងព្រៃដោយខុសច្បាប់
- ការកាប់ឈើអនាធិបតេយ្យ នៅព្រៃសហគមន៍
- ការគម្រាមកំហែងដោយពួកទាហាននៃអង្គភាព ៣០៤ ដោយប្រើកាំភ្លើង គម្រាមកំហែងដល់សមាជិកសហគមន៍ព្រៃឈើ (សហគមន៍ព្រៃឈើសាមគ្គី)
- ទាហានគម្រាមកំហែងដល់សមាជិកសហគមន៍ព្រៃឈើ មិនឲ្យចុះល្បាតមើលព្រៃក្នុងតំបន់ការពារ គម្រាមដោយ "កងពលតូចលេខ៦"
- អាជ្ញាធរមូលដ្ឋាន ស្រុកត្រពាំងតាវបំភ័យសមាជិកសហគមន៍ព្រៃឈើ មិនឲ្យចូលរួមក្នុងការការពារព្រៃឈើ
- សហគមន៍ក្រីក្រដោយសារគ្រោះធម្មជាតិដូចជាទឹកជំនន់ និងរាំងស្ងួត

៦. ក្រុមពិភាក្សាស្រុកសំរោង និងស្រុកចុងកាល

គំនិតផ្តួចផ្តើមអំពីព្រៃឈើ

- សហគមន៍ព្រៃឈើចំនួន៦ បានរៀបចំរចនាសម្ព័ន្ធរួចរាល់ ហើយបានចុះកិច្ចព្រមព្រៀងអំពីឥណទានកាបូន រវាងសហគមន៍ព្រៃឈើ និង FA នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩
- ពង្រីកសហគមន៍ព្រៃឈើមួយទៀតនៅស្រុកចុងកាល់ (ពុំទាន់អនុម័តដោយរដ្ឋាភិបាល)
- កាត់បន្ថយការកាប់ព្រៃខុសច្បាប់ កនុងតំបន់ព្រៃសហគមន៍ ឲ្យបានត្រឹម៦០% ទើបធានានិរន្តរភាពព្រៃឈើបាន

បញ្ហាប្រឈមព្រៃឈើ

- ភូមិអនាធិបតេយ្យបង្កើតក្នុងតំបន់ព្រៃសហគមន៍
-ទីតាំងប្រមូលផ្តុំអ្នករកអុសគីនៅក្បែរតំបន់សហគមន៍ព្រៃឈើ
- ការទន្ទ្រានដី និងព្រៃ ក្នុងតំបន់សហគមន៍ព្រៃឈើយកដីធ្វើស្រែ
- កងទាហានដាក់មូលដ្ឋានក្នុងតំបន់ព្រៃសហគមន៍
-ការកាប់ឈើខុសច្បាប់ច្រើនធ្វើឡើងដោយពួកមានអំណាច និងមន្ត្រីមានអំណាច

ដី

- ដីសម្បទានសេដ្ឋកិច្ចផ្ដល់ទៅឲ្យក្រុមហ៊ុន ក្នុងតំបន់ព្រៃសហគមន៍ ហើយក្រុមហ៊ុនភាគច្រើនមិនគោរពតាមច្បាប់ និងអនុក្រឹត្យស្ដីពីដីសម្បទានសេដ្ឋកិច្ចទេ (ពិគ្រោះយោបល់ និងសំណាង)
- ដីសម្បទានសេដ្ឋកិច្ច និងដីសម្បទានសង្គមកិច្ចនៅក្នុងព្រៃសហគមន៍
- ការទន្ទ្រានដី ដោយសហគមន៍

ធនធានធម្មជាតិ

- ប្រម៉ាញ់ខុសច្បាប់ក្នុងតំបន់ព្រៃសហគមន៍ ដោយប្រើសម្ភារទំនើបៗ
-ភ្លើងឆេះព្រៃក្នុងតំបន់ព្រៃសហគមន៍ បង្កការបាត់បង់ជីវចម្រុះ

៧. ក្រុមពិភាក្សាស្រុកអន្លង់វែង

-ការទន្ទ្រានដីដោយខុសច្បាប់ ជាពិសេសក្នុងតំបន់ព្រៃសហគមន៍
- ទាហានកាប់ព្រៃខុសច្បាប់ ក្នុងតំបន់សហគមន៍
- សំរោង វុធរំលោភយកដីសហគមន៍ នៅលំទងថ្មីរហូតដល់បាន ដាំដើមកៅស៊ូ

- ក្រុមហ៊ុនរុករករ៉ែឈ្មោះ "សួន វណ្ណៈ" បានមកស្រាវជ្រាវនៅភូមិលំទង និងកុកសំប៉ោរ ក្នុងទំហំដី ប្រមាណ ១១០០០ហិចតា។
- ប្រម៉ាញ់ខុសច្បាប់ នៅតំបន់ព្រៃសម្បទាន
- សមាជិកសហគមន៍ព្រៃឈើជាប្រជាជនក្រីក្រ ដូច្នេះពួកគេពិបាកក្នុងការការពារព្រៃក្នុងតំបន់ព្រៃសហគមន៍ណាស់
-គណៈកម្មាធិការសហគមន៍ព្រៃឈើមិនទាន់មានការយល់ដឹងដូចៗគ្នា (មិនទាន់ចេះសាមគ្គីគ្នា)

៨.ក្រុមពិភាក្សាស្រុកបន្ទាយអំពិល

- ទាហានកាប់ព្រៃយ៉ាងអនាធិបតេយ្យ
- ការបរបាញ់សត្វព្រៃខុសច្បាប់ ក្នុងតំបន់ព្រៃសហគមន៍
- ការទន្ទ្រានដីខុសច្បាប់ធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួននិងសង់
ផ្ទះក្នុងតំបន់ព្រៃសហគមន៍
- ដីរ៉ែសម្បទាន ក្នុងតំបន់ព្រៃសហគមន៍
- ព្រំប្រទល់ដីរបស់ខេត្តជាប់គ្នា មិនមានភាពច្បាស់លាស់
- នៅមានការទន្ទ្រានដី និងព្រៃខុសច្បាប់
- រដ្ឋាភិបាលសាងសង់ផ្លូវឆ្លងកាត់ព្រៃសហគមន៍

## លទ្ធផលនៃការពិភាក្សាតាមក្រុម

| បញ្ហា | កម្លាំងបង្ក | បុព្វហេតុ | ផលប៉ះពាល់ |
|---|---|---|---|
| ការកាប់ឈើ និង បរបាញ់ខុសច្បាប់ | កំណើនប្រជាជន- ពុំមានផែនការគ្រួសារ និងភាពក្រីក្រ | - សហគមន៍មានចំណេះដឹងតិចតួចអំពីសារសំខាន់នៃធនធានព្រៃឈើ និងធនធានធម្មជាតិ<br>- ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច<br>- សហគមន៍មួយចំនួនលោភលន់<br>- ខ្វះមធ្យោបាយផ្សេងក្នុងការចិញ្ចឹមជីវភាព និងពុំមានដីធ្វើស្រែ ឬកសិកម្ម<br>- ប្រជាជនខ្វះការអប់រំ និងខ្វះចំណេះដឹងអំពីច្បាប់ | - ប្រជាជនសហគមន៍ ធ្វើចំណាកស្រុក និងទៅប្រទេសផ្សេង ព្រោះពុំមានការងារធ្វើ ឬមុខរបរអ្វីនៅមូលដ្ឋាន<br>- សហគមន៍ច្រើនងាយជឿគេ ឲ្យគេបោក |
| ខ្វះមូលនិធិសម្រាប់គាំទ្រដល់ការការពារព្រៃឈើ និងធនធានធម្មជាតិហើយសហគមន៍ខ្វះសមត្ថភាព | | - មិនអនុវត្តតាមតួនាទីភារកិច្ចកំណត់សម្រាប់សហគមន៍ព្រៃឈើ<br>- គណៈកម្មាធិការមិនមានបទបញ្ជាផ្ទៃក្នុង<br>- ខ្វះ សាមគ្គីភាព<br>- បាត់បង់គណៈកម្មាធិការ<br>- បាត់បង់ដី និងជីវភាពធ្លាក់ចុះ បង្កឲ្យមានភាពក្រីក្រ<br>- ការល្បាតមើលព្រៃមិនគ្រប់គ្រាន់<br>-សមាជិកសហគមន៍ពុំជឿគណៈកម្មាធិការ<br>- ខ្វះសមត្ថភាពគ្រប់គ្រង ធ្វើផែនការ និងរកជំនួយ សម្រាប់សហគមន៍ព្រៃឈើ<br>- ខ្វះការគាំទ្រពីភាគីពាក់ព័ន្ធផ្សេងៗដូចជា រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល<br>- សមាជិកសហគមន៍មិនទទួលស្គាល់អំពីសារសំខាន់នៃព្រៃសហគមន៍ | - សហគមន៍ខ្វះមូលនិធិ គាំទ្រដល់ការការពារព្រៃឈើ និងធនធានធម្មជាតិ<br>- ការធ្វើចំណាកស្រុកចេះតែកើនឡើង<br>- ប្រជាជនកាន់តែក្រទៅៗ<br>- ចំនួនប្រជាជនកើនឡើង ហើយអ្នកចំណូលថ្មីក៏កើនឡើងដែរ<br>- បាត់បង់ព្រៃឈើដោយសារខ្វះការល្បាតព្រៃ<br>- ប្រព័ន្ធគ្រប់គ្រងព្រៃ សហគមន៍មានលក្ខខណ្ឌមិនសូវល្អ |
| ការប្រែប្រួល បរិយាកាសធ្ងន់ធ្ងរ | - ឧស្សាហកម្មភាវូបនីយកម្ម<br>-ការអភិវឌ្ឍសេដ្ឋកិច្ចជំរុញឲ្យមានដី សម្បទានសេដ្ឋកិច្ចកាន់តែច្រើន<br>- ទីផ្សារត្រូវការកសិកម្មពឹងផ្អែកលើបច្ចេកវិទ្យា និងកសិកម្មពឹងផ្អែកលើដើមទុនជាតុបញ្ចូល | -កាប់ព្រៃ<br>-ភ្លើងឆេះព្រៃ<br>-ផ្តល់ដីសម្បទានសេដ្ឋកិច្ចច្រើនថែមទៀត ដោយពុំមានពិគ្រោះយោបល់ជាមួយសហគមន៍<br>- ការបញ្ចេញកាបូនពីប្រទេសអភិវឌ្ឍន៍<br>- ព្រំប្រទល់ដីសម្បទាសេដ្ឋកិច្ចមិនច្បាស់លាស់ ដូច្នេះ ក្រុមហ៊ុនមានដីសម្បទានសេដ្ឋកិច្ចកាប់ឆ្ការព្រៃលើដីសហគមន៍<br>- ខ្វះថវិកាគាំទ្រដល់ការការពារព្រៃ<br>- ការទន្ទ្រានដីធ្វើកសិកម្មកាន់តែមានច្រើន | |

| | | | |
|---|---|---|---|
| | | - ប្រើប្រាស់បច្ចេកទេសទំនើប ឬសម្ភារៈទំនើបសម្រាប់ធ្វើ | - ភាពរាំងស្ងួត និងទឹកជំនន់<br>- ខ្យល់ព្យុះ<br>- អាកាសធាតុឡើងកំដៅ<br>- ប្រជាជនឈឺកាន់តែច្រើន<br>- ជីវភាពប្រជាជនក្នុង សហគមន៍ធ្លាក់ចុះ<br>- ចោរកម្មមានច្រើន<br>- ប៉ះពាល់ដល់ដំណាំកសិកម្មគ្រប់ប្រភេទ<br>- ការបាក់ដី |
| | | កសិកម្ម | |
| ដីសម្បទានសេដ្ឋកិច្ច និងដីសម្បទានរុករករ៉ែ | -គោលនយោបាយរដ្ឋាភិបាលស្តីពីការអភិវឌ្ឍសេដ្ឋកិច្ច | - ការអនុវត្តច្បាប់ភូមិបាល និងច្បាប់ព្រៃឈើ នៅមានកម្រិត (មិនបានអនុវត្តច្បាប់ដែលមានស្រាប់ ទាក់ទងនឹងធនធាន ធម្មជាតិ<br>- មិនគោរពអនុក្រឹត្យស្តីពីដីសម្បទាន សេដ្ឋកិច្ច (មានលក្ខខណ្ឌ៥ មុននឹងផ្តល់ដីសម្បទានសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុន)<br>- មិនមានយន្តការតាមដានអំពីការអភិវឌ្ឍដីសម្បទានសេដ្ឋកិច្ច ដោយសារ រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ខ្វះ<br>ថវិកា (ខ្វះយន្តការតាមដានការអនុវត្តផែនការរបស់ក្រុមហ៊ុន)<br>- ពុំមានការពិគ្រោះយោបល់ត្រឹមត្រូវជាមួយសហគមន៍មុននឹងផ្តល់ដីសម្បទានសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុន<br>- អំពីពុករលួយពាក់ព័ន្ធនឹងការផ្តល់ដី សម្បទានសេដ្ឋកិច្ច នៅស្ថាប័នពាក់ព័ន្ធនឹងការផ្តល់ដីសម្បទានសេដ្ឋកិច្ច<br>- រដ្ឋាភិបាលមានគោលនយោបាយកម្មសិទ្ធិដីធ្លីមិនទាន់គ្រប់គ្រាន់ក្នុងការផ្តល់កម្មសិទ្ធិដីធ្លី និងព្រៃឈើសមូហភាពទៅឲ្យ សហគមន៍។<br>- ពុំមានការវាយតម្លៃស្ថានភាព្រៃឈើ មុនផ្តល់ដីសម្បទានសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុន (ពុំមានកំណត់ចំណាក់ថ្នាក់ប្រភេទនៃព្រៃឈើមុននឹងផ្តល់ដីសម្បទានសេដ្ឋកិច្ចដូចជាតំបន់ណាទុកជាដីកសិកម្ម ទុកជាដីព្រៃ និងទុកជាដីសហគមន៍) | -បង្កឲ្យសហគមន៍កាន់តែក្រ ព្រោះបាត់បង់ដីកសិកម្ម និងដីព្រៃ<br>-ប្រជាជនធ្វើចំណាកស្រុកច្រើន<br>-ពលកម្មកុមារ ដោយសារជីវភាព<br>ក្រក្រី<br>-ប៉ះពាល់ដល់សុខភាពសហគមន៍ និងអំពើហិង្សា<br>-កុមារទៅសាលារៀនមិនជាប់លាប់<br>-បាត់បង់ព្រៃឈើ ជីវចម្រុះ និងដែនជម្រកសត្វព្រៃ<br>-ការប្រែប្រួលបរិយាកាសដូចជាទឹកជំនន់ និងរាំងស្ងួត<br>-បាត់បង់ដីសហគមន៍ និងដីព្រៃ<br>ដែលជាកម្មសិទ្ធិស្របច្បាប់របស់ សហគមន៍ |

| | | | |
|---|---|---|---|
| ការអនុវត្តច្បាប់ពាក់ព័ន្ធនឹង<br>ការគ្រប់គ្រងព្រៃឈើនិង<br>ធនធានធម្មជាតិនៅ<br>មានកម្រិត | | - ខ្វះចំណេះដឹង មិនស្គាល់ភាគីពាក់ព័ន្ធ<br>- រដ្ឋាភិបាលខ្វះថវិកា និងប្រាក់ខែទាប<br>- ខ្វះការយល់ដឹងនិងការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រង<br>ព្រៃឈើនិងធនធានធម្មជាតិ<br>- អំពើពុករលួយ និងបក្សពួកនិយមនៅតាម<br>ស្ថានប័នបច្ចេកទេស<br>- សហគមន៍ខ្វះការប្រាស្រ័យទាក់ទងជាមួយស្ថាប័នរដ្ឋាភិបាល<br>- សហគមន៍ខ្វះចំណេះដឹងអំពីច្បាប់ និងបទបញ្ញាពាក់ព័ន្ធនឹងធនធានធម្មជាតិ<br>និងព្រៃឈើ<br>- សហគមន៍ខ្លាចមិនហានតវ៉ាទាមទារសិទ្ធិ<br>ស្របច្បាប់ អំពីព្រៃឈើ និងធនធានធម្មជាតិ<br>-ស្ថាប័នបច្ចេកទេស ធ្វើការយឺតនិងបក្ស ពួកនិយម<br>-ខ្វះយន្តការតាមដានការអនុវត្តច្បាប់<br>-ពុំមានការជំរុញនិងលើកទឹកចិត្តឲ្យប្រជាជន<br>ស្វែងយល់អំពីច្បាប់ និងសារាចរនានា | -បទល្មើសព្រៃឈើជាច្រើន<br>បានកើនឡើង<br>-ជំរុញឲ្យការប្រើប្រាស់ផលិតផលក្រៅពីឈើមានកា<br>រធ្លាក់ចុះ<br>-បាត់បង់ធនធានធម្មជាតិនិងព្រៃឈើ<br>-អំពើពុករលួយកើនឡើងក្នុង<br>ប្រព័ន្ធរដ្ឋាភិបាល<br>-សេវារដ្ឋមានតិចតួច<br>-សហគមន៍កាន់តែក្រ |

ថ្ងៃទី២ (១២ តុលា ឆ្នាំ២០១១)

លោកស្មឿន បូរ័ត្ន បានចែកសិក្ខាកាមជាប្រាំក្រុម៖

- ក្រុមគម្រោង REDD
- ក្រុមព្រៃសហគមន៍
- ក្រុមតំបន់ការពារដីសហគមន៍
- ក្រុមពិភាក្សាខេត្តព្រះវិហារ និងកំពង់ធំ
- និងក្រុមពិភាក្សាខេត្តរតនគីរី

ដើម្បីចែករំលែកបទពិសោធន៍ ពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមការពារដី ព្រៃឈើ និងធនធានធម្មជាតិ ៖

- តើត្រូវបង្កើតគំនិតផ្តួចផ្តើមនេះយ៉ាងដូចម្តេចដែរ? រៀបចំរចនាសម្ព័ន្ធដូចម្តេច?អនុវត្តយ៉ាងដូចម្តេច? គ្រប់គ្រងដូចម្តេច និងទទួលហិរញ្ញវត្ថុដូចម្តេច?
- តើសហគមន៍មូលដ្ឋានចូលរួម សម្រេចចិត្តយ៉ាងដូចម្តេច? មានអំណាចសម្រេចចិត្តយ៉ាងដូចម្តេច?
- តើសហគមន៍មូលដ្ឋានបានប្រយោជន៍ដូចម្តេច (ឬមិនបាន)? តើការបែងចែកតួនាទីភារកិច្ចនិងប្រយោជន៍ឲ្យស្មើគ្នា ឬមិនស្មើគ្នា
- តើគំនិតផ្តួចផ្តើមនេះមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រឈម ដែលបានលើកឡើងកាលពីថ្ងៃទីមួយយ៉ាងដូចម្តេច? ហើយតើគំនិតផ្តួចផ្តើមនេះការពារដី ព្រៃឈើ និងធនធានធម្មជាតិដូចម្តេច?

ក្រុម១ ៖ ក្រុមគម្រោង REDD

ចាប់ផ្តើមគម្រោងREDD :

**១. CFMC និងបណ្តាញសហគមន៍ព្រៃឈើ**

- សហគមន៍ត្រូវបានទទួស្គាល់ជាផ្លូវការដោយរដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន (ចរចាជាមួយគណៈកម្មការដីសម្បទានសេដ្ឋកិច្ច អំពីព្រំប្រទល់ដីសហគមន៍ព្រៃឈើ)
- នៅថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០៩ សហគមន៍ព្រៃឈើបានព្រមព្រៀង ជាមួយការិយាល័យរដ្ឋបាលព្រៃឈើ
- បង្កើនការយល់ដឹង និងកសាងសមត្ថភាព របស់ CFMC និងសមាជិកពាក់ព័ន្ធ នឹងគម្រោងREDD និងអំពីការប្រែប្រួលបរិយាកាស
- ផ្សព្វផ្សាយអំពីគុណប្រយោជន៍នៃគម្រោងឥណទានកាបូន ដោយប្រើវីដេអូ
- ធ្វើដីគំរូ (ចុះបញ្ជីសារពើភ័ណ្ឌ)
- កំណត់តំបន់សម្រាប់ដាំដើមឈើឡើងវិញ តំបន់កាប់ព្រៃ និងស្ថានភាពព្រៃឈើ
- ចូលរួមក្នុងដំណើរការវាយតម្លៃជនបទតាមវិធីសាស្ត្រចូលរួម (PRA')
- ធ្វើអង្កេតអំពីជីវចម្រុះក្នុងតំបន់ព្រៃសហគមន៍

- ផ្ទៀតផ្ទាត់ឲ្យត្រឹមត្រូវដោយអ្នកឯករាជ្យអំពីគំរូប្លង់ដី
- ដាក់បង្គោលកំណត់ព្រំដែន និងសង់ការិយាល័យការពារ និងស្លាកសញ្ញា សម្គាល់ព្រៃសហគមន៍
- ចុះល្បាតព្រៃ
- បញ្ជូនរបាយការណ៍ និងបណ្តឹងអំពីការកាប់ឈើខុសច្បាប់ ទៅឲ្យរដ្ឋបាលព្រៃឈើ
- ទំនាក់ទំនងជាមួយបណ្តាញថ្នាក់ជាតិ និងចែករំលែកបទពិសោធន៍

## ២. សេចក្តីព្រាងផែនការគម្រោង REDD

- ពង្រៀងផែនការគំរោងរ៉េដ
- ចុះល្បាតព្រៃ នៅតាមព្រៃសហគមន៍ចំនួន១៣កន្លែង
- ដាក់បង្គោលសម្គាល់ព្រៃសហគមន៍
- ដាក់ស្លាកសញ្ញាសម្គាល់ព្រៃសហគមន៍
- សង់ការិយាល័យការពាររបស់ CFMC
- សង់ផ្លូវ
- ផ្គត់ផ្គង់សម្ភារៈឲ្យក្រុមល្បាតព្រៃ
- លើកកម្ពស់ជីវភាពរស់នៅ
- កសាងសមត្ថភាពរបស់CFMC/Sub-CFMC និងសមាជិក
- ផ្សព្វផ្សាយអំពីគម្រោងរ៉េដ ដល់សមាជិកព្រៃសហគមន៍ ទាំងក្នុង និងក្រៅព្រៃសហគមន៍
- បង្កើតគណៈកម្មាធិការទប់ស្កាត់រាល់ការកាប់ឈើខុសច្បាប់

## ៣. រចនាសម្ព័ន្ធបណ្តាញព្រៃសហគមន៍ នៅថ្នាក់ខេត្តឧត្តរមានជ័យ

១. ប្រធានបណ្តាញសហគមន៍ព្រៃឈើ
២. អនុប្រធានបណ្តាញសហគមន៍ព្រៃឈើ
៣. លេខាធិការ (ប្រុស)
៤. គណនេយ្យ (ស្ត្រី)
៥. សមាជិកប្រាំបួនរូប

## តួនាទី និងការទទួលខុសត្រូវរបស់បណ្តាញព្រៃសហគមន៍

- កិច្ចប្រជុំបណ្តាញប្រចាំត្រីមាស
- រៀបចំបណ្តឹង
- ជួយសម្របសម្រួលការងារជាមួយសហគមន៍ និងភាគីពាក់ព័ន្ធ
- ទំនាក់ទំនងជាមួយអាជ្ញាមូលដ្ឋាន

- រៀបចំផែនការ និងអនុវត្តផែនការ
- ចូលរួមជាមួយបណ្តាញទាំងថ្នាក់ជាតិ និងមូលដ្ឋាន
- ចូលរួម និងផ្តល់ភស្តុតាងពាក់ព័ន្ធនឹងការកាប់ឈើខុសច្បាប់ដល់តុលាការ
- ស្វែងរកមេធាវីដើម្បីគាំទ្រសហគមន៍
- កៀរគរការចូលរួមរបស់សហគមន៍ និងបញ្ជូនទៅយន្តការតែមួយ
- ទំនាកទំនងជាមួយអង្គការជាតិ និងអន្តរជាតិ
- ផ្សព្វផ្សាយក្របខ័ណ្ឌច្បាប់ និងសារប្រយោជន៍នៃការគ្រប់គ្រងព្រៃឈើ និងធនធានធម្មជាតិប្រកបដោយនិរន្តរភាពពីការប្រើប្រាស់ ផលិតផលមិនមែនឈើឲ្យមាននិរន្តរភាព

ក្រុម២ ៖ ក្រុមព្រៃសហគមន៍នៅខេត្តឧត្តរមានជ័យ

តើគំនិតផ្តួចផ្តើមអ្វីដែលអាចធ្វើកើត ? តើត្រូវរៀបចំរចនាសម្ព័ន្ធយ៉ាងដូចម្តេច អនុវត្តយ៉ាងដូចម្តេច គ្រប់គ្រងយ៉ាងដូចម្តេច និងផ្តល់ហិរញ្ញវត្ថុយ៉ាងដូចម្តេច ?

- ផ្សព្វផ្សាយអំពីសារប្រយោជន៍នៃព្រៃសហគមន៍
- ដាក់បង្គោលព្រំប្រទល់ និងស្លាកសញ្ញាសម្គាល់ព្រៃសហគមន៍
- ចែកក្រុមដើម្បីការពារ និងល្បាតព្រៃឈើ
- សង់ការិយាល័យការពារព្រៃឈើ
- ស្វែងរក UTM របស់ GPS
- សហការជាមួយភាគីពាក់ព័ន្ធគន្លឹះៗ
- ល្បាតព្រៃ និងហាមឃាត់ការកាប់ឈើខុសច្បាប់
- ផ្តល់ភស្តុតាងអំពីអំពីខុសច្បាប់ដល់ស្ថាប័នពាក់ព័ន្ធ

រចនាសម្ព័ន្ធគ្រប់គ្រង

១. ប្រធានសហគមន៍ព្រៃឈើ
២. អនុប្រធានសហគមន៍ព្រៃឈើ
៣. លេខាធិការ (ប្រុស)
៤. គណនេយ្យ (ស្ត្រី)
៥. ការល្បាតព្រៃ
៦. ការដាំដើមឈើឡើងវិញ

សកម្មភាពគន្លឹះៗដែលបានអនុវត្តកន្លងមក

- បង្កើតផែនទីផ្លូវការ
- ចាត់ចែងក្រុម និងកៀរគរឲ្យមានការចូលរួម

- ជ្រើសតំណាងក្រុម
- ជ្រើសរើសគណៈកម្មាធិការ និងអនុគណៈកម្មាធិការ
- ទទួលស្គាល់ជាផ្លូវការ ដោយប្រធានឃុំ ដូចជា ដីការ ច្បាប់ និងបទបញ្ជា
- សេចក្តីណែនាំរបស់ក្រសួងអំពីសហគមន៍ព្រៃឈើ
- តំបន់មានសក្តានុពលខ្ពស់ ត្រូវទទួលការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- ស.ជ.ណ ពាក់ព័ន្ធនឹងគម្រោងREDD ចេញដោយខុដ្ឋកាល័យក្រសួង
- កិច្ចព្រមព្រៀងរវាងរដ្ឋបាលព្រៃឈើ និងCFMC

តើសហគមន៍មូលដ្ឋានទទួលបានប្រយោជន៍អ្វីខ្លះ

- រួមចំណែកដោយសមាជិកសហគមន៍ព្រៃឈើ
- បង្កើតក្រុមជួយខ្លួនឯង
- ផ្តល់មូលនិធិដោយCDA Oxfam-GBUNDP និងមនុស្សធម៌

តើគំនិតផ្តួចផ្តើមនេះមានប្រសិទ្ធភាពយ៉ាងណា ក្នុងការដោះស្រាយបញ្ហាប្រឈមដែលបានពិភាក្សាថ្ងៃទី១

- សហគមន៍ចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងអនុវត្តផែនការគ្រប់គ្រងសហគមន៍
- ចូលរួមវគ្គបណ្តុះបណ្តាលអំពីការគ្រប់គ្រងព្រៃឈើ
- ចូលរួមផ្តល់ព័ត៌មានអំពីសកម្មភាព និងបង្ហាញទីតាំងឲ្យបានច្បាស់លាស់
- ដឹកនាំរាល់ការទទួលខុសត្រូវកម្រិតខ្ពស់
- សហប្រតិបត្តការ និងផ្តល់ព័ត៌មានឲ្យអាជ្ញាធរ និងភាគីពាក់ព័ន្ធ អំពីពេលវេលាសារប្រយោជន៍ និងបែងចែក
- សមាជិកព្រៃសហគមន៍ងាយស្រួល និងមានឱកាសទទួលប្រយោជន៍ពី NTFP
- តម្លាភាពក្នុងការចែករំលែកផលចំណេញ
- សមាជិកសហគមន៍ជាអ្នកកំណត់តំបន់ព្រៃឈើដែលត្រូវការការ

ក្រុម៣ ៖ ក្រុមតំបន់ការពារព្រៃសហគមន៍

យុទ្ធសាស្ត្រគម្រោង

- យោងតាមតំបន់គម្រោងរបស់សហគមន៍ និងតំបន់អភិរក្សសត្វព្រៃ
- ផ្សព្វផ្សាយអំពីគុណប្រយោជន៍នៃព្រៃឈើដល់ប្រជាពលរដ្ឋ
- កំណត់ព្រំប្រទល់ឲ្យច្បាស់លាស់ និងបង្កើតផែនទីសម្រាប់ CPA

រចនាសម្ព័ន្ធ

- ចាត់ចែងក្រុម
- ជ្រើសរើសអនុគណៈកម្មាធិការភូមិ
- ជ្រើសរើសគណៈកម្មាធិការនៅកម្រិតឃុំ
- ចាត់ចែងរៀបចំឯកសារផ្លូវការ ទៅឲ្យក្រសួង ដើម្បីទទួលស្គាល់គណៈកម្មាធិការគ្រប់គ្រងធនធានធម្មជាតិ ជាផ្លូវការ

ថវិការ

- គាំទ្រដោយសហភាពអ៊ឺរ៉ុប និងCDA ព្រមទាំងសហការជាមួយអភិបាលខេត្ត

សហគមន៍ចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ

- មានការយល់ដឹងអំពីច្បាប់ពាក់ព័ន្ធនឹងធនធានធម្មជាតិ
- ស្ម័គ្រចិត្តចូលរួមក្នុងព្រៃ
- ចូលរួមជាមួយប្រធានភូមិ ក្រុមប្រឹក្សាឃុំ និងខេត្ត
- ចូលរួមដោយវិទ្យាស្ថានគូលេនព្រហ្មទេព និងមន្ទីរបរិស្ថានខេត្តផលប្រយោជន៍ និងការបែងចែក
- ផលប្រយោជន៍បានពីNTFPs រួមមាន ៖ ទំពាំងបាយជូគ្រាម ផ្សិត ផ្ដៅ អុស ខ្ទាយ អ៊ូគីដេរ MtangPrie និងពន្លៃ

ប្រសិទ្ធភាព

-ការពារដី៥៩២៩ហិចតា រួមមាន ៖ ដី១១២៥ហិចតា នៅព្រះពន្លៃ (ពីរភូមិ) ដី២៧២៨ហិចតា នៅ ត្រពាំងប្រាសាទ (៥ភូមិ) និងដី២០៧៦ហិចតា នៅអំពិល (៤ភូមិ)។

ផ្សេងៗ

-សំណូមពរឲ្យ CDA ដាក់បង្គោល និងស្លាកសញ្ញាសម្គាល់ ព្រៃសហគមន៍ឲ្យកាន់តែឆាប់
-សំណូមពរឲ្យCDA គាំទ្រដល់សហគមន៍របស់យើង

ក្រុម៤ ៖ ក្រុមខេត្តមណ្ឌលគីរី និងរតនៈគិរី

សហគមន៍ព្រៃឈើ

- ជ្រើសគណៈកម្មាធិការគ្រប់គ្រងព្រៃសហគមន៍
- ដាក់លិខិតផ្លូវការជូនក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដើម្បីអនុម័ត
- ចាត់ចែងបណ្តាញសហគមន៍
- ផ្សព្វផ្សាយ និងដាក់សញ្ញាក្នុងព្រៃ
- ចេញល្បាតព្រៃជាប្រចាំ
- ដាក់បង្គោលជាំវិញព្រៃសហគមន៍
- រាយការណ៍ជូនមន្ត្រីរដ្ឋបាលព្រៃឈើ និងWCS
- សិក្សាបន្ថែមទៀតអំពីផលប៉ះពាល់
- ជួយប្រជុំជាប្រចាំ ដើម្បីឆ្លុះបញ្ចាំងអំពីលទ្ធផលនៃការចុះល្បាតព្រៃ
- សហការជាមួយអាជ្ញាធរ
- តាមដាន និងវាយតម្លៃ

រចនាសម្ព័ន្ធគ្រប់គ្រងព្រៃសហគមន៍

១. ប្រធាន
២. អនុប្រធាន
៣. លេខាធិការ (ប្រុស)
៤. គណនេយ្យ (ស្រ្តី)
៥. សមាជិក
៦. សហគមន៍

សហគមន៍គាំទ្រដោយអង្គការរួមមាន ៖

- សម្ភារៈរួមមាន (អង្រឹង មុង អាវភ្លៀង .......)
- អាហារធម្មតា
- ថ្នាំពេទ្យ និងដឹងជញ្ជូន
- កិច្ចប្រជុំ

សហគមន៍ចូលរួមក្នុងការគ្រប់គ្រងព្រៃឈើ និងធនធានធម្មជាតិ

- ចូលរួមក្នុងសកម្មភាពតស៊ូមតិ
- ចូលរួមក្នុងការបង្កើតគណៈកម្មាធិការគ្រប់គ្រងព្រៃសហគមន៍
- ចូលរួមក្នុងការអនុវត្តសកម្មភាពទាំងអស់របស់ព្រៃសហគមន៍( ជាំបង្គោល និងហាមឃាត់ការកាប់ឈើខុសច្បាប់ )
- ចូលរួមវិភាគទានពេលវេលា ក្នុងសហគមន៍ និងគណៈកម្មាធិការសហគមន៍
- ចូលរួមវិភាគទានជាថវិកា

ផលប្រយោជន៍ និងការបែងចែក

- និរន្តរភាពព្រៃឈើ
- គាំទ្រ និងជួយដល់សហគមន៍តាមតម្រូវការ ដូចជាឈើ និងNTFPs
- ចែករំលែកបទពិសោធល្អៗ អំពីការគ្រប់គ្រងព្រៃឈើ ដល់សហគមន៍ផ្សេងៗ

ប្រសិទ្ធភាព

- មិនទាន់ល្អ ឬកំពុងដំណើរការ ក្នុងការបង្កើតសហគមន៍ព្រៃឈើ
- ការគាំទ្ររបស់អាជ្ញាធរមូលដ្ឋានដល់សហគមន៍ព្រៃឈើមានតិចតួច

ក្រុម៥ ៖ ក្រុមពិភាក្សាអំពីខេត្តកំពង់ធំ និងព្រះវិហារ

តំបន់ការពារសហគមន៍ ( CPA )

ជនបង្គោលត្រូវបានជ្រើសរើសដោយអង្គការ IRAM និងICSO នៅថ្នាក់ភូមិ

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការបង្កើតតំបន់ការពារសហគមន៍
- ការពារព្រៃ និងធនធានធម្មជាតិ
- ជ្រើសរើសអ្នកស្មគ្រចិត្តឲ្យផ្តល់សេវាដល់សហគមន៍ក្នុងការសម្របសម្រួលរកឯកសារពាក់ព័ន្ធ សម្រាប់ផ្តល់ទៅឲ្យភាគីពាក់ព័ន្ធ
- កំណត់ទីតាំងភូមិសាស្ត្រ និងព្រាងផែនទី
- ជួបប្រជុំជាមួយប្រជាពលរដ្ឋ និងរកស្នាមមេដៃប្រជាពលរដ្ឋក្នុងភូមិ ដើម្បីដាក់សំណើទៅក្រសួងបរិស្ថាន ដើម្បីបង្កើតតំបន់ការពារសហគមន៍
- ក្រសួងបរិស្ថានវាយតម្លៃស្ថានភាពនៃតំបន់ព្រៃ និងពិគ្រោះយោបល់។

រចនាសម្ព័ន្ធ

ជ្រើសរើសប្រធានក្រុម អនុប្រធាន ទីប្រឹក្សា អ្នកសម្របសម្រួលត្រូវទទួលស្គាល់ដោយ ប្រធានក្រុមប្រឹក្សាឃុំ និងក្រសួងបរិស្ថាន ហើយអង្គការ ICSO ជាអ្នកផ្តល់ការ បណ្តុះបណ្តាល។

ថវិកា

រួមចំណែកវិភាគទានដោយសហគមន៍ និងICSO (ផ្សព្វផ្សាយ ពិគ្រោះយោបល់ បណ្តុះបណ្តាល និងរួមចំណែកពេលវេលា ផលប្រយោជន៍ និងការបែងចែក

- មានសិទ្ធិរៀបចំផ្ទះសម្បែង និងសង់ផ្ទះ ឲ្យស្របតាមច្បាប់របស់សហគមន៍
- ប្រសិទ្ធភាពក្នុងការការពារ និងរកដំណោះស្រាយ
- ការទប់ស្កាត់ការកាប់ឈើខុសច្បាប់ប្រកបដោយប្រសិទ្ធភាពរបស់សហគមន៍ ត្រូវទទួលស្គាល់ដោយច្បាប់ និងមានការចូលរួមពីសំណាក់អាជ្ញាមូលដ្ឋាន ក្រសួងបរិស្ថាន និងសហគមន៍
- មានជម្លោះជាច្រើន ត្រូវបានដោះស្រាយ ប្រសិនបើគណៈកម្មាធិការមិនដោះស្រាយបញ្ហានោះបានទេ ដាក់សំណើទៅក្រសួងបរិស្ថានដោះស្រាយ

ថ្ងៃទី៣ (១៣ តុលា ឆ្នាំ២០១១)

## កំណត់យុទ្ធសាស្ត្រ

លោកឈី បូរ៉េត បានបូកសរុបសង្ខេបលទ្ធផលសិក្ខាសាលាថ្ងៃទី២ ចែករំលែកបទពិសោធន៍ ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ។ ក្រោយពីលោក ហ៊ាន ប៊ុនធៀង មកពីវេទិកាអង្គការមិនមែនរដ្ឋាភិបាល បានង្ហាញអំពីបច្ចុប្បន្នភាពពាក់ព័ន្ធនឹងរ៉េដ និងធនធានធម្មជាតិ។ លើសពីនេះទៀត លោកបូរ៉េតក៏បានង្ហាញអំពីព្រៃសហគមន៍ និងរ៉េដ។ ហើយក្រោពីលោកបានបង្ហាញ គាត់បានចែកសិក្ខាកាមជាក្រុមតូចៗចំនួនពីរៈ

1. ខេត្តមណ្ឌលគីរី រតនៈគីរី ព្រះវិហារ និងកំពង់ធំ
2. ក្រុមរ៉េដ ក្នុងខេត្តឧត្តរមានជ័យ

ដោយអនុវត្តតាមសំណួរណែនាំដូចខាងក្រោម ៖

ក្រុមពិភាក្សាអំពីសំណួរយុទ្ធសាស្ត្រ

- តើសហគមន៍អាចធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហាសមូហភាពឲ្យបានពេញលេញ បញ្ហាដីធ្លី ព្រៃឈើ និងធនធានធម្មជាតិ? (ស្វែងរកសកម្មភាពទាំងថ្នក់ជាតិ និងថ្នាក់ជាតិ)

- តើអ្នកណាអាចមានលទ្ធភាពជួយសហគមន៍ ក្នុងការដោះស្រាយបញ្ហារួមខាងលើឲ្យបានពេញលេញ? ស្វែងរកអ្នកសកម្មពាក់ព័ន្ធ ក្នុងការជួយដោះស្រាយបញ្ហាបានដូចជារដ្ឋបាលព្រៃឈើ CDA អង្គការមិនមែនរដ្ឋាភិបាល ព្រះសង្ឃ .............។ល។
- តើអ្នកណាអាចជួយរារាំង ឬទប់ស្កាត់អ្នក? (សហគមន៍)
- តើផែនការលើរបាំងរារាំងត្រូវធ្វើយ៉ាងដូចម្តេច?

ក្រុម ៖ ខេត្តមណ្ឌលគីរី រតនៈគីរី ព្រះវិហារ និងកំពង់ធំ

១. យុទ្ធសាស្ត្រ

- ត្រូវមានប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានចូលរួម
- ត្រូវមានរចនាសម្ព័ន្ធគ្រប់គ្រង
- ត្រូវមានការទទួលស្គាល់ដោយស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល
- ត្រូវដាក់បង្គោលព្រំ ដោយមានការឯកភាពជាមួយភាគីពាក់ព័ន្ធ ជុំវិញព្រំប្រទល់ ព្រៃសហគមន៍ /CPA
- ផ្សព្វផ្សាយអំពីផលប្រយោជន៍ និងគោលការណ៍ណែនាំអំពីព្រៃសហគមន៍ត្រូវមានសហគមន៍ចូលរួមក្នុងការសម្រេចចិត្ត

រចនាសម្ព័ន្ធ




ផលប្រយោជន៍ និងការបែងចែក

- ត្រូវមានបទបញ្ញា និងច្បាប់
- ត្រូវអនុវត្តគោលនយោបាយឲ្យបានសកម្ម តាមការកំណត់
- ត្រូវចូលរួមក្នុងដំណើរការចែករំលែកផលប្រយោជន៍

តំណាងសហគមន៍

- ប្រព័ន្ធបោះឆ្នោតបានទទួលការគាំទ្រដោយប្រជាពលរដ្ឋ
- ជ្រើសរើសតំណាងដែលមានសមត្ថភាព និងអាចជួយរួមចំណែក

ព័ត៌មាន

- តើត្រូវបង្កើតសហគមន៍ព្រៃឈើដូចម្តេច?
- ស្គាល់ពីពេលវេលាក្នុងការចាត់ចែងព្រៃសហគមន៍
- តើមានស្ថាប័នប៉ុន្មានចូលរួមក្នុងដំណើរការព្រៃសហគមន៍?
- ស្គាល់ពំពីសិទ្ធិ
- កំណត់ស្លាកសញ្ញាសម្គាល់ព្រំប្រទល់
- ស្គាល់អំពីសារប្រយោជន៍នៃការចាត់ចែង និងគ្រប់គ្រងព្រៃសហគមន៍

ឱកាស និងការពង្រឹង

- គាំទ្រដោយសហគមន៍ អង្គការសង្គមស៊ីវិល រដ្ឋបាលព្រៃឈើ ក្រសួងបរិស្ថាន និងរដ្ឋអំណាចមូលដ្ឋាន
- ចែករំលែក និងផ្សព្វផ្សាយព័ត៌មានដល់គ្នាទៅវិញទៅមក

ក្រុមរ៉េដ : បណ្តាញសហគមន៍ព្រៃឈើ នៅថ្នាក់ខេត្ត នៅឧត្តរមានជ័យ



ផលប្រយោជន៍ និងការបែងចែក

- ការពិគ្រោះយោបល់នៅតាមសហគមន៍
- ជួបជាមួយsub-CFMC នៅថ្នាក់ភូមិចូលរួម
- ថ្នាក់ជាតិត្រូវអញ្ជើញតំណាងសហគមន៍ព្រៃឈើក្នុងការពិគ្រោះយោបល់ ដោយអញ្ជើញតាម រយៈអង្គការ
- CFMC បានពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន
- ថ្នាក់ជាតិត្រូវបង្កបរិយាកាសផ្តល់សិទ្ធិឲ្យតំណាងសហគមន៍ព្រៃឈើចូលរួមបញ្ចេញមតិ មិនត្រូវជំទាស់ មិនផ្តល់ឱកាសទេ
- កិច្ចប្រជុំពិគ្រោះយោបល់ និងឯកសារគួរជាភាសាខ្មែរ មិនគួរភាសាបរទេស
- គួរចែករបៀបវារៈ និងឯកសារពាក់ព័ន្ធនឹងសហគមន៍ យ៉ាងហោចណាស់ ៥ថ្ងៃមុនកិច្ចប្រជុំ

ដើម្បីធានាឲ្យមានតំណាងចូលរួមក្នុងផែនការយុទ្ធសាស្រ្តរ៉េដថ្នាក់ជាតិឆ្នាំ២០១៤

- តំណាងគួរជ្រើសរើសចេញពីសហគមន៍
- មានសមត្ថភាព និងស្មោះត្រង់
- លះបង់ពេលវេលាផ្ទាល់ខ្លួន ដើម្បីប្រយោជន៍រួម
- តំណាងត្រូវមានការទទួលខុសត្រូវខ្ពស់ និង
- ផ្សព្វផ្សាយព័ត៌មានដល់CFMC និងសមាជិកព្រៃសហគមន៍ អំពីលទ្ធផលនៃកិច្ចប្រជុំ

ព័ត៌មាន

- រូបភាពត្រូវច្បាស់ ដោយសរសេរជាភាសាខ្មែរ និងដាក់រូបភាពក្នុងឯកសារ
- ចែករំលែកផលប្រយោជន៍ដល់សហគមន៍ដោយផ្ទាល់
- ធ្វើយ៉ាងណាឲ្យសហគមន៍ និងអ្នកចូលរួមទុកចិត្ត និងចូលរួមពេញលេញ
- ផ្សព្វផ្សាយព័ត៌មានឲ្យបានទូលំទូលាយដល់អាជ្ញាធរមូលដ្ឋាន
- ចាត់ចែងបណ្តាញ និងចែករំលែកព័ត៌មានគ្នាទៅវិញទៅមក ប្រកបដោយ តម្លាភាព

## អនុសាសន៍

គួរទទួលបានការគាំទ្រក្នុងការចែករំលែកព័ត៌មាននៅថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ន អាជ្ញាធរមូលដ្ឋាន និងផ្សព្វផ្សាយព័ត៌មានដល់សហគមន៍។

# កំពង់ធំ



# កំពង់ធំ

សិក្ខាសាលាអប់រំផ្សព្វផ្សាយលើកទីពីរ ត្រូវបានរៀបចំឡើងក្នុងខេត្តខេត្តកំពង់ធំ មាន រយៈពេល០២ថ្ងៃគឺចាប់ពីថ្ងៃទី ១៦-១៧ ខែកុម្ភៈ ឆ្នាំ ២០១២នៅ បរិវេណសណ្ឋាគារអារុណរះ ។ មានអ្នកចូលរួមសរុបចំនួន ៧១នាក់ក្នុងនោះស្រីចំនួន១៨នាក់ ដែលជាតំណាងមកពី៖

- Community Forestry and Protected Areas
- Indigenous Rights Active Members
- Community Forestry committees
- អង្គការដៃគូររួមមាន
- ម្លប់បៃតង
- BFDK
- RECOFTC (Center for People and Forests)
- EHE
- NGO Forum on Cambodia
- IDEA
- EWMI
- AEC
- AFD
- CPN
- បុគ្គលិកមកពីមន្ទីរបរិស្ថាន និងខណ្ឌ រដ្ឋបាលព្រៃឈើខេត្តកំពង់ធំ

## ប្រធានបទសំខាន់ៗ

កម្មវិធីនៅក្នុងសិក្ខាសាលាអប់រំផ្សព្វផ្សាយក្នុងខេត្តកំពង់ធំនេះ រួមមាន៖

1.ខ្សែភាពយន្តឯកសារស្តីពីការប្រែប្រួលអាកាសធាតុ និងបទពិសោធន៍ដែលទាក់ទងទៅនឹងគម្រោង រេដបូក ក្នុងខេត្តឧត្តមានជ័យ
2.បទបង្ហាញស្តីពី ទំនោរនៃវិស័យព្រៃឈើ និងនិន្នាការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា។ រេដបូកការប្រែប្រួលអាកាសធាតុ និងជនជាតិដើមភាគតិច និងការព្រួយបារម្ភរបស់ពួកគេ។ផែនទីបង្ហាញផ្លូវរេដបូកនៅកម្ពុជា និងការរួមបញ្ចូលតួនាទីសង្គមស៊ីវិលទៅក្នុងការអភិវឌ្ឍន៍ផែនទីបង្ហាញផ្លូវរេដបូក

## កិច្ចពិភាក្សា និង លទ្ធផលសិក្ខាសាលា

ថ្ងៃទី១៖ ១៦ កុម្ភៈ ឆ្នាំ២០១២

ចំណាប់អារម្មណ៍របស់លោក អ៊ុន យិត នាយរងខណ្ឌរដ្ឋបាលព្រៃឈើខេត្តកំពង់ធំៈ

ការគំរាមកំហែងដែលបណ្តាលមកពីបំរែបំរួលអាកាសធាតុគឺមានលក្ខណៈជាសកលដែលបង្ករអោយកើតមានឡើងនូវខ្យល់ព្យុះ ទឹកជំនន់ និង ការរអិលបាក់ដី ហើយទាំងនេះគឺបណ្តាលមកពីការបាត់បង់ព្រៃឈើ។

លោកបានបន្ថែមទៀតថាប្រទេសកម្ពុជាជាប្រទេសសំបូរព្រៃឈើមានជាង១៣លានហិកតា រឺប្រមាណជា៧៣ភាគរយដោយឡែកនៅកំពង់ធំមានប្រមាណជា៦៤៣ពាន់ហិកតាប៉ុណ្ណោះ។ ការប្រែប្រួលនៅអំឡុងឆ្នាំ២០០០ មកពីតំលៃដីឡើងថ្លៃ ដែលជំរុញអោយមានការកាប់ឈើ ការរានដីសំរាប់កសិកម្មមានដំឡូងមី និង ចំការកៅស៊ូជាដើមហើយកំណើននៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចគឺមានកំណើនយ៉ាងខ្លាំង ហើយក្នុងនោះក៏មានការកាប់ពីប្រជារដ្ឋមកពីខេត្តនានាផងដែរ ហើយពួកគាត់មិនបានប្រើប្រាស់ដីនោះទេពេលមានអ្នកមានលុយទិញគាត់ក៏លក់ ហើយបន្តទៅកាប់កន្លែងផ្សេងទៀត។

ទាក់ទងនឹងការរៀបចំសិក្ខាសាលាថ្ងៃនេះនឹងផ្ញើរនូវសារដ៏មានសារៈសំខាន់ណាស់ ស្តីអំពីផលប៉ះពាល់នៃការបាត់បង់ព្រៃឈើ។ ម្យ៉ាងវិញទៀតសិក្ខាសាលានេះមានគោលបំណងលើកទឹកចិត្ត និងជំរុញការថែរក្សាព្រៃឈើ ដើម្បីស្តារស្ថានភាពគំរបព្រៃឈើយើងឡើងវិញនិងឈានទៅលក់កាបូនឥណទានផងដែរ។

មតិចំណាប់អារម្មណ៍របស់លោកលី កាណារ៉ា អនុប្រធានមន្ទីរបរិស្ថានខេត្តកំពង់ធំៈ

សិក្ខាសាលាថ្ងៃនេះគឺជាប្រធានបទដ៏សំខាន់ដែលបានគូសបញ្ជាក់អំពីផលប៉ះពាល់ដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាពល។ ការកាប់ព្រៃឈើធ្វើផ្ទះ ធ្វើចំការ និងសាងសង់ហេដ្ឋារចនាសម្ពន្ធ័ក៏ជាមូលហេតុនៃការប្រែប្រួលអាកាសធាតុផងដែរ ហើយទង្វើរទាំងនេះសុទ្ធសឹងតែមានការប៉ះពាល់ដល់ជំរើសជីវភាពរបស់ប្រជាជន។រាជរដ្ឋាភិបាលបានសម្បទានដីសេដ្ឋកិច្ចដាំកៅស៊ូ ពេលដែលកំពុងឈូសឆាយវានឹងបាត់បង់គំរបព្រៃឈើ ពី៤ ទៅ៦ឆ្នាំទើបចំការកៅស៊ូអាចនឹងក្លាយទៅជាគំរបព្រៃឈើ ដូច្នេះដើម្បីងាយស្រួលយើងត្រូវកំណត់ព្រំប្រទល់បានច្បាស់។ សព្វថ្ងៃនៅខេត្តកំពង់ធំមានការបង្កើតសហគមន៍ព្រៃឈើបានជាច្រើនហើយប្រទេសអ្នកមានគេកំពុងបរិច្ចាគធនធានទិញកាបូនពីប្រទេសកម្ពុជា ដូច្នេះហើយទើបរដ្ឋាភិបាលខិតខំស្តារព្រៃឈើដើម្បីបង្កើនគំរបព្រៃឈើឡើងវិញ ដូចជាចំការឈើដាំជាដើមព្រោះចំការឈើដាំក៏ជួយស្រូបឥណទានកាបូនផងដែរមានដូចជាចំការដូងប្រេង។

នៅក្នុងខេត្តកំពង់ធំមានអង្គការមួយចំនួនបានធ្វើកិច្ចសហការយ៉ាងជិតស្និតជាមួយមន្ទីរពាក់ព័ន្ធ ហើយបង្កើតសហគមន៍ព្រៃឈើបន្ថែមនៅឃុំតាគ្រាមផងដែរ តំបន់នេះមានសក្តានុពលនៃព្រៃឈើគឺមានទាំងក្នុងបឹងទន្លេសាបផងដែរ ដូច្នេះយើងត្រូវចូលរួមគ្នាអនុវត្តច្បាប់ទាំងអស់គ្នាទៅតាមវិស័យនីមួយៗ។

មតិចំណាប់អារម្មណ៍របស់លោក ជី បូរ៉េដ នាយកប្រតិបត្តិសមាគមន៍កុមារៈ

ទិសដៅរ៉េដដែលយើងកំពុងអនុវត្តនេះ គឺទទួលបាននូវការយកចិត្តទុកដាក់និងទទួលជ្រាបទូទាំងពិភពលោក។ ហើយរាជរដ្ឋាភិបាលបានទទួលយកនូវគោលការណ៍ស្តីពីរ៉េដនេះ ហើយបានកំណត់តំបន់សាកល្បងកម្មវិធីរ៉េដនៅឧត្តរមានជ័យ និងកែវសីម៉ា។ ហើយUN-REDD និងរដ្ឋបាលព្រៃឈើបានធ្វើការចងក្រងឯកសារផែនទីបង្ហាញផ្លូវរ៉េដផងដែរ។ ការធ្វើកម្មវិធីរ៉េដគឺត្រូវគិតពីការបាត់បង់ព្រៃដូចជាតាមរយៈដីសម្បទានសេដ្ឋកិច្ចជាដើម ។ ល ។

មានមតិមួយចំនួនលើកថាជនជាតិដើមភាគតិចជាអ្នកបំផ្លាញព្រៃ ផ្ទុយទៅវិញ ជនជាតិដើមភាគតិចដើរតួនាទីយ៉ាងសំខាន់ក្នុងការពារព្រៃព្រោះជនជាតិដើមភាគតិចធ្វើចំការវិលជុំ។ តាមការសិក្សា កន្លងមកកម្មវិធីរ៉េដគេមិនបានរាប់បញ្ចូលចំការដូងប្រេង និងចំការកៅស៊ូទេ ហើយនៅប្រទេសខ្លះមានក្រុមហ៊ុនសម្បទានកាបូនដូចជានៅវៀតណាម គឺរដ្ឋាភិបាលបានផ្តល់សម្បទាន ឲ្យក្រុមហ៊ុនហើយក្រុមហ៊ុន ជាអ្នកគ្រប់គ្រងព្រៃនោះ។ ក៏ប៉ុន្តែការធ្វើបែបនេះបណ្តាលសហគមន៍ជនជាតិដើមភាគតិចបានបាត់បង់សិទ្ធិក្នុងការប្រើប្រាស់ព្រៃឈើ។ ឆ្លើយតបទៅនិងហេតុផលនេះ UN និង World Bank បានផ្តល់មូលនិធិសំរាប់ ការរៀបចំឯកសាររ៉េដ ហើយដែលតម្រូវឲ្យមានការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល។

មតិសំណេះសំណាល និងបើកកម្មវិធី របស់លោកស្រី យស ថានារី អភិបាលរងខេត្តកំពង់ធំ ៖

ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះអ្នកចូលរួមក្នុងសិក្ខាសាលានេះ ដែលជាកម្មវិធីដ៏មានសារៈប្រយោជន៍ដល់ការកាត់បន្ថយឧស្ម័ននានា។ កាលពីព្រៃឈើមិនទាន់រិចរិលគឺមិនទាន់មានការរីកចំរើន និង ជឿនលឿន តែដល់កាប់ព្រៃឈើអស់មានការជឿនលឿន។ សព្វថ្ងៃមិនដឹងប្រាំង មិនដឹងវស្សា ពីដើមមកមិនដែលជីកអណ្តូងតាមស្រែទេ តែឥឡូវមានជីក មានការចោលកាកសំណល់(ថង់ផ្លាស្ទិក)បំពុលបរិស្ថាន។ បើយើងមើលពីមុនយើងប្រើប្រាស់ស្លឹកឈើ ស្លឹកចេកខ្ចប់អាហារហើយមិនមានបន្សល់សារធាតុពុល។ ដូច្នេះដើម្បីដោះស្រាយបញ្ហានេះគឺត្រូវធ្វើដូចម្តេច? គឺតាមរយៈការចូលរួមសិក្ខាសាលាដើម្បីផ្លាស់ប្តូរបទពិសោធន៍ ជាពិសេសការផ្តល់ចំណេះដឹងពីអង្គការដែលមានបទពិសោធន៍ខាងកម្មវិធីរ៉េដ។ មានឯកសារមួយបង្ហាញថាស្ត្រីស្លាប់ចន្លោះអាយុ៥០ទៅ៥៥ឆ្នាំ ចំណែកឯបុរសវិញអាចស្លាប់ក្នុងអំឡុងអាយុពី៥៥ទៅ៦០ឆ្នាំ នេះបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដែលពីមុនប្រទេសខ្លះប្រជាជនអាចមានអាយុរហូតដល់១២០ឆ្នាំ។

ខ្ញុំសូមថ្លែងអំណរគុណដល់អង្គការរ៉េដដែលបានផ្តួចផ្តើមសិក្ខាសាលានេះ និងសូមជូនពរដល់ និងសិក្ខាកាមដែលបានចូលរួម និងសូមប្រកាសបើកកម្មវិធីសិក្ខាសាលាសំរាប់រយៈពេល២ថ្ងៃ។

## បទបង្ហាញ និងការពិភាក្សា

លោក ហ៊ាន ប៊ុនហៀង មកពីអង្គការ NGO Forum ធ្វើបទបង្ហាញពីការប្រែប្រួលអាកាសធាតុដោយការបង្ហាញខ្សែភាពយន្តឯកសារ ជាមួយនិងការពិភាក្សាជុំវិញទស្សនៈទាន និងពាក្យគន្លឹះដែលពាក់ព័ន្ធ ដូចជាឥទ្ធិពលនៃឧស្មន័ផ្ទះកញ្ចក់។

លោកគីម ហុង (EWMI) ធ្វើបទបង្ហាញពីនិន្នាការអភិវឌ្ឍន៍ និងវិស័យព្រៃឈើនៅប្រទេសកម្ពុជាៈ លោកបានពន្យល់ពីមូលហេតុដែលធ្វើឲ្យមានការប្រែប្រួលអាកាសធាតុគឺបណ្តាលមកពីការបញ្ចេញឧស្ម័នកាបូនិក តាមរយៈឧស្សាហកម្មនានា។ សំរាប់ប្រទេសកម្ពុជា យើងក៏បានចូលរួមចំណែកតិចតួចដែរក្នុងការបំភាយឧស្ម័នផ្ទះកញ្ចក់លើពិភពលោក។ ចំពោះគំរបព្រៃឈើនៅប្រទេសកម្ពុជាគឺដូចអ្វីដែលរដ្ឋបាលព្រៃឈើមានប្រសាសន៍គឺមានទំហំធំណាស់ តែបើយើងមើលលើផែនទីនេះគឺមានការប្រែប្រួលពីមួយឆ្នាំទៅឆ្នាំ នៅឆ្នាំ២០០៥ ឬ២០០៦ រដ្ឋាភិបាលបានលុបបំបាត់ព្រៃសម្បទានតែបង្វែមកជាដីសម្បទានសេដ្ឋកិច្ច និងសម្បទានរ៉ែ វារីអគ្គិសនី។

លោកស្រីអភិបាលរងស្រុកកំពង់ស្វាយក៏បានឡើងធ្វើចំណាប់អារម្មណ៍ថាកម្មវិធីរ៉េដមានសារៈសំខាន់ និងគុណតំលៃជាច្រើន ដែលអាចនឹងយកទៅផ្សព្វផ្សាយដល់មន្ត្រីភូមិ ឃុំ។ លោកស្រីបានបន្ថែមទៀតថា ទោះបីស្រុកកំពង់ស្វាយមិនសូវមានព្រៃក៍ពិតមែនក៏អាជ្ញាធរស្រុកនៅតែខិតខំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យយល់ដឹងពីរ៉េដ និងចូលរួមការពារព្រៃ។

បទបង្ហាញពីបទពិសោធន៍ការអនុវត្តន៍កម្មវិធីរ៉េដនៅឧត្តរមានជ័យដោយលោកបូររិទ្ធ័ បានបង្ហាញទស្សនៈទានផ្សាភ្ជាប់គ្នារវាងព្រៃឈើ និងការបំភាយឧស្ម័ន ហើយគោលបំណងរបស់យើងគឺចង់ជំរុញការការពារ និងស្តារនូវគំរបព្រៃឈើ លោកបានបញ្ជាក់ថាមានសហគមន៍១២៣នៅឧត្តរមានជ័យដែលចុះបញ្ជីនៅក្រសួងកសិកម្ម។ ការប្រតិបត្តិគំរោងរ៉េដគឺចាប់ផ្តើមនៅឆ្នាំ២០០៨ ដោយមានស្ថាប័នអនុវត្តន៍ផ្ទាល់គឺរដ្ឋបាលព្រៃឈើ អង្គការដៃគូរគឺ CFI, PACT និងសហគមន៍ព្រៃឈើ។កម្មវិធីនេះផ្តោតសំខាន់គឺការអភិរក្សកាបូនដែលការរំពឹងទុកមានរយៈពេល៣០ឆ្នាំ។ សកម្មភាពស្នូលរួមមាន៖

- កិច្ចព្រមព្រៀង
- ការផ្សព្វផ្សាយ
- ការបណ្តុះបណ្តាល និងអនុវត្តន៍ជាក់ស្តែងនៅទីវាល
- ការអភិវឌ្ឍវិធីសាស្ត្រ
- ការវាស់វែងទីវាល
- ការរៀបចំឯកសារគំរោងដាក់ទៅស្តង់ដារកាបូនស្មគ្រ័ចិត្ត និងសម្ពន័ជីវចំរុះ
- ការបង្កើតនិតិវិធីការអនុវត្តគំរោង
- ការតាមដាន និង រៀបចំសម្រាប់ការពិនិត្យបញ្ជាក់លើកទី១
- ឯកសារស្របច្បាប់ និងការរៀបចំឯកសារពាក់ព័ន្ធ
- កិច្ចព្រមព្រាងទិញកាបូន។

ហើយការដែលអនុវត្តទៅបានគឺលុះត្រាមានការគាំទ្រពីមន្ត្រីជំនាញ (អ្នកបច្ចេកទេស អ្នកធានាអះអាងលំដាប់អន្តរជាតិ រឺអ្នកវាយតំលៃ ដើម)។ ការបកប្រែក៏ត្រូវការអ្នកជំនាញជាពិសេសក្រុមហ៊ុនដែលបានទទួលស្គាល់ ព្រោះថាបើយើងធ្វេសប្រហែសអាចនឹងធ្វើឲ្យគំរោងមិនទទួលបានជោគជ័យ។ ដើម្បីធានាទៅលើតំបន់កាបោន ជាចាំបាច់គឺត្រូវការការធានាចំពោះការការពារព្រៃឈើផងដែរ ព្រោះថាបើមានការកាប់បំផ្លាញព្រៃឈើ តំបន់កាបូន ក៏មិនទិញដែរ។ រាល់៥ឆ្នាំម្តងត្រូវពិនិត្យមើលកិច្ចសន្យាទិញកាបោន។

មូលហេតុសំខាន់ៗនៃការកាប់បំផ្លាញព្រៃឈើក្នុងខេត្តឧត្តរមានជ័យរួមមាន៖

- ក្រុមហ៊ុនសម្បទាន
- ការកាប់រានដីយក
- ភ្លើងឆេះព្រៃ
- ខ្វះបច្ចេកទេសដកហូតអនុផលព្រៃឈើ
- ការប្រើប្រាស់ព្រៃឈើសំរាប់ដោះស្រាយបញ្ហាក្នុងតំបន់
- ការបង្កើតភូមិថ្មីនៅតំបន់ជិតព្រំដែនថៃ។
- អ្នកចំណូលថ្មី និងការមិនយល់ច្បាស់ពីREDD
- ទីផ្សាកាបូនតំលៃទាប។

## សំនួរ និងមតិនានា

សំណួរពីលោកយុត សារី មកពីសហគមន៍ព្រៃឈើស្រុកប្រាសាទបាល្លង្គ័ សុំឲ្យមានឯកសារ នានាវីដេអូផ្សព្វផ្សាយដល់សហគមន៍ព្រោះងាយស្រួលដល់សហគមន៍ក្នុងការផ្សព្វផ្សាយ និងយល់ពីការគំរាមកកំហែង និងយល់ពីតួនាទីរបស់ការបូន។

លោក សនទីន មកពីភូមិកូនត្នោត ស្រុកកំពង់ស្វាយ បានសួរថា ដើម្បីជួយកាត់បន្ថយការបញ្ចេញឧស្ម័ន តើគំរោងរ៉េដមានអ្វីដើម្បីជួយសហគមន៍ព្រៃឈើ? តើសហគមន៍នៅឧត្តរមានជ័យមានវិធីសាស្រ្តអ្វីដើម្បីទប់ស្កាត់បទល្មើសព្រៃឈើ?

ចំលើយ ៖
លោកសាថ្លៃ ប្រធានបណ្តាញព្រៃឈើខេត្តឧត្តរមានជ័យ មុនពេលដែលគំរោងរ៉េដត្រូវបានអនុវត្តក្នុង ខេត្តឧត្តមានជ័យ អជ្ញាធរ នបានជជែក ជាមួយសហគមន៍ព្រៃឈើនោះទេ។ ពេលដែលមានការស្នើសុំឲ្យទទួលស្គាល់សហគមន៍ ពួកគាត់មានការរារែកព្រោះខ្លាចហត្ថលេខា ដែលផ្តល់អោយនោះ បែជាមានន័យថាជាកិច្ចព្រមព្រាង ផ្តល់ដីធ្លីទៅវិញ។ គំរោងនេះត្រូវបានរៀបចំឡើង ដើម្បីកាត់បន្ថយការទន្រ្ទានព្រៃឈើដោយខុសច្បាប់។ ចំពោះបទល្មើសមានការថយចុះខ្លះ តែក្រោយពីមានវិបត្តិព្រំដែនគឺទាហ៊ានបានឈរជើងនៅតំបន់នោះ ហើយបណ្តាលអោយសកម្មភាពកាប់ បំផ្លាញព្រៃមានសំទុះឡើងវិញ។ ចំពោះការការពារព្រៃឈើ គឺសមាជិកសហគមន៍បានពួតដៃគ្នា ដូចជាការដាក់ពាក្យបណ្តឹង ឬទប់ស្កាត់បទល្មើសជាដើម។ការយាមល្បាតគឺចាត់ជាវេណផ្លាស់ប្តូរគ្នា។

ថ្ងៃទី២៖ ១៧ កុម្ភៈ ឆ្នាំ២០១២

បទបង្ហាញពីបទពិសាធន៍ការអនុវត្តគម្រោងរ៉េដ ស្រុកមណ្ឌលសីម៉ា ខេត្តមណ្ឌលគីរីដោយលោក ណក់ វ៉ែន មន្រ្តីអង្គការ NTFP-EP ។

បើនិយាយពីកាបូន គឺយើងសំដៅដល់ការលក់ខ្យល់ ពីព្រោះសហគមន៍នៅក្នុងខេត្តមណ្ឌលគិរី បានកំពុងដំណើរអនុវត្តគម្រោងរ៉េដ។

- ជំហានទីមួយគឺការផ្សព្វផ្សាយពីការយល់ដឹង និង ពង្រាងឯកសារផលប៉ះពាល់ពីគម្រោងរ៉េដ
- ជំហានទី២គឺការពិភាក្សាលើកិច្ចព្រមព្រៀង និង បង្ហាញពីកិច្ចព្រមព្រៀងសហគមន៍
- ជំហានទី៣គឺចុះហត្ថលេខាលើកិច្ចព្រមព្រៀង និងការអនុវត្ត។

តាមរយៈលទ្ធផលនៃការពិគ្រោះយោបល់ សហគមន៍បានសំដែងនូវការព្រួយបារម្ភ របស់ពួកគាត់លើដំណើរការរៀបចំគម្រោងរ៉េដមានដូចជា៖

- នៅពេលអនុវត្តគម្រោងរ៉េដសហគមន៍មិនអាចប្រមូលផល និង អនុផលព្រៃឈើសំរាប់ជីវភាពរស់នៅប្រចាំថ្ងៃ របស់ពួកគាត់
- សហគមន៍មានការយល់ព្រមលើគម្រោងរ៉េដ ដោយមិនបានយល់ដោយពេញលេញ
- កិច្ចព្រមព្រៀងបានធ្វើជាមួយសហគមន៍ តែរាល់ការបែងចែកផលប្រយោជន៍ និង ការគ្រប់គ្រងជាអ្នកចាត់ចែង។

ពួកគាត់ក៏មានការភ័យខ្លាចផងដែរទៅលើ៖

- គំរោងដែលអាចគ្រប់គ្រងដោយក្រុមហ៊ុនឯកជន
- បញ្ហាដីសម្បទាន
- និងការបែងចែកផលប្រយោជន៍ដែលមិនមានតម្លាភាព

បន្ទាប់មកក៏មានសំនួរពីអ្នកចូលរួមដូចជា៖

សំនួរទី១៖ ប្រសិនបើយើងកំពុងអនុវត្តគម្រោងរ៉េដហើយមានប្រជាពលរដ្ឋកំពុងធ្វើដំណាំវិលជុំដែលជាចំការប្រព្រៃណី តើគួរតម្រូវឲ្យពួកគាត់បញ្ឈប់ ឬ អនុវត្តបន្ត?

ចំលើយ ៖
ក្នុងគោលការណ៍អនុវត្តរ៉េដគឺគេមិនអនុញ្ញាត្តអោយបន្តសកម្មភាពទាំងនេះទៀតទេ។ ហេតុដូច្នេះហើយទើប ដីដែលធ្វើកសិកម្មវិលជុំ គឺត្រូវគូសចេញពីតំបន់គំរោងរ៉េដ។

សំនួរទី២៖ តើនៅពេលដែលយើងអនុវត្តកម្មវិធីរ៉េដនៅតំបន់ជនជាតិ ដើមភាគតិច តើវាធ្វើឲ្យបាត់បង់សិទ្ធិជាប្រព្រៃណីរបស់ពួកគាត់ដែលរឺទេ?

ចំលើយ ៖
នៅពេលដែលយើងអនុវត្តគម្រោងនេះ សហគមន៍ដែលជាជនជាតិដើមភាគតិចអាចនឹងបាត់បង់នូវអត្តសញ្ញាណ ព្រៃឈើ នឹងទំនៀមទំលាប់ ដែលរស់នៅពឹងពាក់លើធនធានធម្មជាតិ ព្រមទាំងការធ្វើរបរកសិកម្មពនេចរ។ ហេតុដូច្នេះហើយ ដែលសកម្មភាពនេះគឺ តំរូវឲ្យប្រជាជនចេះធ្វើការតស៊ូមតិ ដើម្បីគាំទ្រសិទ្ធប្រព្រៃឈើ របស់ពួកគាត់។

បទបង្ហាញរបស់ កញ្ញា តេង រិទ្ធីធានី (NGO Forum) ពីដំណើរការអនុវត្តគម្រោងរេ៉ដនៅថ្នាក់ជាតិ

ផែនការអនុវត្តន៍ថ្នាក់ជាតិរួមមានជំហ៊ានដូចខាងក្រោម៖

- ការរៀបចំបង្កើតផែនទីបង្ហាញផ្លូវរេ៉ដ(ឆ្នាំ២០០៩-២០១១)
- ផលិតឯកសារពីរេ៉ដបូក និង ការផ្សព្វផ្សាយ (២០១២-២០១៤)
- អនុវត្តរេ៉ដបូក(២០១៥)

បច្ចុប្បន្នយើងកំពុងដំណើរការដល់ជំហានទី២ គឺការជ្រើសរើសតំណាងសហគមន៍ចូលរួមក្នុង ការពិភាក្សាពិគ្រោះយោបល់លើការរៀបចំផែនការយុទ្ធសាស្រ្តរេ៉ដថ្នាក់ជាតិ។ សិក្ខាសាលាស្តីពីកម្មវិធីរេ៉ដនឹងត្រូវរៀបចំឡើងដើម្បីបន្តដំណើរការជ្រើសរើសនេះ។

មកបំបែកក្រុមពិភាក្សាជា៥ក្រុម ដោយពិភាក្សាទៅលើសំនួរ៣ដូចខាងក្រោម៖

- តើអ្នកគិតថាសហគមន៍មូលដ្ឋាន អាចចូលរួមក្នុងដំណើរការពិគ្រោះយោបល់ និង ការអនុវត្តរេ៉ដនៅកម្ពុជាយ៉ាងដូចម្តេច?
- តើអ្នកត្រូវការពត៌មានជាក់លាក់អ្វីខ្លះអំពីកម្មវិធីរេ៉ដដែលសហគមន៍ត្រូវការ?
- តើអ្នកមានការព្រួយបារម្ភ មានអនុសាសន៍ និង សំណូមពរទាក់ទងនឹងកម្មវិធីរេ៉ដបូកនៅកម្ពុជារឺទេ?

សំយោគលទ្ធផលពិភាក្សាតាមក្រុម

១) សហគមន៍ត្រូវចូលរួមក្នុងដំណើរការពិគ្រោះយោបល់ ពីថ្នាក់មូលដ្ឋានដល់ថ្នាក់ជាតិ ហើយត្រូវយក យោបល់សហគមន៍ដាក់ចូលក្នុងកម្មវិធីរេ៉ដ

- ត្រូវអនុវត្តជាមួយសហគមន៍ឲ្យសហគមន៍ធ្វើជាម្ចាស់គម្រោង
- ឲ្យសហគមន៍ចូលរួមពិគ្រោះយោបល់ជាប្រចាំ និងគ្រប់ជំហានជាមួយអ្នកពាក់ពន្ធ័
- ផលប្រយោជន៍ត្រូវឲ្យជាអតិបរិមាដល់សហគមន៍
- ផ្សព្វផ្សាយពីកម្មវិធីរេ៉ដដល់សមាជិកសហគមន៍

- ជ្រើសរើសអ្នកតំណាងទៅចូលរួមក្នុងកិច្ចប្រជុំពិភាក្សាពីថ្នាក់ភូមិ ឃុំ ស្រុក និង ថ្នាក់ខេត្ត ថ្នាក់ជាតិ។ ជ្រើសរើស តំណាងដែលមានស្រាប់ក្នុងសហគមន៍
- មុននឹងធ្វើសេចក្តីសំរេចចិត្តអ្វីមួយត្រូវពិគ្រោះយោបល់ជាមួយសហគមន៍
- សហគមន៍មានសិទ្ធិក្នុងការសំរេចចិត្តក្នុងការអនុវត្ត និង ការទទួលយកគម្រោងរ៉េដបូក
- សហគមន៍មូលដ្ឋានមានសិទ្ធិបញ្ជូនតំណាងរបស់ខ្លួនចូលរួមក្នុងការពិគ្រោះយោបល់នៅថ្នាក់ ជាតិពី៥-១០នាក់។
- សហការជាមួយមន្ត្រីពាក់ពន្ធ័ និង អាជ្ញាធរមូលដ្ឋានដោយធ្វើការពិគ្រោះយោបល់ជាមួយសហគមន៍ចាប់ពីថ្នាក់ភូមិ រហូតដល់ថ្នាក់ខេត្ត។
- ផ្តល់ឯកសារកម្មវិធីរ៉េដជាភាសាខ្មែរដល់សហគមន៍មូលដ្ឋាន

២ ) ពត៌មានដែលសហគមន៍ត្រូវការ៖

- គោលនយោបាយកម្មវិធីរ៉េដថ្នាក់ជាតិមកដល់មូលដ្ឋានដូចជាដីធ្លី ព្រៃឈើ សត្វព្រៃ និងថវិកា
- វគ្គបណ្តុះបណ្តាលនឹងផ្សព្វផ្សាយដល់សហគមន៍ដែលពាក់ពន្ធ័ទៅក្នុងកម្មវិធីរ៉េដ
- ជួយផ្តល់ផែនទីពិតប្រាកដពីគម្រោងរ៉េដបូកដល់ដៃសហគមន៍
- ត្រូវការដឹងពីគោលនយោបាយស្តីពីកម្មវិធីរ៉េដបូក
- ពត៌មានលំអិតពីកម្មវិធីរ៉េដបូកត្រូវសរសេរជាភាសារខ្មែរ ហើយការនិយាយក៏ត្រូវនិយាយជា ភាសារ ខ្មែរដែររួមជាមួយភាសាជនជាតិដើមភាគតិច។
- ពត៌មានទាំងឡាយត្រូវបញ្ជូនមកសហគមន៍ជាមុនសិន
- ពត៌មានពីរ៉េដត្រូវផលិតជាវីដេអូ ឬ រូបភាពដើម្បីផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋាន
- បណ្តុះបណ្តាលបច្ចេកទេសដល់គណៈកម្មការ និងតំណាងក្រុម
- ដំណើរការរៀបចំក្នុងកម្មវីធីរ៉េដ ផលប្រយោជន៍របស់កម្មវធីរ៉េដ
- គោលការណ៍ណែនាំ និង បទបញ្ញាត្តិអំពីគម្រោងរ៉េដ
- ព័ត៌មានស្តីពីផលប៉ះពាល់ពីការអនុវត្តគម្រោងរ៉េដ
- ត្រូវផ្តល់ពត៌មានជាក់លាក់ពីតួនាទីរបស់សហគមន៍ក្នុងការចូលរួមកម្មវិធីរ៉េដ

៣ ) តើលោកអ្នកមានការព្រួយបារម្ភ, សំណូមពរ និងអនុសាសន៍អ្វីខ្លះ ?

- ការព្រួយបារម្ភ៖
  - បើធ្វើរ៉េដត្រូវគិតគូរដោះស្រាយបញ្ហាព្រៃឈើជាធំ ហើយគំរោងគួរតែផ្តោតការយកចិត្តទុកដាក់ លើបញ្ហានេះ
  - បើធ្វើរ៉េដគ្មានការពិគ្រោះយោបល់ពីប្រជាពរដ្ឋ នឹងជួបនូវបញ្ហាជីវភាពរស់នៅរបស់សហគមន៍ ដូចជាទំនៀមទំលាប់ប្រពៃណីជាពិសេសជនជាតិដើមភាគតិច។
  - ការបែកបាក់សាមគ្គីតាមរយៈបែងចែកផលប្រយោជន៍មិនមានតម្លាភាព
  - សហគមន៍យល់មិនច្បាស់អំពីកម្មវិធីរ៉េដ
  - ខ្លាចមានភ្លើងឆេះព្រៃ, ខ្លាចមានបទល្មើសកើតឡើង

- ប្រជាជនមិនអាចធ្វើកសិកម្មពនេចរបាន
- ប្រជាពលរដ្ឋមិនអាចដកហូតអនុផលព្រៃឈើបាន
- បាត់បង់មុខរបររបស់ប្រជាពលរដ្ឋ
- បាត់បង់ដីស្រែចំការដែលនៅក្នុងគម្រោងរ៉េដ
- បាត់បង់ការរកផល និង អនុផលព្រៃឈើតាមប្រពៃណី
- ថវិកា មិនធ្លាក់ដល់ក្រុមសហគមន៍
- ពិបាកការពារទប់ស្កាត់បទល្មើសផ្សេងៗ
- ខ្លាចរដ្ឋាភិបាលប្រគល់ដីសម្បទានឲ្យក្រុមហ៊ុន
- ខ្លាចរដ្ឋាភិបាលធ្វើសម្បទានគម្រោងរ៉េដបូកឲ្យទៅក្រុមហ៊ុនឯកជន
- ការអនុវត្តដីសម្បទានសេដ្ឋកិច្ចធ្វើឲ្យបាត់បង់ព្រៃឈើ និង ជីវៈចំរុះ ដែលនាំឲ្យមានការថ្លាយ កាបូន។
-សហគមន៍មូលដ្ឋានមិនអាចរកផល និង អនុផលព្រៃឈើជាលក្ខណៈគ្រួសារ ព្រមជាមួយ ប្រពៃណីជនជាតិដើមភាគតិច។
- ថវិកាដែលទទួលបានពីការលក់កាបូនមិនបានដល់ដៃសហគមន៍ និង ការអភិវឌ្ឍន៍សហគមន៍ មូលដ្ឋាន។

- សំណូមពរ និង អនុសាសន៍៖

- សូមអោយមានការពិគ្រោះយោបល់ជាមួយសហគមន៍
- សូមឲ្យមានវគ្គបណ្តុះបណ្តាលកម្មវិធីរ៉េដបូកដល់សហគមន៍
- ជួយលើកកំពស់វិស័យព្រៃឈើរបស់សហគមន៍
- សូមឲ្យលប់បំបាត់ដីក្រុមហ៊ុនដែលនៅជិត និង ក្បែព្រៃសហគមន៍
- ការបែងចែកផលប្រយោជន៍ឲ្យមានតម្លាភាពដល់សហគមន៍
- មុនអនុវត្តគម្រោងត្រូវមានការបណ្តុះបណ្តាលបច្ចេកទេសផ្សព្វផ្សាយដល់សហគមន៍មូលដ្ឋាន
- រាជរដ្ឋាភិបាលមិនត្រូវផ្តល់ដីសម្បទានសេដ្ឋកិច្ច ឬ សង្គមកិច្ចនៅតំបន់កម្មវិធីរ៉េដបូក
- ផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់ប្រជាពលរដ្ឋដែលរស់នៅជិតកម្មវិធីរ៉េដ
- ផ្តល់សំភារៈដល់សហគមន៍សំរាប់ថែរក្សាការពារលើកម្មវិធីរ៉េដ
- រាជរដ្ឋាភិបាលត្រូវគាំទ្រ និងសហការជាមួយសហគមន៍ក្នុងតំបន់ព្រៃការពារ
- ជំរុញឲ្យមានការពិគ្រោះយោបល់ជាមួយសហគមន៍ក្នុងកម្មវិធីរ៉េដ
- សូមរាជរដ្ឋាភិបាលមានគោលការណ៍ច្បាស់លាស់ក្នុងការបែងចែកផលប្រយោជន៍
- សូមរាជរដ្ឋាភិបាលជួយផ្សព្វផ្សាយពត៍មានអំពីកម្មវិធីរ៉េដដល់សហគមន៍ជាប្រចាំ
- រាជរដ្ឋាភិបាលត្រូវជំរុញផ្នែកពាក់ពន្ធ័គ្រប់ជាន់ថ្នាក់ការពារព្រៃឈើ និង អនុវត្តច្បាប់ឲ្យមានប្រសិទ្ធិភាព។
- បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ
- និតិវិធីនៃការចរចារ- ជំនាញទំនាក់ទំនង
- ជំនាញដោះស្រាយវិវាទ- ជំនាញទាក់ទងនឹងច្បាប់ផ្សេងៗ
- ជំនាញទំនាក់ទំនងពត៍មានតាមប្រពន្ធ័អេឡិចត្រូនិច

- មានវគ្គបណ្តុះបណ្តាលពីកម្មវិធីរ៉េដបូកដល់សហគមន៍
- ទស្សនៈកិច្ចសិក្សា និង ផ្លាស់ប្តូរបទពិសោធន៍ពីកម្មវិធីរ៉េដ

## ការវាយតំលៃវគ្គសិក្ខាសាលា

កម្មវិធីជាបន្តគឺជាដំណើរការវាយតំលៃវគ្គសិក្ខាសិលា ដែលសម្របសម្រួលដោយ កញ្ញា តេង រិទ្ធីនី ដែលមានសំនួរសំខាន់ៗចំនួន២គឺ៖

១) តើពូ មីង គិតដូចម្តេចចំពោះសិក្ខាសិលានេះ? តើវាមានប្រយោជន៍ដែរឬទេ?
២) ប្រសិនបើមានវគ្គសិក្ខាសិលាលើកក្រោយទៀតតើពូមីងគួរមានអនុសាសន៍អ្វីខ្លះ?

លោក អ៊ាន អាន៖ សិក្ខាសាលា នេះយើងបានរៀនសូត្រច្រើនពីរ៉េដ ដោយសារវាជាលើកទី១នៅក្នុងខេត្តកំពង់ធំ។ ហើយគម្រោងនេះបានជួយដល់ការគ្រប់គ្រងធនធានព្រៃឈើឲ្យបានគង់វង្ស និង ជួយផ្តល់ប្រាក់ចំណូលដល់សហគមន៍ និងសំណូមពរឲ្យជួយផ្សព្វផ្សាយបន្តដល់សហគមន៍មូលដ្ឋាន។

លោក សា ថ្លៃ៖ ចង់ឲ្យមានការផ្សព្វផ្សាយបន្តឲ្យបានច្រើន ជាពិសេសប្រជាពលរដ្ឋនឹងបានទទួលនូវប្រាក់កំរៃ ហើយគម្រោងនេះបានជួយការពារឲ្យបានគង់វង្ស។

លោក ហែម សៀន៖ មានការចាប់អារម្មណ៍លើប្រធានបទខាងលើ ប៉ុន្តែសំណូមពរគួរតែឲ្យអ្នកជំនាញបានជួយចូលរួម និង ផ្តល់យោបល់ដល់អ្នកចូលរួមដោយសារពួកគាត់គឺជាអ្នកទទួលបន្ទុកផ្ទាល់លើការងារនេះ។

លោក សៀន ភាព៖ សូមឲ្យអញ្ជើញក្រុមប្រឹក្សាឃុំ និង អ្នកពាក់ពន្ធ័ចូលរួមឲ្យបានច្រើន និងជួយផ្សព្វផ្សាយឲ្យបានទូលំទូលាយ។

លោក វិន សុភាព៖ ខ្ញុំមិនដែលបានដឹងពីផលប្រយោជន៍ព្រៃឈើខ្លាំងបែបនេះទេពីមុន ទើបតែបានចូលរួមវគ្គផ្សព្វផ្សាយពីរ៉េដនេះទេ មិនតែប៉ុណ្ណោះយើងក៏អាចបានទទួលប្រាក់កំរៃពីរ៉េដផងដែរ។ សំណូមពរអោយបើកវគ្គបណ្តុះបណ្តាលដល់អ្នកពាក់ពន្ធ័ដែលជាកងរាជអាវុហត្ថ ពីព្រោះពួកគាត់សុទ្ធ តែមានការពាក់ពន្ធ័នឹងបទល្មើសព្រៃឈើ។

លោកស្រី សឿន ឡៃអ៊ី៖ ចំនុចខ្វះខាតរបស់វគ្គគឺខ្វះខាតអាហារសំរ៉ន់សំរាប់អ្នកចូលរួម ប៉ុន្តែចំនុចល្អគឺយើងអាចស្វែងយល់ពីកម្មវិធីរ៉េដដោយសារវាអាចជួយផ្តល់ប្រាក់ចំណូលដល់សហគមន៍។

លោកស្រីអភិបាលរងស្រុកកំពង់ស្វាយ៖ ចំនុចខ្វះខាតរបស់វគ្គ គឺពុំមានឯកសារគ្រប់គ្រាន់ សំរាប់អ្នកចូលរួមចំណែកឯការសំណូមពររបស់ខ្ញុំគួររៀបចំកម្មវិធីផ្សព្វផ្សាយពីរ៉េដ១ឆ្នាំ២ដងបើអាច។ មួយវិញទៀតចំនុចសំខាន់ គឺស្ថាបន័ពាក់

ពន្ធ័មានរដ្ឋបាលព្រៃឈើ និង បរិស្ថានគួរតែចូលរួមឲ្យបានពេញថ្ងៃពីព្រោះមានចំនុចខ្លះត្រូវការការបកស្រាយនឹងពន្យល់ពីពួកគាត់។

លោក ឆោម វណ្ណៈ ប្រសិនបើមានសិក្ខាសិលាលើកក្រោយគួរតែមានរៀបចំជាសំនួរវាយតំលៃ និង ការវាយតំលៃកំរិតយល់ដឹងរបស់អ្នកចូលរួម។

លោក វ៉ន ពៅ៖ គួរតែមានឯកសារចែកជូនជាមុនទៅគណៈអធិបតី និង ការរៀបចំទឹកឲ្យបានគ្រប់គ្រាន់ដល់អ្នកចូលរួម និង គណៈអធិបតី។ ចំនុចខ្លាំងដែលយើងទទួលបាននៅក្នុងវគ្គនេះគឺយើង បានធ្វើការផ្សព្វផ្សាយជូននូវកម្មវិធីរ៉េដដែលជាប្រធានបទថ្មី ដែលយើងទើបតែបានដឹង និងបានលឺតាមរយៈវគ្គសិក្ខាសិលានេះ។

# ព្រះវិហារ



# ព្រះវិហារ

សិក្ខាសាលាអប់រំផ្សព្វផ្សាយលើកទីបីនេះត្រូវបានរៀបចំឡើងសំរាប់រយៈពេល០២ថ្ងៃគឺចាប់ពីថ្ងៃទី ១៥-១៦ ខែមិនា ឆ្នាំ២០១២ នៅបរិវេណមន្ទីរអប់រំយុវជន និង កីឡាខេត្តព្រះវិហារ។ មានអ្នកចូលរួមសរុបចំនួន ៦០នាក់ក្នុងនោះស្រី ចំនួន ០៩នាក់ព្រមជាមួយនិងអ្នកតំណាងមកពី៖

- សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ
- ជនជាតិដើមភាគតិច (ជនជាតិគួយ) និងអង្គការសង្គមស៊ីវិលមួយចំនួនដូចជា ពន្លកខ្មែរ EWMI, RECOFTC, មជ្ឈមណ្ឌលសំរាប់ប្រជាជន និងព្រៃឈើ, វិទ្យាស្ថានខ្មែរសំរាប់សន្តិភាព និងការអភិវឌ្ឍន, IDEA, World Vision, CPN និង WCS
- មន្ទីរបរិស្ថាន និងខណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះវិហារ។

## ប្រធានបទសំខាន់ៗ

កម្មវិធីរបស់សិក្ខាសាលាក្នុងខេត្តព្រះវិហាររួមមាន៖

១) ខ្សែភាពយន្តឯកសារស្តីពីការប្រែប្រួលអាកាសធាតុ និងបទពិសោធន៍REDD
២)បទបង្ហាញស្តីពី និន្នាការអភិវឌ្ឍន៍ និងវិស័យព្រៃឈើនៅកម្ពុជា។ ទំនាក់ទំនងរវាងជនជាតិដើមភាគតិច និងរ៉េដបូក ជាមួយនិងការប្រែប្រួលអាកាសធាតុ ព្រមទាំងការព្រួយបារម្ភចំពោះបញ្ហាពាក់ព័ន្ធនានា។ បទពិសោធន៍រ៉េដបូកនៅខេត្តឧត្តមានជ័យ បញ្ហាបំរែបំរួលអាកាសធាតុពិភពលោក និងកម្មវិធិថ្នាក់ជាតិ(NAPA)។ ផែនទីបង្ហាញផ្លូវរ៉េដបូកនៅកម្ពុជា និងការចូលរួមរបស់ អង្គការសង្គមស៊ីវិល ក្នុងការអភិវឌ្ឍន៍ផែនទីបង្ហាញផ្លូវរ៉េដបូក។

## កិច្ចពិភាក្សា និង លទ្ធផលសិក្ខាសាលា

ថ្ងៃទី១៖ ១៥ មិនា ឆ្នាំ២០១២

ក្រោយពីមតិស្វាគមន៍ និង បើកកម្មវិធីរបស់គណៈអធិបតីរួមមក អ្នកសម្របសម្រួលបានអញ្ជើញវាគ្មិនដើម្បីធ្វើបទបង្ហាញដែលរួមមានប្រធានបទសំខាន់ៗដូចខាងក្រោម៖

លោក ឆឹង ស៊ីរិយ៉ា, អង្គការNTFP-EP បានធ្វើបទបង្ហាញស្តីពីព្រៃឈើ និងនិន្នាការការអភិវឌ្ឍន៍នៅប្រទេស កម្ពុជារួមជាមួយការបង្ហាញខ្សែភាពយន្តឯកសារ។ បន្ទាប់ពីការបង្ហាញខ្សែភាពយន្តលោក រិរិយ៉ាបានបំផុសកិច្ចពិភាក្សាមួយចំនួនអំពីពាក្យគន្លឹះ និង ទស្សនៈទានសំខាន់ៗដូចជា: «ឧស្ម័នផ្ទះកញ្ចក់»

បន្ទាប់មកទៀតអ្នកចូលរួមបានលើកជាសំនួរមួយចំនួនមានជាអាទិ៍៖

១)តើហេតុអ្វីបានប្រទេសអភិវឌ្ឍន៍ស្នើសុំឲ្យប្រទេសកំពុងអភិវឌ្ឍន៍ដូចជាកម្ពុជាការពារព្រៃឈើបើប្រទេសទាំងអស់នោះបានបាត់បង់ព្រៃឈើអស់ទៅហើយ?

ចំលើយ៖
ការប្រែប្រួលអាកាសធាតុមិនមែនជាបញ្ហា សំរាប់តែប្រទេសកម្ពុជានោះទេវាគឺជាបញ្ហាសំរាប់ប្រទេសទាំងអស់នៅក្នុងតំបន់។ នៅពេលដែលយើងខិតខំការពារព្រៃឈើ នៅប្រទេសយើងមានន័យថាយើង បានរួមចំណែកទៅដល់ការកាត់បន្ថយការសាយភាយ ឧស្ម័នដែលជាមូលហេតុ នាំឲ្យមានការកើនឡើង នូវកំដៅផែនដី។

២) ហេតុដូចម្តេចបានជាគំរបព្រៃឈើឆ្នាំ១៩៩៦ មានការថយចុះហើយឆ្នាំ២០០២ មានការកើនឡើង?

តំណាងខណ្ឌរដ្ឋបាលព្រៃឈើបានឆ្លើយសំនួរខាងលើ៖ ដោយសារតែនៅចន្លោះឆ្នាំ១៩៩៦ និង ១៩៩៧ រាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានទៅក្រុមហ៊ុនឯកជនដែលគេឲ្យឈ្មោះថាព្រៃគុប ហើយនៅក្នុងឆ្នាំ២០០២ រដ្ឋាភិបាលបានបញ្ឈប់ការផ្តល់ដីសម្បទានទាំងនោះ។

លោក ណាក់ វ៉េន, មន្ត្រីសិទ្ធិព្រៃឈើមូលដ្ឋានរបស់អង្គការ NTFP-EP បានធ្វើបទបង្ហាញស្តីពីទំនាក់ទំនង របស់ជនជាតិដើមភាគតិចទៅនឹងកម្មវិធីរ៉េដបូក ការប្រែប្រួលអាកាសធាតុ និង ការព្រួយបារម្ភរបស់ពួកគេ។

សំនួរ និង យោបល់ចូលរួមសំខាន់ៗមួយចំនួនលើប្រធានបទនេះមានដូចខាងក្រោម៖

១) តើកាទិញលក់កាបូនគេធ្វើដូចម្តេចខ្លះ? តើអ្វីទៅជាការលេចធ្លាយ?

ចំលើយ៖
ប្រទេសកំពុងអភិវឌ្ឍន៍នឹងទិញកាបូនតាមរយៈទីផ្សារស្មគ្រ័ចិត្ត ឬតាមរយៈយន្តការព្រមព្រៀង។ ការលេចធ្លាយកាបូនមានន័យថានៅពេលដែលផ្ទៃដីព្រៃឈើក្នុងតំបន់ឫនៅក្បែរតំបន់ដែលយើងខិតខំការពារមានការកាប់បំផ្លាញ និងការអស់ព្រៃឈើ។

២) តើអ្វីទៅជាកាបូន?

ចំលើយ៖
គាត់បានពន្យល់ថាកាបូនគឺជាប្រភេទឧស្ម័នធម្មជាតិ ដែលមាននៅក្នុងដើមឈើដែលមានវាតួនាទីបន្សុទ្ធជាតិពុលក្នុងបរិយាកាស។

៣)តើហេតុអ្វីបានជាកម្មវិធីរេដបូកចំណាយពេលរហូតដល់ឆ្នាំ២០១៥ មុនពេលចាប់ផ្តើមអនុវត្តសកម្មភាពរបស់ ខ្លួន?

ចំលើយៈ
យោងទៅលើផែនទីបង្ហាញផ្លូវរេដបូកកម្ពុជាវាតំរូវឲ្យមានការរៀបចំផែនការសកម្មភាពតាមរយៈដំណើរ ការពិគ្រោះយោបល់ដែលរួមមានការជ្រើសរើសតំណាងអង្គការសង្គមស៊ីវិល និងជនជាតិដើមភាគតិចដើម្បីឆ្ពោះ ទៅការរៀបចំផែនការយុទ្ធសាស្ត្ររេដបូកថ្នាក់ជាតិ។ ដំណើរការទាំងនេះនឹងទាមទារឲ្យមានតម្លាភាព ភាពស្មើគ្នា តាមរយៈការផ្តល់ឱកាសឲ្យតំណាងជនជាតិដើមភាគតិចមួយរូប ដែលតំណាងនេះនឹងមានការចូលរួមពិភាក្សាជ្រើសរើសតាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់ជាតិ។

បទបង្ហាញពីបទពិសោធន៍នៃការអនុវត្តកម្មវិធីរេដបូក និងបញ្ហាប្រឈមនៅខេត្តឧត្តរមានជ័យដោយ លោក ជី បូរ៉េត,នាយកប្រតិបត្តិសមាគមន៍អភិវឌ្ឍន៍កុមារ។គាត់បានមានប្រសាសន៍ថាបទបង្ហាញនាពេលព្រឹកនេះនឹងរួមបញ្ចូលនូវទស្សនៈទាននៃព្រៃឈើ និងការសាយភាយឧស្ម័ន ហើយគោលបំណងសំខាន់របស់ពួកយើងគឺលើកទឹកចិត្តឲ្យមានការការពារ និងដាំព្រៃឈើឡើងវិញ។ គាត់បានមានប្រសាសន៍ថាមានសហគមន៍ព្រៃឈើសរុបទាំងអស់ចំនួន១២៣ សហគមន៍ នៅក្នុងខេត្តឧត្តរមានជ័យដែលបានចុះបញ្ជីជាមួយក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និង នេសាទ។ គម្រោងរេដបូកបានចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៨ដោយមានការអនុវត្តផ្ទាល់ពីខណ្ឌរដ្ឋបាលព្រៃឈើ សហការជាមួយគម្រោងអង្គការ CFI/PACT និង សហគមន៍មូលដ្ឋានដែលមានគោលបំណងសំខាន់ គឺការថែរក្សាកាបូនស្តុកសំរាប់រយៈពេល៣០ឆ្នាំ ខាងមុខទៀត។ សកម្មភាពសំខាន់ៗដែលមានអនុវត្តរួមមានៈ

- ការរៀបចំកិច្ចព្រមព្រៀង
- ការផ្សព្វផ្សាយ
- វគ្គបណ្តុះបណ្តាល
- ការអនុវត្តនៅទីវាល
- ការបង្កើតនូវវិធីសាស្ត្រអនុវត្ត
- ការវាស់វែងនៅទីវាល
- ការរៀបចំនូវឯកសារគម្រោងសំរាប់ស្នើសុំទៅស្តង់ដាកាបូនស្មគ្រ័ចិត្ត និង សម្ពន្ធ័ភាពជីវៈចំរុះ សហគមន៍
- ការរៀបចំនិតិវិធីអនុវត្តគម្រោង
- ការរៀបចំការត្រួតពិនិត្យសំរាប់អធិការកិច្ចលើកទីមួយ
- ច្បាប់ និងឯកសារបន្ថែម
- កិច្ចព្រមព្រៀង ទិញលក់កាបូន។

ប្រសិនបើគ្មានការជឿជាក់ពីមន្ត្រីជំនាញ និងអ្នកឯកទេស(អ្នកត្រួតពិនិត្យ/អ្នកវាយតម្លៃអន្តរជាតិ) គម្រោង នេះនឹងមិនអាចអនុវត្តបានឡើយ។ ដើម្បីធ្វើអោយមានសន្តិសុខដល់តំបន់អភិក្យកាបូន ត្រូវធានាដល់ដល់តំបន់ ផ្សេងៗដែលនៅជុំវិញតំបន់កំពុងអនុវត្តដើម្បីជៀសវាងកុំឲ្យមានការលេចធ្លាយ ដោយសារតែនៅពេលដែលមានការ លេចធ្លាយគម្រោងលក់កាបូននឹងមិនមាននរណាទិញឡើយ។ កិច្ចព្រមព្រៀងទិញលក់កាបូននឹងត្រូវពិនិត្យឡើងវិញ រៀងរាល់៥ឆ្នាំម្តង។

មូលហេតុនៃការកាប់បំផ្លាញព្រៃឈើនៅខេត្តឧត្តរមានជ័យដោយសារតែៈ

- ក្រុមហ៊ុនសម្បទាន
- ការរានដី
- ភ្លើងឆេះព្រៃ
- កង្វះខាតជំនាញបច្ចេកទេសក្នុងការប្រមូលផលពីព្រៃឈើ
- ការប្រើប្រាស់ផលព្រៃឈើសំរាប់ការប្រើប្រាស់ក្នុងតំបន់
- ការសាង់សង់នូវភូមិថ្មីជាប់នឹងព្រំដែនខ្មែរថៃ
- បញ្ហានៃជនអន្តរប្រវេសន៍
- ការយល់ដឹងតិចតួចរបស់ សហគមន៍លើគម្រោងរ៉េដបូក
- ទីផ្សារកាបូនមានតម្លៃទាប។

១) តើមានការកាត់បន្ថយឧស្ម័នកាបូននិចប៉ុន្មានភាគរយនៅក្នុងប្រទេសកម្ពុជា?

ចំលើយៈ
លោកស្មៀន បុរីរ័ត្ន, នាយករងសមាគមន៍សមាគមន៍អភិវឌ្ឍន៍កុមារៈ យោងតាមឯកសារគម្រោងបានបង្ហាញ ថាមានកាបូនស្តុកប្រមាណជា៨.១លានតោន/ឆ្នាំនៅខេត្តឧត្តរមានជ័យ ប៉ុន្តែយើងមិនទាន់ បានឃើញពីការគណនា របស់គម្រោងរ៉េដបូកនៅតំបន់របស់យើងនៅឡើយទេ ដូចនេះយើងមិនទាន់អាចកំណត់ បាននៅឡើយទេ។

២) តើមានប៉ុន្មានប្រទេសដែលអនុវត្តគម្រោងរ៉េដបូកសាកល្បង? តើលោកគិតថាគម្រោងសាកល្បងទាំងនេះ ពិតជានឹងផ្តល់ផលប្រយោជន៍ដែលអាចតំណាងឲ្យតំបន់ផ្សេងៗទៀតក្នុងប្រទេសកម្ពុជាដែរឬទេ?

ចំលើយៈ
មានប្រទេសរុបចំនួន១៩២ប្រទេសនៅលើពិភពលោក បាននឹងកំពុងចូលរួម ដែលក្នុងនោះនៅតំបន់អាស៊ី ប្រទេសដែលកំពុងអនុវត្តគម្រោងរ៉េដបូកមានដូចជាៈ ឥណ្ឌូនេស៊ី វៀតណាម ឡាវ ថៃ នេប៉ាល់ ហ្វីលីពីន...។ល។ ប្រទេសទាំង១៩២បានប្តេជ្ញាចិត្តដើម្បីចូលរួមកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ យោងទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ សន្និសិទនៃបណ្តាភាគីជាសមាជិក និងគោលនយោបាយជាមូលដ្ឋានរបស់ជាតិ ។ នៅក្នុងប្រទេសកម្ពុជាយើងមានគម្រោងរ៉េដសាកល្បងនៅខេត្តឧត្តរមានជ័យ គម្រោងអភិរក្សជីវចំរុះ និងរ៉េដបូក សីម៉ារ ខេត្តមណ្ឌលគិរី និង ព្រៃឡង់។ ប្រសិនបើមានការសហការល្អរវាងអ្នកពាក់ពន្ធ័ទាំងអស់ និងការគាំទ្រគោល នយោបាយគម្រោងរ៉េដបូកអាចមានលទ្ធភាពទទួលជោគជ័យច្រើន។

លោក សេង សុខហេង, ប្រធានបណ្តាញកសាងបណ្តាញសន្តិភាពសហគមន៍បានធ្វើបទបង្ហាញស្តីពីផែនទី បង្ហាញផ្លូវរ៉េដបូកកម្ពុជា។ គាត់ក៏បានបង្ហាញផងដែរនូវខ្សែភាពយន្តឯកសារស្តីពី បទពិសោធន៍នៃ ការអនុវត្តគម្រោងរ៉េដបូកនៅតំបន់សីម៉ា ខេត្តមណ្ឌលគិរី

ថ្ងៃទី២៖ ១៦ មិនា ឆ្នាំ២០១២

របៀបវារៈបន្ទាប់លោក ឆឹង ស៊ីរីយ៉ា បានធ្វើបទបង្ហាញស្តីពីការចូលរួមរបស់សហគមន៍មូលដ្ឋាន និង អង្គការសង្គមស៊ីវិលលើកម្មវិធីរ៉េដបូក និងដំណើរការអនុវត្តគម្រោងរ៉េដបូកនៅថ្នាក់ជាតិ៖

- ការរៀបចំផែនទីបង្ហាញផ្លូវរ៉េដបូក(២០០៩-២០១១)
- ការរៀបចំនូវឯកសាររ៉េដបូក និងការផ្សព្វផ្សាយ (២០១២-២០១៤)
- ការអនុវត្តកម្មវិធីរ៉េដបូក(២០១៥)

នៅពេលបច្ចុប្បន្នយើងបានអនុវត្តដល់ជំហានទី២នៃផែនទីបង្ហាញផ្លូវរ៉េដបូក ដែលនឹងមានការបោះឆ្នោតជ្រើសរើសតំនាងពីសង្គមស៊ីវិល និងសហគមន៍មូលដ្ឋានដើម្បីចូលរួមពិគ្រោះយោបល់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ រ៉េដបូកថ្នាក់ជាតិ។

បន្ទាប់មកទៀតអ្នកចូលរួមទាំងអស់ត្រូវបានបែងចែកជា៣ក្រុមដើម្បីពិភាក្សាទៅលើសំនួរសំខាន់ៗ៣ដែលមាន ជាអាទិ៍៖

១) តើសហគមន៍មូលដ្ឋាន និង ជនជាតិដើមភាគតិចត្រូវចូលរួមក្នុងដំណើរការនៃការពិភាក្សា និង អនុវត្តនូវកម្មវិធីរ៉េដបូកក្នុងប្រទេសកម្ពុជាយ៉ាងដូចម្តេច?
២) តើព័ត៌មានសំខាន់ៗអ្វីខ្លះដែលលោកអ្នកត្រូវការដឹងអំពីកម្មវិធីរ៉េដបូក?
៣) តើលោកអ្នកមានសេចក្តីព្រួយបារម្ភ និង សំនើរសុំអ្វីខ្លះទាក់ទងទៅនឹងកម្មវិធីរ៉េដបូកនៅប្រទេសកម្ពុជា?

**សង្ខេបលទ្ធផលនៃការពិភាក្សាក្រុមលើសំនួរទាំង៣ខាងលើ៖**

១) សហគមន៍ត្រូវតែចូលរួមរាល់គ្រប់ដំណើរការនៃការពិគ្រោះយោបល់ពីថ្នាក់មូលដ្ឋាន រហូតដល់ថ្នាក់ជាតិ ហើយសហគមន៍បានផ្តល់ថាត្រូវតែមានតំណាងរបស់ពួកគេនៅក្នុងរចនាសម្ព័ន្ធកម្មវិធីរ៉េដបូក។

- ផ្តល់ឱកាសឲ្យសហគមន៍ជាពិសេសគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិ បានចូលរួមក្នុងការជ្រើសរើសតំណាងនៅសិក្ខាសាលាថ្នាក់ខេត្ត។
- គួរតែផ្តល់ឱកាសដល់ក្រុមជនជាតិដើមភាគតិចដើម្បីបានចូលរួមក្នុងសិក្ខាសាលាពិភាក្សានៅថ្នាក់ជាតិ។
- គួរតែមានប្រាក់ឧបត្ថម្ភចូលរួមសំរាប់តំនាងក្រុមជនជាតិដើមភាគតិចនៅសិក្ខាសាលាពិគ្រោះ យោបល់ថ្នាក់ជាតិ។
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយស្តីពីគម្រោងរ៉េដបូកដល់សហគមន៍តំបន់ការពារធម្មជាតិ
- ការពិភាក្សាពិគ្រោះយោបល់គួរតែរួមបញ្ចូលទៅក្នុងដំណើរការអនុវត្តគម្រោងរ៉េដបូក
- ដំណើរការគម្រោងរ៉េដបូកគួរតែអនុវត្តជាមួយសហគមន៍មូលដ្ឋាន
- គម្រោងរ៉េដបូកបានរួមចំណែកកាត់បន្ថយនូវជំលោះលើបញ្ហាដីធ្លី និងព្រៃឈើដែលបណ្តាលមកពីក្រុមហ៊ុនឯកជន និង ទាហាន។

- អាជ្ញាធរមូលដ្ឋាន និង ខណ្ឌរដ្ឋបាលព្រៃឈើត្រូវធ្វើការយ៉ាងជិតស្និតជាមួយសហគមន៍ដើម្បីជួយសម្របសម្រួល ដោះស្រាយទំនាស់ដែលកើតឡើង។
- សិក្ខាសាលាពិគ្រោះយោបល់ស្តីពីរ៉េដបូកត្រូវតែរៀបចំនៅថ្នាក់ភូមិ ឃុំ និង ខេត្តដើម្បីជ្រើសរើស តំណាង។
- គួរតែមានការផ្សព្វផ្សាយព័ត៌មានស្តីពីសកម្មភាពរ៉េដបូកដល់សហគមន៍មូលដ្ឋាន
- ពង្រឹងសមត្ថភាពផ្សេងៗដល់គណៈកម្មការគ្រប់គ្រងសហគមន៍
- ធ្វើការបង្ហាញឲ្យបានច្បាស់លាស់ពីចំនុចវិជ្ជមាន និង អវិជ្ជមាននៃគម្រោងរ៉េដបូកដល់សហគមន៍
- គម្រោងរ៉េដបូកមានការពាក់ពន្ធ័ជាមួយសហគមន៍ដោយសារតែពួកគេបានរស់ក្បែរ និង ក្នុងព្រៃដោយទទួលបានផលប្រយោជន៍ដោយផ្ទាល់ពីព្រៃឈើ។
- ប្រសិនបើគ្មានសហគមន៍នៅក្បែរ ឬ ក្នុងព្រៃសហគមន៍គម្រោងរ៉េដបូកមិនអាចទទួលបានជោគជ័យនោះទេ។
- គួរតែធ្វើការសិក្សាប៉ាន់ប្រមាណលើផលប៉ះពាល់វិជ្ជមាន និង អវិជ្ជមាននៃគម្រោងរ៉េដបូកដល់សហគមន៍។
- ផលប្រយោជន៍ពីគម្រោងរ៉េដបូក បទពិសោធន៍ និង ការសំរេចបានគួរតែត្រូវផ្សព្វផ្សាយ ដល់សហគមន៍មូលដ្ឋាន។
- កសាងទំនាក់ទំនងរវាងស្ថាបន័ពាក់ពន្ធ័ដើម្បីធ្វើការរៀបចំគម្រោងរ៉េដបូកឲ្យបានល្អ

២) ព័ត៌មានដែលត្រូវសំរាប់សហគមន៍មូលដ្ឋានមានដូចខាងក្រោម៖

- ធ្វើការអប់រំផ្សព្វផ្សាយពីគម្រោងរ៉េដបូកដល់សមាជិកសហគមន៍
- វគ្គបណ្តុះបណ្តាលពីការប្រែប្រួលអាកាសធាតុ
- ឯកសាររ៉េដបូកស្តីពីបទល្មើស និងសកម្មភាពហាមឃាត់គួរតែបកប្រែជាភាសាខ្មែរនិងមានការផ្សព្វផ្សាយតាមទូរទស្សន៍ និងវិទ្យុផងដែរ។
- ស្នើសុំនូវឯកសារច្បាប់ពាក់ពន្ធ័ផ្សេងៗរួមទាំងក្របខណ្ឌ័ច្បាប់របស់គម្រោងរ៉េដបូក
- ការរួមបញ្ចូលនូវសិទ្ធិជនជាតិដើមភាគតិចទៅក្នុងកម្មវិធីរ៉េដបូកថ្នាក់ជាតិ
- សហគមន៍ត្រូវការនូវការកសាងសមត្ថភាពមានដូចជា៖ ច្បាប់ និងរ៉េដបូក។ ហើយពួកគេក៏ត្រូវការការវគ្គបំប៉នដើម្បីលើកកំពស់ចំណេះដឹងស្តីពីការគ្រប់គ្រងប្រព័ន្ធព្រៃឈើផងដែរ។
- គួរតែផ្តល់ឱកាសឲ្យសហគមន៍ដើម្បីធ្វើទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ និងរៀនសូត្រពី គម្រោងជោគជ័យផ្សេងៗនៅខាងក្រៅប្រទេស។

៣) តើលោកអ្នកមានសេចក្តីព្រួយបារម្ភ សំណើសុំ និងអនុសាសន៍យ៉ាងដូចម្តេចខ្លះ?

- សេចក្តីព្រួយបារម្ភ៖
  - គួរតែដោះស្រាយអោយបានច្បាស់លាស់ពីបញ្ហាព្រៃឈើមុននឹងអនុវត្តគម្រោងរេដបូក
  - ការទទួលបានព័ត៌មានមិនគ្រប់គ្រាន់នឹងធ្វើអោយបាត់បង់សិទ្ធិជនជាតិដើមភាគតិចនៅក្នុងដំណើរការរៀបចំគម្រោងរេដបូក។
  - មិនត្រូវផ្តល់គម្រោងដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនឯកជននៅពេលកំពុងអនុវត្តគម្រោង រេដបូក
  - សហគមន៍មូលដ្ឋាននឹងមិនត្រូវបានអនុញ្ញាត្តិឲ្យទៅប្រមូលអនុផលព្រៃឈើរបស់ពួកគេដូចជា៖ ជ័រ ទឹក, ផ្តៅ,ឃ្មុំ, ផ្លែឈើ, និងអនុផលព្រៃឈើផ្សេងៗទៀតដែលពួកគេប្រើប្រាស់ប្រចាំថ្ងៃ។
  - បទល្មើសផ្សេងៗដូចជា៖ ការចាប់យកដីព្រៃ និងការកាប់បំផ្លាញព្រៃឈើនឹងមាន ការកើនឡើងតាមរយៈការអនុវត្តគម្រោងរេដបូក។
  - សហគមន៍ដែលនៅក្បែរតំបន់ព្រៃឈើមិនសូវមានការយល់ដឹងពីទស្សនៈទាននៃរេដបូក
  - ការចែករំលែកព័ត៌មានពីរដ្ឋបាលព្រៃឈើ និង សហគមន៍លើគម្រោងរេដបូក

- សំណើសុំ និងអនុសាសន៍
  - គម្រោងរេដបូកត្រូវតែធ្វើឲ្យមានតម្លាភាព និងគណនេយ្យភាពពីខាងរដ្ឋាភិបាល
  - រដ្ឋាភិបាលគួរតែលុបចោលគម្រោងដីសម្បទានសេដ្ឋកិច្ចដែលជាន់ជាមួយដីសហគមន៍ និងជនជាតិ ដើមភាគតិច។
  - សហគមន៍មូលដ្ឋានត្រូវការប្រមូលនូវអនុផលព្រៃឈើសំរាប់ផ្គត់ផ្គង់សកម្មភាពប្រចាំថ្ងៃរបស់ពួកគេប្រសិនបើរដ្ឋាភិបាលសំរេចផ្តល់ដីសម្បទានគម្រោងរេដទាំងនោះមកសហគមន៍គ្រប់គ្រង។
  - សំណើសុំយល់ព្រមលើការសាងសង់ផ្ទះ
  - តួនាទីរបស់សហគមន៍គួរត្រូវពិចារណានៅក្នុងដំណើរការរៀបចំគម្រោងរេដបូកស្តីពីការគ្រប់គ្រងព្រៃឈើ និងដីព្រៃ។
  - នៅពេលការអនុវត្តគម្រោងរេដបូកត្រូវបានបញ្ចប់ ដីព្រៃសហគមន៍ដែលបានអនុវត្តគួរត្រូវបង្វែរជូន ទៅសហគមន៍ជាអ្នកគ្រប់គ្រងវិញ។
  - គួរតែពន្យល់ពីផលប៉ះពាល់ជាវិជ្ជមាន អវិជ្ជមានពីគម្រោងរេដបូកដល់សហគមន៍មូលដ្ឋាន
  - ផ្សព្វផ្សាយពីចំណោះដឹង និងគុណតម្លៃពីគម្រោងរេដបូកដល់សហគមន៍
  - កសាងនូវកិច្ចសហការ និងការទំនាក់ទំនង រវាងស្ថាបន័ពាក់ពន្ធ័លើការរៀបចំគម្រោងរេដបូក

## សន្និដ្ឋាន

តាមការសង្កេតជាទូទៅបានបង្ហាញថា ក្នុងក្របខ័ណ្ឌរេដបូកនេះការយល់របស់អ្នកចូលរួម មានខុសៗគ្នា។ នៅមានចំនុចបច្ចេកទេសមួយចំនួនទៀតដែលមិនបានបង្ហាញនៅក្នុងវគ្គបណ្តុះបណ្តាលនេះ។ នៅខាងផ្នែកវិជ្ជមានវិញពួកគេបានពិភាក្សាអំពីបទពិសោធន៍ផ្សេងៗគ្នា និងការយល់ឃើញទៅលើទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងព្រៃឈើ ការគ្រប់គ្រងព្រៃឈើ និងជីវភាពរបស់ប្រជាជន។

មួយភាគធំនៃការចូលរួមរបស់ជនជាតិដើមភាគតិចគួយបានបង្ហាញពីការផ្តួចផ្តើមរបស់ពួកគេដើម្បីការពារ និងអភិរក្សព្រៃឈើ និង ជីវចំរុះ និងធនធានធម្មជាតិ។ ចំនុចពិភាក្សាពួកគេបានផ្តល់នូវកសិណសក្សីអំពីប្រពៃណី ប្រើប្រាស់ដីធ្លីនិង ការគ្រប់គ្រង និងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីការពារ និងទាមទារផ្ទៃដី ដែលបាត់បង់ក្នុង ខេត្តព្រះវិហារជាពិសេសអ្នកដែលមានដីជាន់ជាមួយដីប្រើប្រាស់ផ្សេងៗរបស់ក្រុមហ៊ុន ទាហាន ឬ តំបន់ដែលបានប្រកាសឲ្យការពារ និងតំបន់ជីវៈចំរុះដែលបច្ចុប្បន្នពួកគេមិនអាចប្រើប្រាស់បាន។

### យោបល់ទូទៅ និង អនុសាសន៍

- ការចែកឯកសារផ្សព្វផ្សាយស្តីពីរ៉េដបូកដល់សហគមន៍
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយរ៉េដបូកម្តងទៀត
- ត្រូវតែកំណត់ឯកសារផ្សព្វផ្សាយរ៉េដបូកកុំឲ្យជាន់ខ្លឹមសារដូចគ្នា
- វិធីសាស្ត្រផ្សព្វផ្សាយត្រូវរៀបចំដោយមានរូបភាពពន្យល់ជៀសវាងការសរសេរវែង ពីព្រោះចំណេះដឹងរបស់សិក្ខាកាមនៅមានកំរិត
- ត្រូវមានការសិក្សាពីការជ្រើសរើសទីតាំងរ៉េដបូក
- សហគមន៍បានផ្តល់យោបល់ទៅរដ្ឋបាលព្រៃឈើគួរតែផ្តល់ដីព្រៃទៅដល់សហគមន៍ដើម្បីធ្វើការគ្រប់គ្រងដោយខ្លួនឯង។

# មណ្ឌលគិរី



# មណ្ឌលគិរី

សិក្ខាសាលាអប់រំផ្សព្វផ្សាយទីបួននេះត្រូវបានរៀបចំឡើងសំរាប់រយៈពេល០២ថ្ងៃគឺចាប់ពីថ្ងៃទី ១៧-១៨ ខែ ឧសភា ឆ្នាំ២០១២ នៅបរិវេណមន្ទីរសុខាភិបាល ខេត្តមណ្ឌលគីរី។ មានអ្នកចូលរួមសរុបចំនួន ៦២នាក់ក្នុងនោះស្រីចំនួន ១៦នាក់ រួមជាមួយនិងអ្នកតំណាងបងប្អូនជនជាតិដើមភាគតិចភ្នង មកពីសហគមន៍ព្រៃឈើ អង្គការដៃគូរនានារួមមាន៖ MVI CLEC IRAM និងCIYA។ និស្សិត និងតំណាងមកពីមន្ទីរបរិស្ថាន និង រដ្ឋបាលព្រៃឈើក៏បានចូលរួមផងដែរ។

## ប្រធានបទសំខាន់ៗ

កម្មវិធីរបស់សិក្ខាសាលាក្នុងខេត្តមណ្ឌលគិរីរួមមាន៖

១) ខ្សែភាពយន្តឯកសារស្តីពីការប្រែប្រួលអាកាសធាតុ និងបទពិសោធន៍រ៉េដបូកក្នុងខេត្តឧត្តមានជ័យ
២) បទបង្ហាញស្តីពី និន្នាការអភិវឌ្ឍន៍ និងវិស័យព្រៃឈើនៅកម្ពុជា។ ទំនាក់ទំនងរវាងជនជាតិដើមភាគតិច និងរ៉េដបូក ជាមួយនិងការប្រែប្រួលអាកាសធាតុ ព្រមទាំងការព្រួយបារម្ភចំពោះបញ្ហាពាក់ព័ន្ធនានា។ បទពិសោធន៍រ៉េដបូកនៅខេត្តឧត្តមានជ័យ។ ផែនទីបង្ហាញផ្លូវរ៉េដបូកនៅកម្ពុជា និងការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងការអភិវឌ្ឍន៍ផែនទីបង្ហាញផ្លូវរ៉េដបូក។

## កិច្ចពិភាក្សា និង លទ្ធផលសិក្ខាសាលា

ថ្ងៃទី១៖ ១៧ ឧសភា ឆ្នាំ២០១២

ក្រោយពីមតិបើកកម្មវិធីរបស់គណៈអធិបតីរួមមក ក្រុមការងារបានបញ្ចាំងភាពយន្តឯកសារ ស្តីពីការប្រែប្រួលអាកាសធាតុ ដែល ផលិតដោយក្រសួងបរិស្ថានដែលមានរយៈពេល១៥នាទី។ ប្រធានបទបន្តគឺជាបទបង្ហាញរបស់លោក ឆឹង ស៊ីរីយ៉ា ស្តីពីនិន្នាការអភិវឌ្ឍន៍នៅកម្ពុជា និងវិស័យព្រៃឈើ។ ដែលផ្តោតជាសំខាន់ទៅលើសកម្មភាពអភិវឌ្ឍន៍ដែលធ្វើអោយមានផលប៉ះពាល់ដល់ធនធានធម្មជាតិ។

សំនួរ និង យោបល់ចូលរួមសំខាន់ៗមួយចំនួនលើប្រធានបទនេះមានដូចខាងក្រោម៖

១)ប្រសិនបើការដាំដំណាំកៅស៊ូនាំឲ្យមានការកាប់បំផ្លាញព្រៃឈើ ហេតុអ្វីបានរាជរដ្ឋាភិបាលកម្ពុជានៅតែបន្តអនុគ្គគម្រោងទាំងនោះ?

ចំលើយ៖
ការអភិវឌ្ឍន៍មួយចំនួនមិនបណ្តាលឲ្យមានផលជាអវិជ្ជមានដល់ធនធានព្រៃឈើទេ ប្រសិនបើយើងមាន យន្តការច្បាស់លាស់ក្នុងការអភិវឌ្ឍន៍។ ជាគោលការណ៍ណែនាំគេតំរូវឲ្យ មានការសិក្សាវាយតម្លៃពីផលប៉ះពាល់លើធនធាន

ធម្មជាតិមុនសំរេចផ្តល់គម្រោងអភិវឌ្ឍន៍ដល់ក្រុមហ៊ុនឯកជន ប៉ុន្តែពេលខ្លះយន្តការទាំងនេះមិនត្រូវបានគេអនុវត្តឡើយ។

២) តើមានការខេត្តណាខ្លះដែលនៅសេសសល់ព្រៃឈើ?

ចំលើយ៖
ខេត្តកោះកុង មណ្ឌលគិរី រតនៈគិរី ឧត្តរមានជ័យ ស្ទឹងត្រែង ពោធិ៍សាត់ និងបាត់ដំបង

ប្រធានបទបន្តលោក ណក់ វ៉ែន, បានធ្វើបទបង្ហាញស្តីពីទំនាក់ទំនងរបស់ជនជាតិដើមភាគតិច ទៅនឹងកម្មវិធីរ៉េដបូក ការប្រែប្រួលអាកាសធាតុ និង ការព្រួយបារម្ភរបស់ពួកគេ។

កម្មវិធីបន្ទាប់គឺការបង្ហាញខ្សែវីដេអូពីបទពិសោធន៍អនុវត្តកម្មវិធីរ៉េដបូកនៅខេត្តឧត្តរមានជ័យ និង បទបង្ហាញ ពីការងារអនុវត្តកម្មវិធីរ៉េដរបស់អង្គការស៊ីឌីអេ ដោយលោក ជី បូរ៉េត នាយកប្រតិបត្តិអង្គការ ស៊ីឌីអេ។

លោក ស្មៀន បុរីរត្ន័, នាយករងអង្គការ ស៊ីឌីអេ បានធ្វើបទបង្ហាញស្តីពីការចូលរួម របស់អង្គការសង្គមស៊ីវិលលើកម្មវិធីរ៉េដបូក ហើយគាត់ក៏បានបង្ហាញពីយុទ្ធសាស្រ្ត ណាប៉ា(NAPA)ផងដែរ។

## ថ្ងៃទី២៖ ១៨ ឧសភា ឆ្នាំ២០១២

អ្នកចូលរួមទាំងអស់ត្រូវបានបែងចែកជា៣ក្រុមដើម្បីពិភាក្សាទៅលើសំនួរសំខាន់ៗ៣ខាងលើលទ្ធផលនៃការពិភាក្សាក្រុមមានដូចខាងក្រោម៖

១) ផែនទីបង្ហាញផ្លូវនៃយុទ្ធសាស្រ្តរ៉េដបូកថ្នាក់ជាតិៈ

ក).តើលោកអ្នកនឹងចូលរួមរៀបចំដូចម្តេច?

ចំលើយ៖
- ចូលរួមប្រជុំផ្សព្វផ្សាយកម្មវិធីរ៉េដបូកនៅថ្នាក់មូលដ្ឋាន ស្រុក និង ថ្នាក់ខេត្ត
- ជំរុញ និងលើកទឹកចិត្តសហគមន៍ដើម្បីគាំទ្រ និង អនុវត្តកម្មវិធីរ៉េដបូក
- មានការផ្តួចផ្តើមលើការងារគ្រប់គ្រង និង ការតាមដានសហគមន៍ព្រៃឈើ
- បង្កើតបណ្តាញគណៈកម្មការ៉េដថ្នាក់ឃុំ ស្រុក និង ថ្នាក់ខេត្ត
- លើកទឹកចិត្តឲ្យមានការូលរួមពីសហគមន៍ ក្រុមជនជាតិដើមភាគតិច និង អាជ្ញាធរមូលដ្ឋាន

ខ).តើព័ត៌មានអ្វីខ្លះដែលលោកអ្នកត្រូវការដើម្បីឲ្យមានប្រសិទ្ធិភាពក្នុងដំណើរការអនុវត្តកម្មវិធីរ៉េដបូក?

ចំលើយៈ

- ព៌ត៌មានទាក់ទងទៅនឹងការកាប់បំផ្លាញព្រៃឈើ
- ព៌ត៌មានស្តីពីគ្រោះធម្មជាតិ(ទឹកជំនន់,ខ្យល់ព្យុះ...)
- ព៌ត៌មានផលប្រយោជន៍នៃព្រៃឈើ
- ត្រូវមានការផ្សព្វផ្សាយពត៌មានពីកម្មវិធីរ៉េដបូកតាមវិទ្យុ, ទូរទស្សន៍, ការសែត, ផ្ទាំងរូបភាពតាមផ្លូវ, ទស្សនាវដ្តី និង ឯកសារផ្សេងៗ
- ផ្សព្វផ្សាយតាមរយៈការប្រជុំពិគ្រោះយោបល់ សិក្ខាសាលាថ្នាក់មូលដ្ឋានគ្រប់តំបន់
- ត្រូវការការចូលរួមពីប្រជាពលរដ្ឋពិសេសជនជាតិដើមភាគតិច

គ).តើលោកអ្នកត្រូវការ ការកសាងសមត្ថភាពបែបណាខ្លះ?

ចំលើយៈ

- បើកវគ្គសិក្ខាសាលាស្តីពីកម្មវីធីរ៉េដបូក
- បើកវគ្គបណ្តុះបណ្តាលអោយប្រជាជនបានយល់ដឹងពីច្បាប់ព្រៃឈើ និង ច្បាប់ភូមិបាល
- ត្រូវការការយល់ដឹងពីបច្ចេកទេសវាស់កាបូនក្នុងព្រៃសហគមន៍
- ទស្សនៈកិច្ចសិក្សាទៅកាន់តំបន់ដែលអនុវត្តកម្មវិធីរ៉េដបូកបានជោគជ័យ

២) ប្រទេសកម្ពុជានឹងបង្កើតក្រុមពិគ្រោះយោបល់នឹងក្រុមការងារបច្ចេកទេសរ៉េដបូកថ្នាក់ជាតិ តើលោកអ្នកគួរជ្រើសរើសតំណាងយ៉ាងដូចម្តេចដើម្បីចូលរួមក្នុងក្រុមនេះ?

ចំលើយៈ

- ជ្រើសរើសបេក្ខជនដែលមានសមត្ថភាពតាមរយៈការបោះឆ្នោតមតិភាគច្រើន
- ជ្រើសរើសតាមបណ្តាញសហគមន៍ដែលមានស្រាប់
- ជ្រើសរើសអ្នកដែលហ៊ានលះបង់ពេលវេលាផ្ទាល់ខ្លួន និង មានសីលធម៌
- ជ្រើសរើសអ្នកដែលធ្លាប់មានបទពិសោធន៍ដោះស្រាយបញ្ហាសហគមន៍
- ជ្រើសរើសតំណាងថ្នាក់ខេត្តដែលមានស្រាប់ដើម្បីងាយស្រួលទំនាក់ទំនងជាមួយ អ្នកពាក់ពន្ធ័
- រៀបចំអោយមានរចនាសម្ពន្ធ័គ្រប់គ្រង

៣) តើលោកអ្នកមានអនុសាសន៍ និង សំណូមពរអ្វីខ្លះដើម្បីធានាការចូលរួមរបស់សង្គមស៊ីវិល និង សហគមន៍នៅក្នុងកម្មវិធីរ៉េដបូកនៅកម្ពុជា?

អនុសាសន៍៖

- ទុកដីព្រៃឈើសំរាប់សហគមន៍គ្រប់គ្រងដោយចេរភាព
- គួរតែមានយន្តការបែងចែកផលប្រយោជន៍ពីគម្រោងរ៉េដបូកប្រកបដោយតម្លាភាព
- គួរមានតម្លាភាពក្នុងការគ្រប់គ្រង និង អនុវត្តគម្រោងរ៉េដបូក
- កាត់បន្ថយការផ្តល់ដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនឯកជន
- ត្រូវចែករំលែកដីសម្បទានសេដ្ឋកិច្ចដល់សហគមន៍
- នៅពេលអនុវត្តកម្មវិធីរ៉េដបូកសហគមន៍រៀបចំក្រុមល្បាតអោយបានច្បាស់លាស់ និងម៉ត់ចត់
- ត្រូវមានការពិភាក្សាអោយបានច្បាស់លាស់ជាមួយសហគមន៍មុនពេលសំរេចចិត្តផ្តល់ដីសម្បទានសេដ្ឋកិច្ច។

សំណូមពរ៖

- សូមអោយមានការគាំទ្រខ្ពស់ពីស្ថាបន្ទ័ពាក់ពន្ទ័ក្នុងកម្មវិធីរ៉េដបូក
- បន្តវគ្គបណ្តុះបណ្តាលស្តីពីកម្មវិធីរ៉េដបូក
- សូមអោយរដ្ឋាភិបាលបញ្ឈប់ការផ្តល់ដីសម្បទាន
- សូមអោយរដ្ឋាភិបាលជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋពីផលប្រយោជន៍ព្រៃឈើ

ការលំបាក

នៅកំឡុងពេលសិក្ខាសាលាយើងស្វែងរកឃើញនូវបញ្ហាលំបាកមួយចំនួនមានដូចជា៖

- អ្នកចូលរួមមានកំរិតយល់ដឹងផ្សេងពីគ្នា និងអាយុខុសគ្នា
- អ្នកចូលរួមភាគច្រើនការយល់ដឹងរបស់គាត់នៅមានកំរិត ហើយមានខ្លះមិនអាចអាន និង សរសេរបាន
- ការពន្យល់ខ្លឹមសារសំខាន់ៗមួយចំនួនទាមទារឲ្យមានការប្រើប្រាស់ពាក្យសាមញ្ញ និង ងាយៗ រួមជាមួយការធ្វើបទបង្ហាញ និងការពិភាក្សាក៏ទាមទារឲ្យមានការពន្យល់ជាលក្ខណៈ រូបភាព និងឧទាហរណ៍ផងដែរ។

**មតិបិទកម្មវិធី**

លោក ជី បូរ៉េត នាយកប្រតិបត្តិរបស់អង្គការស៊ីឌីអេបានចូលរួមបិទកម្មវិធីសិក្ខាសាលារយៈពេល០២ថ្ងៃនេះ ដោយថ្លែងអំណរគុណដល់អ្នកចូលរួមដែលជាតំណាង ឲ្យអង្គការសង្គមស៊ីវិល គណៈកម្មការសហគមន៍ និងសមាជិកលើលទ្ធផលជាផ្លែផ្កា នៃអង្គសិក្ខាសាលានេះហើយសង្ឃឹមថានឹងមានកិច្ចសហការ និង ការទំនាក់ទំនងជាបន្តទៅនាពេលខាងមុខ។

ឯកឧត្តម យឹម លុច, អភិបាលរងខេត្តមណ្ឌលគិរី បានសំដែងនូវសេចក្តីសប្បាយរីករាយចំពោះ អ្នកចូលរួមទាំងអស់ដែលបានចំណាយពេលវេលាចូលរួមក្នុងសិក្ខាសាលាដ៍មានសារៈសំខាន់នេះហើយជាពិសេស បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ ស៊ីឌីអេ និង NTFP-EP ដែលបានប្រឹងប្រែងនឹងការសហការយ៉ាងរលូន ជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីកសាងសមត្ថភាព ដល់គណៈកម្មការសហគមន៍ និងអង្គការដៃគូរក្នុងខេត្ត មណ្ឌលគិរី ហើយសង្ឃឹមថាវគ្គសិក្ខាសាលានេះនឹងកើតឡើងម្តងទៀតនៅក្នុងខេត្តមណ្ឌលគិរី។

# រតនៈគិរី



# រតនៈគិរី

សិក្ខាសាលាអប់រំផ្សព្វផ្សាយនេះត្រូវបានរៀបចំឡើងសំរាប់រយៈពេល០២ថ្ងៃគឺចាប់ពីថ្ងៃទី ១៩-២០ ខែមិថុនា ឆ្នាំ២០១២ នៅបរិវេណសណ្ឋាគាររតនៈស៊ីធី ខេត្តរតនៈគិរី។ មានអ្នកចូលរួមសរុបចំនួន៦៥នាក់ ក្នុងនោះស្រីចំនួន ១៤នាក់ ព្រម ទាំងអ្នកតំណាងមកពី៖

- សហគមន៍ជនជាតិដើមភាគតិច
- សហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ
- DPA
- SCW
- AFM
- IRAM
- ICSO
- CANDO
- KCB
- ADV
- IADC
- CIYA

ព្រមទាំងសិស្សានុសិស្សនិស្សិត និងមន្ត្រីមកពីរដ្ឋបាលព្រៃឈើ និងមន្ទីរបរិស្ថានរដ្ឋាភិបាលក៏បានចូលរួមផងដែរ។

## ប្រធានបទសំខាន់ៗ

១) ខ្សែភាពយន្តឯកសារស្តីពីការប្រែប្រួលអាកាសធាតុ និងបទពិសោធន៍REDD

២) បទបង្ហាញស្តីពី និន្នាការអភិវឌ្ឍន៍ និងវិស័យព្រៃឈើនៅកម្ពុជា។ ទំនាក់ទំនងរវាងជនជាតិដើមភាគតិច និងរ៉េដបូក ជាមួយនិងការប្រែប្រួលអាកាសធាតុ ព្រមទាំងការព្រួយបារម្ភចំពោះបញ្ហាពាក់ព័ន្ធនានា។ បទពិសោធន៍រ៉េដបូកនៅខេត្តឧត្តមានជ័យ បញ្ហាបំរែបំរួលអាកាសធាតុពិភពលោកនិងកម្មវិធិថ្នាក់ជាតិ (NAPA)។ ផែនទីបង្ហាញផ្លូវរ៉េដបូកនៅកម្ពុជា និងការចូលរួមរបស់ អង្គការសង្គមស៊ីវិល ក្នុងការអភិវឌ្ឍន៍ផែនទីបង្ហាញផ្លូវរ៉េដបូក។

## កិច្ចពិភាក្សា និង លទ្ធផលសិក្ខាសាលា

ថ្ងៃទី១៖ ១៩ មិថុនា ឆ្នាំ២០១២

ក្រោយពីមតិបើកកម្មវិធីរបស់គណៈអធិបតីរួមមកក្រុមការងារបានបញ្ចាំងភាពយន្តឯកសារស្តីពីការប្រែប្រួល អាកាសធាតុដែលផលិតដោយក្រសួងបរិស្ថានដែលមានរយៈពេល១៥នាទី។ ប្រធានបទបន្តគឺជាបទបង្ហាញរបស់លោក ឆឹង ស៊ីរីយ៉ា ស្តីពីនិន្នាការអភិវឌ្ឍន៍នៅកម្ពុជា ដែលផ្តោតជាសំខាន់ទៅលើសកម្មភាពអភិវឌ្ឍន៍ដែលធ្វើអោយមានផលប៉ះពាល់ដល់ធនធានធម្មជាតិ។

សំនួរ និង យោបល់ចូលរួមសំខាន់ៗមួយចំនួនលើប្រធានបទនេះមានដូចខាងក្រោម៖

១)តើមានផលប៉ះពាល់ជាវិជ្ជមាន និង អវិជ្ជមានអ្វីខ្លះដែលបណ្តាលមកពីនិន្នារការអភិវឌ្ឍន៍ នៅក្នុងប្រទេសកម្ពុជា? តើមានកត្តាសំខាន់ៗអ្វីខ្លះដែលបណ្តាលឲ្យមានការបាត់បង់គម្រប ព្រៃឈើ?

ចំលើយ៖
ផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីនិន្នាការអភិវឌ្ឍន៍រួមមាន៖ ការបាត់បង់ប្រភពទឹកសំរាប់ប្រើប្រាស់, ការបំពុលបរិស្ថាន, ការប្រែប្រួលអាកាសធាតុ ដែលបណ្តាលឲ្យមានផលប៉ះពាល់ដល់ប្រជាជន និងសន្តិសុខ ស្បៀង។ ចំណែកផលប៉ះពាល់ ជាវិជ្ជមានរួមមាន៖ ជួយបង្កើនសេដ្ឋកិច្ចផលទុនក្នុងស្រុកសរុប និងប្រាក់ចំណូលសេដ្ឋកិច្ច របស់រាជរដ្ឋាភិបាល, ហេដ្ឋារចនាសម្ពន្ធ័ និងសេវាសាធារណៈតាមរយៈការផ្តល់ដីសម្បទាន សេដ្ឋកិច្ច សម្បទានរុករករ៉ែ។ ការបាត់បង់គម្របព្រៃឈើបណ្តាលមកពីសកម្មភាពផ្សេងៗ ហើយការចាប់យក និងទន្ទ្រានដីព្រៃក៏ជាសកម្មភាពមួយនៅក្នុងសកម្មភាពល្មើស ទាំងនេះផងដែរ។ សកម្មភាពអស់នេះបានកើតឡើងទាំងនៅខាងក្នុង និង ខាង ក្រៅតំបន់ព្រៃឈើទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ ឫជនជាតិបរទេស/អន្តរជាតិ។

ប្រធានបទបន្តលោក ណាក់ វ៉េន, បានធ្វើបទបង្ហាញស្តីពីទំនាក់ទំនងរបស់ជនជាតិដើមភាគតិច ទៅនឹងកម្មវិធីរ៉េដបូកការប្រែប្រួលអាកាសធាតុ និង ការព្រួយបារម្ភរបស់ពួកគេ។

សំនួរចំលើយទាក់ទងទៅនឹងប្រធានបទនេះ រួមមានដូចខាងក្រោម៖

១)តើក្រុមជនជាតិដើមភាគតិចត្រូវចូលរួមក្នុងគម្រោងរ៉េដបូកយ៉ាងដូចម្តេច? ហើយតើការចូលរួមនោះមានគោលបំណងបែបណាខ្លះ? តើយើងត្រូវរួមបញ្ចូល ការព្រួយបារម្ភអំពីយ៉ែនឌ័រទៅក្នុងកម្មវិធីរ៉េដបូកយ៉ាងដូចម្តេចខ្លះ?

ចំលើយ៖
ក្រុមជនជាតិដើមភាគតិចគឺជាអ្នកដែលងាយរងគ្រោះបំផុត និងជាក្រុមដែល ទទួលបានអត្ថប្រយោជន៍ តិចជាងគេនៅក្នុងពិភពលោក។ មានការលើកឡើងផ្សេងៗគ្នា នៅថ្នាក់ជាតិ និង អន្តរជាតិទាំងអង្គការជាតិ និងអង្គការអន្តរជាតិស្តី

ពីសកម្មភាពផ្សព្វផ្សាយ គាំទ្រ និង លើកទឹកចិត្តឲ្យមានការចូលរួមរបស់ក្រុមជនជាតិភាគតិចជាមួយគម្រោងរ៉េដបូក។ ជាឧទាហរណ៍៖ ការកំណត់អ្នកដែលចូលរួម ការកំណត់តួនាទីនិងការទទួលខុសត្រូវ ការបង្កើតឡើងនូវរចនាសម្ព័ន្ធកម្មវិធី និងការរួមបញ្ចូលនូវទស្សនៈទាន កំណត់ត្រា សំណើរសុំ និងផែនការស្តីពីយៃនឌ័រ។ការអនុវត្តគំរោង និងសកម្មភាពពាក់ព័ន្ធផ្សេងៗគឺអាចធ្វើបាន ដោយមានការពិចារណានូវយៃនឌ័រភ្ជាប់ជាមួយ។
កម្មវិធីបន្ទាប់គឺការបង្ហាញខ្សែវីដេអូពីបទពិសោធន៍អនុវត្តកម្មវិធីរ៉េដបូកនៅខេត្តឧត្តរមានជ័យ និង បទបង្ហាញ ពីការងារអនុវត្តកម្មវិធីរ៉េដរបស់អង្គការស៊ីឌីអេ ដោយលោក ជី បូរ៉េត នាយកប្រតិបត្តិអង្គការ ស៊ីឌីអេ។

សំនួរចំលើយ សំខាន់ៗលើប្រធានបទនេះរួមមាន៖

១) តើផលប្រយោជន៍នៃការរំពឹងទុកពីគម្រោងរ៉េដបូកក្នុងខេត្តឧត្តរមានជ័យជាអ្វី?

ចំលើយ៖
គម្រោងបានជួយគាំទ្រដល់ការគ្រប់គ្រង ព្រៃឈើប្រកបដោយនិរន្តភាព និងការអភិវឌ្ឍន៍ការចិញ្ចឹមជីវិតនៅក្នុងខេត្តឧត្តរមានជ័យដោយការផ្តល់នូវហិរញ្ញវត្ថុតាមរយៈការផ្តល់នូវមូលនិធិឥណទានការបូនពីការការពារព្រៃឈើនិងការដាំព្រៃឡើងវិញ។ គម្រោងមិនត្រឹមតែជួយដល់ប្រជាជនឲ្យទទួលបានសិទ្ធិកាន់កាប់ស្របច្បាប់លើដីព្រៃ មូលដ្ឋានប៉ុណ្ណោះទេផ្ទុយទៅវិញវាបានជួយធ្វើឲ្យមានចរន្តប្រាក់ចំណូលរយៈពេល៣០ឆ្នាំខាងមុខទៀតដែលនឹង ជួយធ្វើឲ្យប្រសើរឡើងនូវការចិញ្ចឹមជីវិតជាលក្ខណៈគ្រួសារ និងសមត្ថភាព នៃការគ្រប់គ្រងធនធានធម្មជាតិ។ គំរោង រ៉េដបូកបានជួយថែរក្សា និងបង្កើននូវកាបូនស្តុក នៅក្នុងតំបន់នេះតាមរយៈការធ្វើឲ្យប្រសើរឡើងនូវជលសាស្ត្រនៃ ទីជំរាលតំបន់ខ្ពង់រាបនៃអាងទន្លេសាប រួមនឹងការអភិរក្សជីវៈចំរុះ និងប្រភេទងាយរងគ្រោះផងដែរ។ ឥណទានកាបូននឹងត្រូវប្រើប្រាស់ដើម្បីគាំទ្រសហគមន៍ជនបទក្នុងការអភិវឌ្ឍន៍កំរិតជីវភាពរស់នៅរួមមានសកម្មភាពសហគ្រាសអនុផលព្រៃឈើ ហេដ្ឋារចនាសម្ពន្ធ័សហគមន៍អេកូទេសចរណ៍ និងការ អភិវឌ្ឍន៍ធនធានទឹក។ គម្រោងក៏បានធ្វើការជាមួយខណ្ឌរដ្ឋបាលព្រៃឈើ និង អាជ្ញាធរមូលដ្ឋានៈឃុំ ស្រុក ខេត្តដើម្បីបង្កើតនូវផែនការរយៈពេលវែងសំរាប់ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ក្នុងគោលបំណងដើម្បីលើកកំពស់ការអភិវឌ្ឍន៍ក្នុង តំបន់។

លោក ស្មៀន បុរីរត្ន័, នាយករងអង្គការ ស៊ីឌីអេ បានធ្វើបទបង្ហាញស្តីពីការចូលរួម របស់អង្គការសង្គមស៊ីវិល លើកម្មវិធីរ៉េដបូកហើយគាត់ក៏បានបង្ហាញ ពីយុទ្ធសាស្ត្ររបស់ គម្រោងណាប៉ាផងដែរ។

យោបល់ចូលរួម និងសំនួរ ចំលើយលើប្រធាននេះរួមមាន៖

១) ហេតុអ្វីចាំបាច់ឲ្យមានពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងការចូលរួម របស់អង្គការសង្គមស៊ីវិលលើគម្រោងរ៉េដបូក? តើនរណាជាអ្នកចូលរួមផ្តល់មូលនិធិលើកា រចូលរួមនេះ?

ចំលើយ៖
មានកត្តាសំខាន់ៗបីនៅក្នុងការអភិវឌ្ឍន៍ប្រទេសមួយរួមមានៈ រដ្ឋាភិបាល, វិស័យឯកជន និងអង្គការ សង្គមស៊ីវិល។ អង្គការសង្គមស៊ីវិលមានតួនាទី និងការទទួលខុសត្រូវលើការចូលរួមក្នុងសង្គម, គោលនយោបាយ ការអភិវឌ្ឍន៍

បរិស្ថាន និងសេដ្ឋកិច្ច និង ផ្តល់នូវការគាំទ្រដល់ក្រុមដែលងាយរងគ្រោះ និង ក្រុមបាត់បង់ផលប្រយោ ជន៍រួមមានការលើកកំពស់សិទ្ធិមនុស្ស, ភាពស្វ័យម្ចាស់ការលើដំណើរការអភិវឌ្ឍន៍ និង ដំណើរអភិវឌ្ឍន៍ប្រជាធិបតេយ្យទូទៅ។ ជាពិសេសជាងនេះទៅទៀតសិក្ខាសាលា ផ្សព្វផ្សាយគម្រោងរ៉េដបូកនេះមានគោលបំណងផ្សព្វផ្សាយចំណេះដឹងលើទស្សនៈទាន នៃរ៉េដបូក ដោយរួមបញ្ចូលនូវការពិភាក្សាផ្លាស់ប្តូរយោបល់លើការព្រួយបារម្ភ សំនើសុំ និងអនុសាសន៍ដើម្បីផ្ញើរជូនទៅរដ្ឋាភិបាលក្នុងគោលបំណងដើម្បីឲ្យមានការទទួលខុសត្រូវលើសេចក្តីត្រូវការរបស់ សហគមន៍ និង ក្រុមជនជាតិដើមភាគតិច តាមរយៈការរៀបចំ ជាគោលការណ៍ណែនាំច្បាប់ និង គោលនយោបាយផ្សេងៗតាមរយៈដំណើរការ អនុវត្តផែនទីបង្ហាញផ្លូវរ៉េដបូក។ ការពិតយើងមិនទាន់បានទទួលមូលនិធិគាំទ្រពីរដ្ឋាភិ បាលនៅឡើយទេលើដំណើរការផ្សារភ្ជាប់ការចូលរួមរបស់អង្គការសង្គមស៊ីវិលទៅក្នុងកម្មវិធីរ៉េដបូក ប៉ុន្តែយើង ទទួលបាននូវមូលនិធិពីម្ចាស់ជំនួយមួយចំនួនរួមមាន៖ World Bank, UN Family, NTFP-EP, Oxfam-GB, EU ដៃគូរផ្តល់ជំនួយផ្សេងៗទៀតដែលបានចូលរួមចំណែក ជាមួយពួកយើងដើម្បីចូលរួមសកម្មភាពក្នុងដំណើរការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។

ថ្ងៃទី២៖ ២០ មិថុនា ឆ្នាំ២០១២

អ្នកចូលរួមទាំងអស់ត្រូវបានបែងចែកជា៣ក្រុមដើម្បីពិភាក្សាទៅលើសំនួរសំខាន់ៗ៣ខាងលើ លទ្ធផលនៃការពិភាក្សាក្រុមមានដូចខាងក្រោម៖

១) ផែនទីបង្ហាញផ្លូវនៃយុទ្ធសាស្រ្តរ៉េដបូកថ្នាក់ជាតិៈ

ក).តើលោកអ្នកនឹងចូលរួមរៀបចំដូចម្តេច?

ចំលើយ៖

- គួរតែរៀបចំសិក្ខាសាលាផ្សព្វផ្សាយកម្មវិធីរ៉េដបូកនៅថ្នាក់ជាតិ
- ផ្សព្វផ្សាយបន្តនូវទស្សនៈទានរ៉េដបូកនៅគ្រប់ខេត្តទូទាំងប្រទេស
- ផ្សព្វផ្សាយគម្រោងរ៉េដបូកនូវថ្នាក់តំបន់
- ផ្សព្វផ្សាយគម្រោងរ៉េដបូកដល់សហគមន៍មូលដ្ឋាន
- បង្កើតនូវបណ្តាញរ៉េដបូកថ្នាក់មូលដ្ឋាន, ក្រោមជាតិ និងថ្នាក់ជាតិ
- ចូលរួមក្នុងការរៀចចំសិក្ខាសាលា
- ធ្វើការពង្រឹងដល់ក្រុមយុវជន សហគមន៍ និង ក្រុមជនជាតិដើមភាគតិច
- ជ្រើសរើសតំណាងសហគមន៍ដែលមានសមត្ថភាពនិង ជំនាញដើម្បីចូលរួម ទៅក្នុងផែនទីបង្ហាញផ្លូវរ៉េដបូក
- ចងក្រងបណ្តាញយុវជន, ក្រុមជនជាតិដើមភាគតិច, អង្គការសង្គមស៊ីវិល និង សហគមន៍
- រៀបចំក្រុមសិក្សាស្រាវជ្រាវស្តីពីសក្តានុពលក្នុងតំបន់ផ្សេងៗ
- រៀបចំកិច្ចប្រជុំឆ្លុះបញ្ចាំង និងចែករំលែកលទ្ធផលនៃការសិក្សាស្រាវជ្រាវ ជាមួយអ្នកពាក់ពន្ធ័សំខាន់ៗ
- ជ្រើសរើសតំណាងជនជាតិដើមភាគតិចយ៉ាងហោចណាស់៣នាក់រៀបចំសហគមន៍នៅថ្នាក់ខេត្ត និង ថ្នាក់ ជាតិ។
- បង្កើតនូវលក្ខណៈវិនិច្ឆ័យកំណត់នូវបុគ្គលដើម្បីចូលរួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងថ្នាក់ជាតិ
- បង្កើតនូវលក្ខណៈវិនិច្ឆ័យដែលអាចជួយកំណត់នូវតំរូវការក្នុងមូលដ្ឋាន

ខ ).តើព័ត៌មានអ្វីខ្លះដែលលោកអ្នកត្រូវការដើម្បីឲ្យមានប្រសិទ្ធិភាពក្នុងដំណើរការអនុវត្តកម្មវិធី រ៉េដបូក ?

ចំលើយ៖

- ផ្សព្វផ្សាយផែនការរ៉េដបូក
- បង្កើតនូវផែនការច្បាស់លាស់ និងរៀបចំឯកសារផ្សព្វផ្សាយពីគម្រោងរ៉េដបូក
- គោលនយោបាយរ៉េដបូកត្រូវតែមានផែនការយុទ្ធសាស្ត្រច្បាស់លាស់
- ត្រូវមានយន្តការបែងចែកផលប្រយោជន៍ឲ្យបានច្បាស់លាស់
- គួរមានវិភាគឲ្យបានច្បាស់លាស់ពីគុណសម្បត្តិ និង គុណវិបត្តិនៃគម្រោងរ៉េដបូក
- គួរមានសកម្មភាពយៀនឪរនៅក្នុងគម្រោងរ៉េដបូក
- បង្កើតនូវបណ្តាញយុវជនរ៉េដបូក
- ឯកសារផែនទីបង្ហាញផ្លូវរ៉េដបូកគួរតែមានជាភាសារខ្មែរដែលអាចស្វែងរកបានគ្រប់ទី កន្លែងសាធារណៈ
- ផ្សព្វផ្សាយពីសក្កានុពលនៃការអនុវត្តគម្រោងរ៉េដបូកសាកល្បងដល់សហគមន៍ និងអ្នកពាក់ពន្ធ័
- សហគមន៍ និងអ្នកពាក់ពន្ធ័ទាំងអស់ត្រូវតែចូលរួមគ្រប់ដំណើរការនៃការអនុវត្តកម្មវិធី រ៉េដបូក
- ត្រូវមានការផ្សព្វផ្សាយឲ្យបានទូលំទូលាយនូវ ទស្សនៈវិស័យ បេសកកម្ម គោលដៅ និង ផែនការយុទ្ធសាស្ត្ររបស់គម្រោងរ៉េដទៅគ្រប់ស្ថាបន័ អ្នកពាក់ពន្ធ័ទាំងអស់ ជាពិសេសសហគមន៍ដែលរស់នៅក្បែរ និង ក្នុង ព្រៃសហគមន៍។
- ត្រូវមានតម្លាភាព និង គណនេយ្យភាពលើការគ្រប់គ្រងប្រពន្ធ័ហិរញ្ញវត្ថុ
- ផែនការសកម្មភាព និងផែនការថវិកាត្រូវរៀបចំ ឲ្យបានសមស្របជាមួយ ផែនការសហគមន៍
- ច្បាប់ព្រៃឈើ
- រៀបចំវេទិកាផ្លាស់ប្តូរបទពិសោធន៍ស្តីពីទស្សនៈទាននៃការគ្រប់គ្រងធនធានធម្មជាតិ
- ការកាប់បំផ្លាញព្រៃឈើដោយសកម្មភាពទន្រ្ទានដីខុសច្បាប់
- បង្កើតនូវព៌ត័មានសហគមន៍ដើម្បីផ្តល់ព៌ត័មានសកម្មភាពទន្រ្ទានដីខុសច្បាប់ និង បញ្ហាប្រឈមផ្សេងៗនៃព្រៃឈើ។

គ ).តើលោកអ្នកត្រូវការ ការកសាងសមត្ថភាពបែបណាខ្លះ ?

ចំលើយ៖

- បន្តគាំទ្រការកសាងសមត្ថភាពដល់បណ្តាញយុវជនលើកម្មវិធីរ៉េដបូក
- សិក្សារៀនសូត្របន្ថែមពីគម្រោងរ៉េដបូក
- សិក្សារៀនសូត្រពី GIS និង GPS ដើម្បីផលិតផែនទីសហគមន៍
- សិក្សារៀនសូត្រពីកាបូន និងការវាស់វែងកាបូក
- សិក្សារៀនសូត្រពីរបៀបធ្វើសារពើភណ្ឌ័ព្រៃឈើ
- ផ្តល់សិទ្ធិឲ្យក្រុមជនជាតិដើមភាគតិចដើម្បីគ្រប់គ្រងព្រៃឈើ និងការអនុវត្តរ៉េដបូក
- ផែនការយុទ្ធសាស្ត្ររ៉េដបូកគួរតែត្រូវអនុវត្តនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ
- ត្រូវមានជំនាញគ្រប់គ្រង និង ភាពជាអ្នកដឹកនាំ

- ទំនាក់ទំនង
- ការសម្របសម្រួល
- ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ក្នុង និងក្រៅប្រទេសស្តីពីគម្រោងរ៉េដបូក
- បង្កើតនូវផែនការយុទ្ធសាស្ត្រ
- កែលំអរជីវភាពចិញ្ចឹមជីវិត
- ជំនាញផ្សព្វផ្សាយ
- ជំនាញគ្រប់គ្រងហិរញ្ញវត្ថុ
- ជំនាញគោលនយោបាយព្រៃឈើជាតិ
- គម្រោងរ៉េដបូកត្រូវតែបញ្ចូលទៅក្នុងកម្មវិធីសិក្សា
- ត្រូវមានការបកប្រែឯកសារគម្រោងរ៉េដបូកជាភាសាខ្មែរស្របតាមចំណោះដឹងមូលដ្ឋាន
- ផ្សព្វផ្សាយគម្រោងរ៉េដបូកឲ្យបានទូលំទូលាយដល់សហគមន៍
- ផ្តល់សិទ្ធិឲ្យសហគមន៍បញ្ចេញមតិ យោបល់ និង ទទួលយកយោបល់ពីសហគមន៍ ជាពិសេសលើកទឹកចិត្ត ឲ្យមានការចូលរួមពីស្ត្រី និងបង្កើននូវចំណោះដឹងរបស់ពួកគេ។

២) ប្រទេសកម្ពុជានឹងបង្កើតក្រុមពិគ្រោះយោបល់នឹងក្រុមការងារបច្ចេកទេសរ៉េដបូកថ្នាក់ជាតិ តើលោកអ្នកគួរជ្រើសរើសតំណាងយ៉ាងដូចម្តេចដើម្បីចូលរួមក្នុងក្រុមនេះ?

ចំលើយ៖

- ជ្រើសរើសបេក្ខជនតំណាងប្រជាជនដែលមានបទពិសោធន៍ ចំណោះដឹង និងជំនាញរ៉េដបូក និងការគ្រប់ គ្រងធនធានធម្មជាតិនៅថ្នាក់ភូមិ ឃុំ ស្រុក និង ខេត្ត។
- តំណាងសហគមន៍ត្រូវតែចូលរួមក្នុងដំណើរការកម្មវិធីរ៉េដបូក
- ត្រូវមានគណនេយ្យភាពនៅក្នុងយន្តការបែងចែកផលប្រយោជន៍
- ផ្តល់នូវសិទ្ធិ និងសេរីភាពដល់ក្រុមជនជាតិដើមភាគតិចស្តីពីការប្រើប្រាស់ និងដកហូតបែបប្រពៃណីលើការគ្រប់គ្រងព្រៃឈើ។
- ត្រូវមានការកំណត់លក្ខណៈវិនិច្ឆ័យឲ្យបានល្អជាពិសេសមនុស្សដែលមានការ ទំនាក់ទំនងល្អជាលក្ខណៈបុគ្គលនៅក្នុងតំបន់ និងសហគមន៍របស់ពួកគេ។
- គួរតែជ្រើសរើសតំណាងពីថ្នាក់ក្រោមពីថ្នាក់ ភូមិ ឃុំ ស្រុក និងថ្នាក់ជាតិ
- ជ្រើសរើសតំណាងដើម្បីចូលរួមរៀបចំរចនាសម្ពន្ធ័រ៉េដបូក

៣) តើលោកអ្នកមានអនុសាសន៍ និង សំណូមពរអ្វីខ្លះដើម្បីធានាការចូលរួមរបស់សង្គមស៊ីវិល និង សហគមន៍នៅក្នុងកម្មវិធីរ៉េដបូកនៅកម្ពុជា?

អនុសាសន៍៖

- រដ្ឋាភិបាលគួរតែបង្កើតគោលនយោបាយថ្នាក់ជាតិឲ្យបានច្បាស់លាស់លើកម្មវិធីរ៉េដបូក
- ផ្តល់ព័ត៌មានទៅអង្គការសង្គមស៊ីវិល និង សហគមន៍

- អប់រំផលប៉ះពាល់ពីគម្រោងរ៉េដបូក
- ផ្តល់នូវការគាំទ្របច្ចេកទេសលើសកម្មភាពលើកំពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន
- ផ្តល់នូវឥណទានការបូនទៅសហគមន៍ដើម្បីការពារព្រៃឈើ
- សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលគួរតែមានភាពស្វ័យគ្រប់គ្រងលើគម្រោងរ៉េដបូក
- គួរតែមានការកសាងសមត្ថភាពទាក់ទងនឹងគម្រោងរ៉េដបូក
- រដ្ឋាភិបាលគួរតែគាំទ្រគ្រប់សកម្មភាពទាំងអស់របស់សហគមន៍មូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល មានដូចជាការរៀបចំបណ្តាញ។
- គម្រោងរ៉េដបូកគួរតែអនុវត្តនៅតំបន់ ឬ សហគមន៍ណាដែលមានព្រៃឈើ
- គួរតែមានសកម្មភាពគាំទ្រមុខរបរដល់សហគមន៍មូលដ្ឋានដែលរស់នៅក្បែរ ឬក្នុងតំបន់ព្រៃឈើ

សំណូមពរៈ

- ស្នើរសុំឲ្យមានការគោរពសិទ្ធិជនជាតិដើមភាគតិច

យោបល់ទូទៅ និងអនុសាសន៍

- គួរមានតំនាងសង្គមស៊ីវិលចូលរួមក្នុងគម្រោងរ៉េដបូកដើម្បីចូលរួមអនុវត្ត ធ្វើការសំរេចចិត្ត និង ការ កសាងសមត្ថភាពជាមួយស្ថាបន័រដ្ឋាភិបាល លើកម្មវិធីរ៉េដបូកចាប់ផ្តើមពីការវាយតម្លៃជាមូលដ្ឋាន ដំណើរ ការអនុវត្ត និងការត្រួតពិនិត្យវាយតម្លៃ។
- គួរផ្តល់នូវការកសាងសមត្ថភាពលើបច្ចេកទេសកសិកម្មដើម្បីបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយនូវភាពរងគ្រោះរបស់ពួកគេ។
- គួរផ្តល់នូវផ្ទៃដីព្រៃឈើមួយចំនួនធំទៅសហគមន៍តាមរយៈសហគមន៍ជនជាតិដើមភាគតិច សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ...។ល។ នឹងការដោះស្រាយនូវបញ្ហាមួយចំនួនលើការចុះ បញ្ជីដីសហគមន៍ដើម្បីឆ្ពោះទៅ ការរៀបចំគោលនយោបាយរ៉េដបូកដើម្បីការពារពីតំបន់ដែលមានការលេចធ្លាយ។
- ត្រូវមានការគោរពប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស និងភាពស្វ័យម្ចាស់ការ ក្នុងដំណើរការអភិវឌ្ឍន៍កម្មវិធីរ៉េដបូកក្នុងប្រទេសកម្ពុជា។
- ត្រូវមានការធានានូវការចូលរួមពេញលេញរបស់អង្គការសង្គមស៊ីវិលក្នុងកម្មវិធីUN-REDD និងដំណើរ ការផែនទីបង្ហាញផ្លូវរ៉េដបូកតាមរយៈការគោរព លទ្ធិប្រជាធិបតេយ្យ។

- យន្តការបែងចែកផលប្រយោជន៍ដែលទទួលបានកាបូនស្តុកនៃព្រៃឈើគួរតែផ្តល់ឲ្យជាអតិបរិមារដល់សហគមន៍មូលដ្ឋានរួមទាំងផលប្រយោជន៍សេដ្ឋកិច្ចផងដែរ។

ការលំបាក

នៅកំឡុងពេលសិក្ខាសាលាយើងស្វែងរកឃើញនូវបញ្ហាលំបាកមួយចំនួនមានដូចជាៈ

- អ្នកចូលរួមមានកំរិតយល់ដឹងផ្សេងពីគ្នា និងអាយុខុសគ្នា
- អ្នកចូលរួមភាគច្រើនការយល់ដឹងរបស់គាត់នៅមានកំរិត ហើយមានខ្លះមិនអាចអាន និង សរសេរបាន

- ការពន្យល់ខ្លឹមសារសំខាន់ៗមួយចំនួនទាមទារឲ្យមានការប្រើប្រាស់ពាក្យសាមញ្ញ និង ងាយៗរួមជាមួយ ការធ្វើបទបង្ហាញ និងការពិភាក្សាក៏ទាមទារ ឲ្យមានការពន្យល់ជា លក្ខណៈរូបភាព និងឧទាហរណ៍ ផងដែរ។

**មតិបិទកម្មវិធី**

លោក ជី បូរ៉េត នាយកប្រតិបត្តិរបស់អង្គការស៊ីឌីអេបានចូលរួមបិទកម្មវិធីសិក្ខាសាលារយៈពេល០២ថ្ងៃនេះ ដោយថ្លែងអំណរគុណដល់អ្នកចូលរួមដែលជាតំណាង ឲ្យអង្គការសង្គមស៊ីវិល គណៈកម្មការសហគមន៍ និងសមាជិកលើលទ្ធផលជាផ្លែផ្កា នៃអង្គសិក្ខាសាលានេះហើយសង្ឃឹមថានឹងមានកិច្ចសហការ និង ការទំនាក់ទំនងជាបន្តទៅនាពេលខាងមុខ។

បន្ទាប់មកទៀតលោក ឡុង សេរី, នាយកប្រតិបត្តិអង្គការ NTFP បានសំដែងនូវសេចក្តី សប្បាយរីករាយចំពោះអ្នកចូលរួមទាំងអស់ដែលបានចំណាយពេលវេលា ចូលរួមក្នុង សិក្ខាសាលាដ៏មានសារៈសំខាន់នេះ ហើយជាពិសេសបានថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅចំពោះអង្គការ CDA និង NTFP-EP ដែលបានប្រឹងប្រែងនឹងការសហការយ៉ាងរលូនជាមួយអង្គការដៃគូរក្នុងខេត្តរតនៈគិរី ហើយសង្ឃឹមថាវគ្គសិក្ខាសាលានេះនឹងកើតឡើងម្តងទៀតនៅក្នុងខេត្តរតនៈគិរី។

# ស្ទឹងត្រែង



# ស្ទឹងត្រែង

សិក្ខាសាលាអប់រំផ្សព្វផ្សាយនេះត្រូវបានរៀបចំឡើងសំរាប់រយៈពេល០២ថ្ងៃគឺចាប់ពីថ្ងៃទី ២១-២២ ខែមិថុនា ឆ្នាំ២០១២ នៅបរិវេណសណ្ឋាគារសេកុងស្តារ ខេត្តស្ទឹងត្រែង។ មានអ្នកចូលរួមសរុបចំនួន ៦៦នាក់ក្នុងនោះស្រីចំនួន ១០នាក់។ ក្នុងនោះផងដែរក៏មានអ្នកតំណាងមកពីសហគមន៍ព្រៃឈើ បងប្អូនជនជាតិដើមភាគតិច និងអង្គការដៃគូរមួយចំនួនមួសង្គមស៊ីវិលមួយចំនួនដូចជា មូប់បៃតង ព្រហ្មវិហាធម៌ និងសមាគមន៍ថែរក្សាបរិស្ថាន និងវប្បធម៌ ព្រមទាំងមន្ត្រីមកពីមន្ទីរបរិស្ថានខេត្តផងដែរ។ រដ្ឋាភិបាលក៏បានចូលរួមផងដែរ។

ប្រធានបទសំខាន់ៗ

១) ខ្សែភាពយន្តឯកសារស្តីពីការប្រែប្រួលអាកាសធាតុ និងបទពិសោធន៍REDD
២) បទបង្ហាញស្តីពី និន្នាការអភិវឌ្ឍន៍ និងវិស័យព្រៃឈើនៅកម្ពុជា។ ទំនាក់ទំនងរវាងជនជាតិដើមភាគតិច និងរ៉េដបូក ជាមួយនិងការប្រែប្រួលអាកាសធាតុ ព្រមទាំងការព្រួយបារម្ភចំពោះបញ្ហាពាក់ព័ន្ធនានា។ បទពិសោធន៍រ៉េដបូកនៅខេត្តឧត្តមានជ័យ បញ្ហាបំរែបំរួលអាកាសធាតុពិភពលោក និងកម្មវិធិថ្នាក់ជាតិ(NAPA)។ ផែនទីបង្ហាញផ្លូវរ៉េដបូកនៅកម្ពុជា និងការចូលរួមរបស់ អង្គការសង្គមស៊ីវិល ក្នុងការអភិវឌ្ឍន៍ផែនទីបង្ហាញផ្លូវរ៉េដបូក។

**កិច្ចពិភាក្សា និង លទ្ធផលសិក្ខាសាលា**

ថ្ងៃទី១៖ ២១ មិថុនា ឆ្នាំ២០១២

ក្រោយពីមតិបើកកម្មវិធីរបស់គណៈអធិបតីរួចមក ក្រុមការងារបានបញ្ចាំងភាពយន្តឯកសារ ស្តីពីការប្រែប្រួលអាកាសធាតុដែលផលិតដោយក្រសួងបរិស្ថាន។ បន្ទាប់មកអ្នកចូលរួមទាំងអស់មានសំនួរដូចខាងក្រោម៖

១)តើការប្រែប្រួលអាកាសធាតុបណ្តាលមកពីកត្តាអ្វីខ្លះ? តើអ្វីទៅជាឧស្ម័នផ្ទះកញ្ចក់?

ចំលើយ៖
ការប្រែប្រួលអាកាសធាតុគឺបណ្តាលមកពីការបាត់បង់ព្រៃឈើ និងការអភិវឌ្ឍន៍ ដោយមិនបានគិតពីនិរន្តរភាពនៃធនធានបរិស្ថាន។ ការកាប់បំផ្លាញព្រៃឈើគឺ អាចមើលឃើញតាមរយៈការអភិវឌ្ឍន៍ ដែលមិនបានយកចិត្តទុកដាក់ទៅលើចេរភាព នៃធនធានធម្មជាតិ និងបរិស្ថាន ហើយបណ្តាលមកការការអភិវឌ្ឍន៍ ដែលគ្រប់គ្រងដោយទីផ្សារការរីកចំរើននូវបច្ចេកវិជ្ជា និងការកើនឡើងនូវចំនួនប្រជាជន។ ឧស្ម័នផ្ទះកញ្ចក់គឺជាផ្សែងពុលក្នុងផែនដីដែលភាយចេញពីផ្ទៃផែនដីទៅក្នុងបរិយាសកាស។ ស្រទាប់អូហ្សូន និងឧស្ម័នផ្ទះកញ្ចក់គឺផ្ទុយស្រឡះពីគ្នា។ ស្រទាប់អូហ្សូនដើតួនាទីជាស្រទាប់ការពារ ប្រៀបបានទៅនិងដំបូលផ្ទះដែលកំពុងតែស្តើង ដូច្នេះហើយ ទើបធ្វើអោយឧស្ម័នពុលទាំងឡាយអាចជ្រៀបចូលទៅក្នុងស្រទាប់បរិយាកាស។ជាលទ្ធផលគឺធ្វើអោយគំរូអាកាសធាតុមានការផ្លាស់ប្តូរខុសពីមុន។

២) តើនរណាជាអ្នកកំណត់យន្តការការកាត់បន្ថយ និង ការបន្សាំនៅក្នុងសកម្មភាព ការប្រែប្រួលអាកាសធាតុ?

ចំលើយ៖
អ្នកដែលកំណត់យន្តការនៃការបន្សាំ និង ការការកាត់បន្ថយការប្រែប្រួល អាកាសធាតុគឺ បណ្តាប្រទេសដែលជាម្ចាស់ហត្ថលេខីនៃអនុសញ្ញាក្របខណ្ឌ អង្គការសហប្រជាជាតិ និង ពិធីសារក្យូតូ ប៉ុន្តែយន្តការនេះមិនត្រូវបានអនុវត្តគ្រប់បណ្តាប្រទេសហត្ថលេខីទាំងអស់នៅឡើយទេ។

៣) តើអ្វីទៅជាសកម្មភាពបន្សាំនៅក្នុងវិស័យកសិកម្ម?

ចំលើយ៖
ដូចជាការបង្ហាញក្នុងខ្សែវីដេអូអំបាញ់មិញចំពោះវិស័យកសិកម្មគេត្រូវមានការរៀបចំ យុទ្ធសាស្ត្រ លើសកម្មភាពនៃការប្រែប្រួលអាកាសធាតុ ដូចជា៖ ការរៀបចំគ្រាប់ពូជសំរាប់ដាំដុះ ការរៀបចំប្រពន្ធ័ធារាសាស្ត្រ និង ការបណ្តុះបណ្តាលលើសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ។ ឧទាហរណ៍ៈ ទំលាប់នៃការដាំដុះគ្រាប់ពូជ រយៈពេល០៦ខែ អាចពិចារណាជ្រើសរើសរយៈពេល ០៣ខែ ជំនួសវិញផ្អែកលើកត្តាធនធានធម្មជាតិ។

ប្រធានបទបន្តគឺជាបទបង្ហាញរបស់លោក ឆឹង ស៊ីរីយ៉ា ស្តីពីនិន្នាការអភិវឌ្ឍន៍នៅ កម្ពុជាដែលផ្តោតជាសំខាន់ទៅលើសកម្មភាពអភិវឌ្ឍន៍ដែល ធ្វើអោយមានផលប៉ះពាល់ដល់ ធនធានធម្មជាតិ។

សំនួរ និង យោបល់ចូលរួមសំខាន់ៗមួយចំនួនលើប្រធានបទនេះមានដូចខាងក្រោម៖

១) មុននឹងសំរេចផ្តល់គម្រោងអភិវឌ្ឍន៍ទៅដល់ក្រុមហ៊ុនឯកជន តើរដ្ឋាភិបាលបានកំណត់នូវ ជំហានសំខាន់ៗអ្វីខ្លះដើម្បីធ្វើជាលក្ខណៈវិនិច្ឆ័យ?

ចំលើយ៖
តាមគោលការណ៍មុននឹងសំរេចផ្តល់ដីសម្បទានទៅក្រុមហ៊ុនឯកជនរដ្ឋាភិបាលត្រូវតំរូវអោយ មានការសិក្សាទៅផលប៉ះពាល់នៃបរិស្ថានដែលយើងហៅកាត់ជាភាសាអង់គ្លេសថា EIA ។ ការសិក្សានេះតំរូវអោយមានការចូលរួម និង វាយតំលៃពីក្រសួងបរិស្ថាននិងស្ថាបន័ពាក់ពន្ធ័ ហើយក្រសួងបរិស្ថានមានសិទ្ធិ ផ្តល់យោបល់ជូននាយករដ្ឋមន្ត្រីថាគួរផ្តល់អោយ ឬ មិនគួរយោងទៅលើរបាយ៍ដែលបានសិក្សាឃើញ។ ជាធម្មតាគោលការណ៍បានកំណត់ថារាល់ការផ្តល់ដីសម្បទានគឺត្រូវធ្វើទៅលើតំបន់ណាដែលមានព្រៃរិចរឹល ប៉ុន្តែយើងសង្កេត ឃើញថារាល់គម្រោងភាគច្រើនគឺមិនអនុវត្តទាំងស្រុងទៅតាមគោលរណ៍ទាំងអស់នេះទេ។

យោបល់ចូលរួម៖ យើងជាសហគមន៍មានការសោកស្តាយដែលបានឃើញការបាត់ព្រៃឈើដ៏ធំធេងតាមរយៈបទបង្ហាញសំណូមពរអោយរាជរដ្ឋាភិបាលគួរតែមានការពិភាក្សា និង ពិគ្រោះយោល់ជាមួយជាមុនសិន មុននឹងសំរេចចិត្តធ្វើការអភិវឌ្ឍន៍គម្រោងផ្សេងៗ។ រាល់បញ្ហាដែលកើតមានសព្វថ្ងៃគឺប្រជាជនជាអ្នករងគ្រោះមិនមែនមន្ត្រីទាំងនោះទេ។

២) ខ្ញុំឃើញនៅក្នុងផែនទីនៃគម្រោងអភិវឌ្ឍន៍ភាគច្រើនគឺជាន់លើដីនៃឧទ្យានជាតិវីរៈជ័យ ដែលជាដីបានឡាយព្រះរាជក្រឹតពីព្រះមហាក្សត្រជាតំបន់ការពារ ហេតុអ្វីបានជាគេធ្វើគម្រោងអភិវឌ្ឍន៍នៅតំបន់ទាំងនោះ?

ចំលើយ៖
ផែនទីដែលបានបង្ហាញជូនពីគម្រោងអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជានេះគឺយើងស្រង់ចេញពីគេហទំព័រ www.opendevelopmentcambodia.net រាល់គម្រោងអភិវឌ្ឍន៍ផ្សេងៗ ត្រូវបានចងក្រង និង សរសេរជារបាយការណ៍។ ចំពោះសំនួរដែលសួរថាហេតុអ្វីក៏មាន គម្រោងអភិវឌ្ឍន៍នៅលើដីតំបន់ការពារ យើងពិបាកនឹងឆ្លើយជូនណាស់ដោយសារតែបរិបទនៅក្នុងប្រទេសកម្ពុជាយើងពេលខ្លះគោលការណ៍ណែនាំ ឬ ក៏ព្រះរាជក្រិតគឺមាននៅតែលើក្រដាសប៉ុណ្ណោះ រីឯការអនុវត្តជាក់ស្តែងគឺមានលក្ខណៈផ្ទុយដាច់ស្រលះ។ ខ្ញុំយល់ថាគម្រោងអភិវឌ្ឍន៍ខ្លះមានការជាន់ទៅនឹងដីការពារនៃឧទ្យានជាតិវិរៈជ័យ តែផ្នែកខ្លះប៉ុណ្ណោះគឺមិនជាន់ ទាំងអស់នោះទេ។

ប្រធានបទបន្តគឺជាបទបង្ហាញរបស់លោក ណក់ វ៉េន ស្តីពីទំនាក់ទំនងរបស់ជនជាតិដើមភាគ តិចទៅនឹងកម្មវិធីរ៉េដបូក ការប្រែប្រួលអាកាសធាតុ និង ការព្រួយបារម្ភ។

សំនួរ និង យោបល់ចូលរួមសំខាន់ៗមួយចំនួនលើប្រធានបទនេះមានដូចខាងក្រោម៖

១) តើជនជាតិដើមភាគតិចនឹងទទួលបានអ្វីខ្លះពីគម្រោងរ៉េដបូក?

ចំលើយ៖
ជនជាតិដើមភាគតិចនឹងទទួលបាននូវការកសាងសមត្ថភាពលើសកម្មភាពគម្រោងរ៉េដបូក ការទទួលស្គាល់នូវសិទ្ធិប្រើប្រាស់ជាប្រពៃណី ការអភិរក្សនូវធនធានព្រៃឈើ សំរាប់មនុស្សជំនាន់ក្រោយ និង ជាពិសេសគឺប្រាក់ចំណូលពីការលក់កាបូនជូនដល់សហគមន៍។

២) តើការដាំចំការឈើហូបផ្លែ និង ដំណាំកៅស៊ូអាចចាត់បញ្ចូលទៅក្នុងកម្មវិធីរ៉េដបូក បានដែលឬទេ?

ចំលើយ៖
មិនអាចធ្វើទៅបានទេពីព្រោះគោលការណ៍របស់កម្មវិធីរ៉េដបូកគឺគេអនុវត្តតែទៅលើ តំបន់ដែលមានព្រៃឈើធម្មជាតិ និងតំបន់ដែលមានព្រៃឈើសឹករិចរិល។ យើងមិនអាច កាប់ព្រៃធម្មជាតិហើយជំនួសមកវិញដោយដំណាំឈើហូបផ្លែ និង ដំណាំឧស្សាហ៍កម្ម ផ្សេងៗបានឡើយ។

៣) ហេតុអ្វីបានជាការកាប់បំផ្លាញព្រៃឈើនាំអោយបាត់បង់កាបូន?

ចំលើយះ
ដោយសារតែព្រៃឈើមានតួនាទីស្តុកកាបូន នៅក្នុងបរិយាកាសធម្មជាតិ ដូចយើងឃើញស្រាប់រាល់ផ្សែងពុល ផ្សេងៗក្នុងបរិយាសគឺត្រូវបានស្រូបយកដោយដើមឈើដូចច្នោះប្រសិនបើយើងកាប់បំផ្លាញដើមឈើនោះយើង នឹងបាត់បង់នូវភ្នាក់ងារសំយោគ ខ្យល់កខ្វក់ក្នុងបរិយាកាសមួយវិញទៀតនឹង មានការកើនឡើងនូវឧស្ម័នពុល ចេញពីដើមឈើ ដែលកាប់បំផ្លាញទាំងនោះ។

យោបល់ចូលរួមះ សព្វថ្ងៃដើមឈើធំៗនៅក្នុងខេត្តស្ទឹងត្រែងត្រូវបានកាប់បំផ្លាញស្ទើរតែទាំងស្រុង ប្រសិនបើ អនុវត្តកម្មវិធីរ៉េដបូកគួរតែពិចារណារៀបចំផែនការដាំកូនឈើជាមុនសិន។ គួរមានការដាក់ បញ្ចូលសកម្មភាព ដាំកូនឈើនៅតាមសាលារៀន និង វត្តអារ៉ាម។

កម្មវិធីបន្ទាប់គឺការបង្ហាញខ្សែវីដេអូពីបទពិសោធន៍អនុវត្តកម្មវិធីរ៉េដបូកនៅខេត្តឧត្តរមានជ័យ និង បទបង្ហាញ ពីការងារអនុវត្តកម្មវិធីរ៉េដរបស់អង្គការស៊ីឱអេ ដោយលោក ជី បូរ៉េត នាយកអង្គការ ស៊ី ឱអេ។
សំនួរ និងយោបល់ចូលរួមសំខាន់ៗមួយចំនួនលើប្រធានបទនេះមានដូចខាងក្រោមះ

១)តើគម្រោងរ៉េដបូកនៅខេត្តឧត្តរមានជ័យបានលក់កាបូនហើយឬនៅ? តើមាននិតិវិធីបែបណាខ្លះក្នុងការ លក់កាបូន?

ចំលើយះ
រហូតមកដល់ពេលនេះគម្រោងមិនទាន់បានលក់កាបូននូវឡើយទេ ប៉ុន្តែយើងបាន ដឹងទិន្នន័យចំនួនកាបូនស្តុក នៅក្នុងគម្រោងសាកល្បងរបស់យើងហើយ។បញ្ហាដែលយើងកំពុងជួបប្រទះគឺកង្វះនូវការរៀបចំឯកសារសំរាប់ លក់កាបូនហើយយើងកំពុងតែជជែកគ្នា ជាមួយរដ្ឋបាលព្រៃឈើដើម្បីកំណត់នូវនិតិវិធីទាំងនេះ។ និតិវិធីក្នុងការ លក់កាបូនមានចំនុច សំខាន់ៗមួយចំនួនដូចជាះ ការរៀបចំកិច្ចព្រមព្រៀងជាមួយរដ្ឋាបាលព្រៃឈើក្នុងការប្រើ ប្រាស់ផែនការថវិកា, កិច្ចព្រមព្រៀងប្រើប្រាស់ថវិកាជាមួយសហគមន៍ និង កិច្ចព្រមព្រៀងលើតំលៃលក់កាបូន។

២) តើគម្រោងរ៉េដបូករបស់អង្គការស៊ីឱអេមានការលេចធ្លាយដែលឬទេ?

ចំលើយះ
